ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2015, 13:40
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៧៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង) *(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

លោក រូស្សែល ហប់គីនស៍ *(Mr. Russell HOPKINS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកអាកទួរ វែកគែន*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ដួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ្រ ជឹម (2-TCW-809) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ពេជ្រ ជីម ហៅ តាជីម** (2-TCW-809)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................ទំព័រ ៥
សួរដោយលោក អាកឡូរ វែកគែន ផ្តើមពី ....................ទំព័រ ៣៦
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៥៦
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ពេជ្រ ជឹម។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យលោក នួន ជា អវត្តមានដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សី ដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ពេជ្រ ជឹម។ លោក និងមេធាវីប្រឹក្សាលោក មឿន សុវណ្ណ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបឋមនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ

ផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ និងឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៦:៣៤]

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈ -- ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី សូមជម្រាបទៅដល់លោក ពេជ្រ ជឹម ថា បានទទួលព័ត៌មានថាលោកមានស្ថានភាពមិនសូវស្រួលខ្លួន ហើយប្រសិនបើលោកមានបញ្ហាត្រូវចង់ចូលទៅបន្ទប់ទឹកអី សូមលោកលើកដៃជាសញ្ញាប្រាប់យើង ដើម្បីយើងអនុញ្ញាតឲ្យលោកចាកចេញទៅ។ កុំខ្លាចរអែងអី លោក ពេជ្រ ជឹម។

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ពេជ្រ ជឹម។

[០៩:០៧:៥៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីទាំងអស់គ្នា។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមលើកឡើងនូវចំណុចបឋមចំនួនពីរ មុននឹងពេលខ្ញុំសួរទៅលើសាក្សី។ ចំណុចទី១ គឺជាបញ្ហានៃពេលវេលាដែលនៅសល់ តើៗវាជាការត្រឹមត្រូវដែរទេ ដែលយើងខ្ញុំនៅសល់ពេលមួយថ្ងៃ

ពេញក្នុងការសួរសំណួរ? ហើយសំណួរទី២ របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងកំណត់ហេតុពីដែលសាក្សីបានផ្តល់ គឺខ្ញុំយោងទៅលើឯកសារ E127/7.1.4 និង E127/7.1.3 គឺកំណត់ហេតុនេះ គឺមានការកោសលុប ដូច្នេះ ខ្ញុំចង់ដឹងថាតើៗ ខ្ញុំអាចអានចម្លើយដែលគេកោសលុប គឺចម្លើយដែលគាត់ផ្តល់ទៅចៅក្រមស៊ើបអង្កេតបានដែរឬទេ? ខ្ញុំចង់អាន។ ឥឡូវនេះស្ថានភាពវាខុសគ្នាដោយសារបទចោទនៅក្នុងសំណុំរឿង០០៤ វាមានការប្រែប្រួល។ ដូច្នេះខ្ញុំចង់ដឹងថាវាអាចដែរឬទេ ដែលខ្ញុំអាចទទួលបាននូវឯកសារដែលមិនមានការកោសលុបបែបនេះ? ប្រហែលជាមានភាពពាក់ព័ន្ធ ព្រោះថាខាងព្រះរាជអាជ្ញាបានលើកឡើងថាសាក្សីក៏បាននិយាយអំពីចំណុចមួយនៅពេលមួយជាក់លាក់។ ខ្ញុំចង់យោង ជាពិសេសទៅលើសំណួរ៤៤ និង ៤៥ នៅក្នុងឯកសារ E127/7.1.4។ ហើយក្នុងផ្នែកនេះគឺមាន ហើយនិងឯកសារនៅក្នុង E127/7.1.3 ត្រង់សំណួរ១-២ ដែលមានការកោសលុប។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ តើលោកចង់បានអ្វីក្នុងពេលឥឡូវនេះ?

**លោក វិចទ័រ កូប៉េ៖**

យើងចង់បានឯកសារដែលមិនកោសលុប។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកចង់ -- គ្រាន់តែចង់បានទទួលឯកសារហ្នឹង ឬក៏គ្រាន់តែចង់អាន?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំចង់បាននៅព្រឹកនេះ ឬក៏នៅពេលឈប់សម្រាកព្រឹកនេះតែម្តង។

[០៩:១០:៤៦]

**លោក ឌេល លីសាក់៖**

ខ្ញុំអាចជម្រាបលោកបន្ថែម ព្រោះថាយើងបានកត់សម្គាល់តាំងពីប៉ុន្មានសប្តាហ៍កន្លងមក ដែលគេបានធ្វើសំណើដែលយើងទទួលបានសំណើឲ្យផ្តល់ឯកសារនៅ -- ដើម្បី -- យើងដើម្បីទទួលបានសិទ្ធិផ្តល់ឯកសារដែលមិនមានការកោសលុប ប៉ុន្តែយើងមិនទាន់ទទួលបានការអនុញ្ញាតនៅឡើយ។ គឺដាក់សំណើនេះតាំងពីបីសប្តាហ៍មុនមកម្ល៉េះ។

ដូច្នេះ ខ្ញុំសង្ឃឹមថាខ្ញុំអាចផ្តល់ព័ត៌មានអ្វីដែលយើងទទួលបាន ប៉ុន្តែយើងមិនអាចទទួលបានឯកសារដែលមិនមានការកោសលុបទេ។ ប៉ុន្តែយើងចង់បញ្ជាក់ថា ប្រហែលជាផ្នែកដែលកោសលុប

នោះមិនមានអ្វីថ្មីនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយយើងបានស្នើរួចទៅហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន តើខ្ញុំអាចឆ្លើយតបបន្តិចបានទេ? ខ្ញុំយល់ថា សេចក្តីសម្រេចនៅមិនទាន់ចេញនៅឡើយ ប៉ុន្តែខ្ញុំចង់ដឹងថាតើចម្លើយរបស់សាក្សីនេះគាត់និយាយអំពីអ្វី? ចម្លើយដែលកោសលុបនេះមានអ្វីដែល -- តើខ្ញុំនិយាយអ្វីគួរឲ្យចង់សើចឬ?

[០៩:១២:១៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនមែនទេ។ ដូច្នេះ ឥឡូវនេះខ្ញុំចង់សួរព្រះរាជអាជ្ញាថា តើយើងអាចទទួលបានចម្លើយ ឬក៏ទទួលបាននូវសេចក្តីសម្រេចពីសហចៅក្រមស៊ើបអង្កេត អំពីសំណើរបស់ព្រះរាជអាជ្ញាបាននៅថ្ងៃនេះដែរឬទេ?

**លោក ឌេល លីសាក់៖**

ខ្ញុំនឹងបញ្ជូនអ៊ីម៉ែលទៅការិយាល័យថា តើយើងអាចទទួលសេចក្តីសម្រេចនៅថ្ងៃនេះ ឬក៏អត់នោះទេ? ប្រហែលជាអាចភាគីណាមួយ ឬក៏នរណាម្នាក់ធ្វើសំណើនេះបន្ថែមទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ដោយសារតែមិនមានការឆ្លើយតប ឬក៏មិនមានការបកស្រាយពីសំណួរទី១របស់ខ្ញុំៗ គិតថាប្រហែលជាខ្ញុំមានពេលមួយថ្ងៃមែន។ ឥឡូវនេះ ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

លោក កូប៉េ លោកពិតជាមានពេលវេលាមួយថ្ងៃនេះដើម្បីស្មើភាពគ្នារវាងភាគីទាំងពីរ ប៉ុន្តែសូមលោកចាប់អារម្មណ៍ លោកជៀសវាងក្នុងការសតាំងសំណួរប្រភេទសំណួរឯណាដែលនីតិវិធីតុលាការហាមឃាត់ ដូចជាសំណួរមិនពាក់ព័ន្ធ សំណួរច្រំដែល សំណួរនាំមុខជាដើម ដែលជាធ្វើការ -- ធ្វើឲ្យអូសបន្លាយពេលវេលា និងឲ្យនីតិវិធីមានទិដ្ឋភាពច្របូកច្របល់។ ខ្ញុំសង្ឃឹមថា លោកយល់ច្បាស់ណាស់ពីបញ្ហានេះ ព្រោះលោកមានអាជីពជាមេធាវីច្រើនឆ្នាំមកហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងព្យាយាមឲ្យអស់ពីលទ្ធភាពមិនសួរសំណួរនាំមុខលោកប្រធាន។

[០៩:១៤:០៦]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោក ពេជ្រ ជឹម ខ្ញុំចង់ពិភាក្សាបន្ថែមទៅលើប្រធានបទមួយចំនួនដែលយើងជជែកគ្នាកាលពីម្សិលមិញ។ ខ្ញុំមានសំណួរបន្ថែមមួយចំនួនទាក់ទងទៅនឹងប្រធានតំបន់ឈ្មោះ សោម។ តើវាជាការត្រឹមត្រូវដែរទេ ដែលប្រពន្ធរបស់គាត់ឈ្មោះ ឈិត ឬក៏ឆាត ហ្នឹង ឥឡូវហ្នឹងគាត់នៅមានជីវិតនៅឡើយ គាត់នៅរស់រានមានជីវិតនៅឡើយ ហើយរស់នៅតំបន់ម៉ាឡៃ។ តើត្រឹមត្រូវទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** កាលពីម្សិលមិញ យើងបាននិយាយអំពី សោម ហើយនិងទស្សនៈនយោបាយ ហើយនិងគោលជំហរនយោបាយរបស់គាត់។ តើលោកអាចប្រាប់ខ្ញុំអំពីទស្សនៈនយោបាយ និងគោលជំហរនយោបាយរបស់ ខុម ដែរឬទេ ថាតើ ខុម ហើយនិង សោម មានគោលនយោបាយ និងទស្សនៈនយោបាយដូចគ្នាឬក៏យ៉ាងម៉េចដែរ នៅក្នុងចន្លោះពេលរបបនោះ?

**ឆ៖** ទាំងពីរនាក់ហ្នឹង នយោបាយទិសទៅតែមួយតាមមាគ៌ារបស់បក្ស។ ប៉ុនកម្រិតខុសគ្នាបញ្ញាជនផ្សេង។ ខុម បឋមសិក្សា ហើយស្រីអាទ ក្មេងទៀត ហើយទៅឡើងធ្វើការការងារខ្ពស់។ ពីតូចនៅស្រុក ប៉ុន្តែចេញបាត់យូរទៅស្គាល់មនុស្សតិចមួយ កម្រិតប៉ុណ្ណឹង សូមអស់។

[០៩:១៦:២៤]

**ស៖** តើ ខុម គាត់ម៉ឺងម៉ាត់នៅក្នុងគោលជំហរនយោបាយ ឬមួយក៏គាត់មានគណៈជ្រុលបន្តិចនៅក្នុងគោលនយោបាយដូចតែ សោម ដែរឬមួយយ៉ាងណា?

**ឆ៖** តាមមើលជ្រុលប្រហែលគ្នា។ បើខ្មែរយើងហៅថា ក្រហមឆេះ ឆេះគេ ឆេះឯង នឹងមានប្រតិកម្មក្នុងស្រុកអ៊ីចឹង កាលធ្វើ សូមអស់។

**ស៖** តើលោកដឹងទេថា នៅក្នុងចម្លើយសារភាពរបស់ ជូ ជេត គឺគាត់និយាយថា សោម ផ្តាច់ការចូលចិត្តរឹតបន្តឹង។ ខ្ញុំសូមដកសំណួររបស់ខ្ញុំចេញវិញ។ លោក ពេជ្រ ជឹម តើលោកអាចប្រៀបធៀបបានទេរវាង សោម ហើយនិង ខុម គឺថា ប្រៀបធៀបគោលជំហរនយោបាយរបស់គាត់ធៀបទៅនឹងស្ត្រីម្នាក់ទៀត ឈ្មោះ ប៊ុន នៅក្នុងតំបន់១០៥ -- ឈ្មោះបឿន នៅក្នុងតំបន់១០៥ ហ្នឹង តើយ៉ាងម៉េចដែរ?

**ឆ៖** ទាំងពីរនាក់នេះ ស្រីហ្នឹង បឿន ល្អជាង។ ទាំងប្រជាប្រិយ ទាំងការងារ ទស្សនៈមហាជន បឿន ល្អជាង។

**ស៖** តើលោកអាចផ្តល់ឧទាហរណ៍បានទេ ថាហេតុអ្វីបានជា បឿន ហ្នឹងគាត់ល្អជាង ខុម ព្រោះថាទាក់ទងតែរឿងគោលជំហរនយោបាយហ្នឹង ហេតុអីបាន បឿន ល្អជាង ខុម សូមលោកផ្តល់ឧទាហរណ៍?

[០៩:១៨:៤៨]

**ឆ៖** គាត់ចាស់ជាង គាត់មានពិសោធន៍ច្រើនជាង។ ខុម ក្មេង ពិសោធន៍នៅតិច ប៉ុនជំហរដាច់ខាតដូចគ្នា។ សូមអស់។

**ស៖** សំណួរចុងក្រោយទាក់ទងទៅនឹង ខុម ខ្ញុំចង់សួរលោក។ លោកផ្តល់សក្ខីកម្មថា គាត់ស្លាប់នៅវ័យក្មេង ហើយក៏ស្លាប់ដោយសារតែជំងឺហើមពោះ។ តើលោកចង់មានន័យថាម៉េចដែល លោកថាជំងឺហើមពោះ ឬហើមក្រពះហ្នឹង?

**ឆ៖** មិនដឹងទេ ប៉ុនឮដល់ថាស្លាប់ ប៉ុន ខុម ឈឺ នៅមើល១០៥ហ្នឹង ខ្ញុំអ្នកថែ ខ្លះគេថា ឆ្កួតជេរគេ ជេរឯង សំខាន់ជេរខ្ញុំហ្នឹងឯងដែលនៅថែផ្ទាល់ សុទ្ធតែអ្វែងអីម៉េចអីអស់ ខ្ញុំអត់ត។ កាលហ្នឹងយកពេទ្យវៀតណាមមកព្យាបាល។ ថាជំងឺអីៗមើលគ្រប់អស់ ហើយវាជាផ្លូវស្រាលមួយកម្រិតទៅក្រោយមក ក៏គាត់តាមប្តីគាត់ ប្តីគាត់ទៅធ្វើការយូរជិតមួយឆ្នាំបានគាត់ទៅតាម។ ទៅហ្នឹង បានឮដំណឹងថា ស្លាប់។ សួរអីក៏ស្លាប់? ថា ហើមពោះ ឃើញហើមពោះធំ។ អ៊ីចឹង រោគហ្នឹងវាទុំ។ ខ្ញុំបានសួររឿងអីវាស្លាប់ ខ្ញុំឆ្លើយថាហើមពោះទៅ ឃើញពោះធំ។ ប៉ុណ្ណឹង។

**ស៖** តើវាអាចទាក់ទងទៅនឹងមូលហេតុខ្វះចំណីអាហារ ឬក៏វាអាចបណ្តាលមកពីមូលហេតុដទៃទៀត?

**ឆ៖** អាហ្នឹងស្រេចពេទ្យ ខ្ញុំអត់ដឹង។

[០៩:២១:៤០]

**ស៖** អត់បញ្ហាអីទេ លោក ពេជ្រ ជឹម ខ្ញុំយល់ពីចម្លើយរបស់លោក។ ឥឡូវនេះ ខ្ញុំសូមបន្តទៅមុខទៀត ទៅលើចំណុចមួយតូចបន្ថែមទៀត ដែលខ្ញុំចាប់ឲ្យលោកបញ្ជាក់បន្ថែម។ ក្នុងសក្ខីកម្មរបស់លោកកាលពីម្សិលមិញ និងថ្ងៃកន្លងមក លោកបាននិយាយថា លោកបានចាកចេញពីតំបន់១០៥ នៅខែកុម្ភៈ ឆ្នាំ៧៧ ប៉ុន្តែគេសួរសំណួរមួយនេះរួចទៅហើយ ជាមួយលោកគឺសួរដោយព្រះរាជអាជ្ញា។ គឺ

ឯកសារ E319.1.18 គឺសំណួរ១៧២ និង១៧៣។ លោកសាក្សី ខ្ញុំនឹងអានជូនលោកស្តាប់ អ្នកស៊ើបអង្កេតសួរថា នៅពេលដែលលោក -- "នៅក្នុងកិច្ចសម្ភាសន៍របស់លោកពីមុនជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតដែលធ្វើឡើងនៅថ្ងៃ២៥ តុលា ២០០៩ លោកបានទៅដល់ភូមិភាគកណ្តាលនៅថ្ងៃទី១២ ឆ្នាំ៧៧។ ឥឡូវនេះ លោកបាននិយាយថាលោកទៅដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ៧៦ តើលោកច្រឡំឆ្នាំ ឬក៏ចងចាំឆ្នាំខុស? លោកឆ្លើយថា "ខ្ញុំទៅដល់ភូមិភាគកណ្តាលនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ៧៦ ពុំមែនក្នុងឆ្នាំ៧៧ទេ"។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ឥឡូវនេះលោកឆ្លើយថាយ៉ាងម៉េច តើលោកឆ្លើយថាទៅថ្ងៃ១៤ កុម្ភៈ ៧៦ ឬក៏១៤ កុម្ភៈ ៧៧?

**ឆ៖** សូមកែដាក់ ១៤ កុម្ភៈ ៧៦។ អាហ្នឹង ទាក់ទងខ្ញុំរៀនសាលាបក្សជាមួយលោក នួន ជា ហើយចេញមក បានខែ២ហ្នឹង មកតែម្តង។ ចាំត្រង់ហ្នឹងជាគោល។ ក្រោយរំដោះមក មករៀនភ្នំពេញ រៀនភ្នំពេញ ចេញទៅបានពីរខែ ១៤ថ្ងៃ ត្រូវមកភូមិភាគកណ្តាលមក។ សូមអស់។

[០៩:២៤:២៨]

**ស៖** ដូច្នេះ ចម្លើយចុងក្រោយរបស់លោក គឺ១៤ កុម្ភៈ ៧៧ មែនទេ?

**ឆ៖** ៧៦។

**ស៖** សូមទោសខ្ញុំនិយាយខុស។ អ៊ីចឹង មានន័យថាលោកអត់មានការងារពាក់ព័ន្ធអ្វីនៅស្រុកត្រាំកក់ទេ ក្រោយថ្ងៃ១៤ កុម្ភៈ ៧៦នុ៎ង អ៊ីចឹងមែនទេ?

**ឆ៖** ពិតហើយ។

**ស៖** លោក ជឹម ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញជូនលោកនូវឯកសារ គឺឯកសារដែលគេសួរសំណួរលោក នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនូវទំព័រមួយនៃឯកសារ E3/2107 ហើយខ្ញុំសូមបង្ហាញខ្មែរមានលេខ 0068049។

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងផ្តល់លេខ ERN អង់គ្លេស នៅពេលបន្តិចទៀតនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី ខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើចម្លើយ ដែលលោកផ្តល់ដល់សហចៅក្រមស៊ើបអង្កេត គឺ E3/5786 សំណួរចម្លើយ៣៩។ ហើយលោកប្រធាន ឯកសារ គឺឯកសារអង់គ្លេសមានលេខ 00290205។ ខ្ញុំឱ្យលោកមើលឯកសារហ្នឹង ហើយខ្ញុំនឹងអានន្ទូវចម្លើយដែលលោកផ្តល់ទៅលើឯកសារនេះ ហើយខ្ញុំនឹងសួរលោក ថាតើចម្លើយដែលលោកផ្តល់ហ្នឹង វាត្រឹមត្រូវ ឬមួយក៏យ៉ាងម៉េច?

[០៩:២៧:៤៥]

ភាសាបារាំងមានលេខ 00655729។ សំណួរ នេះគឺជាឯកសារដែលមានលេខ 0068046, 0068082។ ខ្ញុំចង់ឱ្យលោកមើល។ យើងចង់ឱ្យលោកមើលទំព័រទី៤ ដែលមានលេខ ERN 49នៅខាងចុង។ លោកឆ្លើយថា "អក្សរនេះមានខ្លឹមសារថា មន្ទីរអប់រំ១០៨ ចាប់ពីថ្ងៃយើងកម្ទេចពួកអាខ្មាំងមកទល់សព្វថ្ងៃនេះ អស់ចំនួន ១៥០០០នាក់។ សូមបក្សជ្រាប មន្ទីរអប់រំស្រុក១០៥ ហត្ថលេខា អាន់។ អក្សរនេះពិតជាអក្សររបស់ឈ្មោះ អាន់ ដែលជាប្រធានមន្ទីរអប់រំក្រាំងតាចាន់។ អក្សរនេះ ហាក់មានពីរម្ចាស់។ អក្សររបស់ឈ្មោះ អាន់ គឺ អក្សរដែលមាននៅពីរបន្ទាត់ខាងក្រោម គឺចាប់ពី សូមបក្សជ្រាប រហូតដល់ហត្ថលេខា ដែលមានដាក់ឈ្មោះ អាន់។ ឯអក្សរបួនបន្ទាត់ខាងលើខ្ញុំមិនដឹងជាអក្សររបស់អ្នកណាទេ"។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកចាំថាលោកផ្តល់ចម្លើយបែបនេះជូនទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** រឿងនេះជារឿង អាន់ ផ្ញើមកប្រធានស្រុក មិនដឹងគាត់បានទទួល ឬក៏អត់ទេ ខុម។ ប៉ុន្តែអក្សរពីរ អក្សរពីរនាក់ យកជាការក៏ត្រឹមត្រូវ១០០ភាគរយ ក៏មិនបាន នេះទស្សនៈខ្ញុំ។ ឯគេរាយការណ៍ រាយការណ៍ចំនួនមនុស្ស ហ្នឹងគេធ្វើគេដឹងហើយ ខាងគេធ្វើគេដឹង។ ហ្នឹងត្រឹមត្រូវរបស់គេហើយ ប៉ុនខ្ញុំអត់ដឹង អត់បានធ្វើ មិនមែនការងារខ្ញុំ ការងារខ្ញុំនៅក្រៅនេះ។ ដឹងតែសុំអង្ករ ឱ្យអង្ករ មានគេតវ៉ាសុំខ្ញុំធ្វើពាក្យតវ៉ា ឬក៏ទៅសុំតំបន់ផ្ទាល់។ មិនច្រើនធ្វើពាក្យទេ សុំផ្ទាល់មាត់តែម្តង ឈ្មោះនេះមួយ នេះពីរថ្ងៃក្រោយគាត់គិតពិចារណា ហើយគាត់អនុញ្ញាត និងមិនអនុញ្ញាតគឺលើគាត់។

[០៩:៣០:៤៨]

**ស៖** លោក ជឹម វាហាក់ដូចជាប្លែកបន្តិច ដែលថាកំណត់ត្រានិយាយអំពីមនុស្ស ១៥០០០នាក់ ប្រហែលជាជនរងគ្រោះនៅក្រាំងតាចាន់ ប៉ុន្តែបែរជាមានសរសេរអក្សរពីរនាក់ទៅវិញ ឬក៏ថាមានមនុស្សពីរនាក់សរសេរអក្សរ។ តើលោកពន្យល់បានទេ ហេតុអ្វីបានជាលោកឆ្លើយថាវាមានកំណត់

ហេតុសរសេរដៃដោយពីរនៅក្នុងឯកសារមួយនេះដែរទេ?

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ដោយសារតែសំណួរហ្នឹងមានការនាំមុខ ដោយសារនិយាយថាវាជារឿងប្លែក។ ដូច្នេះវាជាការនាំមុខចំពោះសក្ខីកម្មព្រោះថាវាយើង វាមិនអាចនោះទេព្រោះថាពេលខ្លាចវាអាចមានអ្នកជួយសរសេរនូវខ្លឹមសារនៃឯកសារអ្វីនោះទេ។ ខ្ញុំមិនជំទាស់ទៅលើសំណួរបើកនោះទេ ប៉ុន្តែខ្ញុំជំទាស់ទៅលើការនិយាយនាំមុខដោយថាវាមានលក្ខណៈប្លែក ឬក៏ចម្លែកទៅលើឯកសារនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាការជជែកគ្នាអំពីការនាំមុខវា គឺរឿងគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ប៉ុន្តែ -- ព្រោះកន្លងមកព្រះរាជអាជ្ញាក៏ធ្វើតែនាំមុខអ៊ីចឹង ប៉ុន្តែខ្ញុំគ្រាន់តែជាការសួរដេញដោលតែប៉ុណ្ណោះ ដូច្នេះខ្ញុំគិតថាវាអាច ដូចថាខ្ញុំសួរថាវា ឯកសារនេះវាចម្លែក ឬក៏មិនចម្លែក អ្វីជាដើមទាំងអស់នេះមាននៅក្នុងដីកាដំណោះស្រាយឬក៏អត់។ ហើយវា -- ទោះជាយ៉ាងណាក៏ដោយអ្វីដែលខ្ញុំសួរវាជារឿងសមស្រប។

**លោក ខេល លីសាក់៖**

ខ្ញុំយល់ស្របថាប្រសិនបើវាជា -- ប្រសិនបើគាត់សួរថាឯកសារហ្នឹងចម្លែក មិនចម្លែក អាហ្នឹងវាជារឿងត្រឹមត្រូវ វាអត់មានការនាំមុខអីនោះទេ។

[០៩:៣២:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អត់បញ្ហា ថាតើវាចម្លែកឬក៏មិនចម្លែក ដែលចំណាររហ្នឹងគឺយើងមើលទៅឃើញថាមានអក្សរសរសេរដៃពីរប្រភេទ គឺមានអក្សរសរសេរដៃហ្នឹង ពីរនាក់?

**លោក ពេជ្រ ជឹម៖**

**ឆ៖** បាទ ខ្ញុំយល់ឃើញថា គេរាយការណ៍ត្រឹមត្រូវរបស់គេ។ ប៉ុន្តែអក្សរហ្នឹងពីរនាក់។ មួយបន្ទាត់ក្រោមម្នាក់ ប្រាំបន្ទាត់លើម្នាក់។ ត្រឹម "ជ្រាប"ហ្នឹងម្នាក់ ហើយមន្ទីរអប់រំស្រុក១០៥ អាន់ ម្នាក់។ ប៉ុន្តែ ខ្ញុំមិនដឹងថាយ៉ាងម៉េចអាហ្នឹងអង្គការ តុលាការមើលដោះស្រាយតាម វិភាគតាមហ្នឹងចុះ។ ខ្ញុំមិនមានសមត្ថភាព មានយោបល់ថាម៉េចដែរ។ សូមអស់។

**ស៖** ខ្ញុំពេញចិត្តនឹងចម្លើយរបស់លោក ប្រហែលជាយើងត្រូវការអ្នកជំនាញដើម្បីពិនិត្យមើលចំណុចនេះ។ ខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងឯកសារក្លែងក្លាយនៅក្នុងស្រុកត្រាំកក់ ដូចជាយើងបានលើក

ឡើងខាងដើមឈ្មោះ ហឿន ហើយនិង តាសាន ក៏ត្រូវអង្គជំនុំជម្រះស្ដាប់ចម្លើយពីមុនហើយ និយាយអំពីអត្ថិភាពនៃការក្លែងក្លាយឯកសារនៅក្នុងស្រុកត្រាំកក់។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះមើលថាវាត្រឹមត្រូវទេថាមានឯកសារណាត្រូវបានគេៗកែច្នៃ ឬក៏ត្រូវបានគេក្លែងក្លាយនៅក្នុងស្រុកត្រាំកក់ទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ។

**ស៖** តើត្រឹមត្រូវទេថា មុនខែកុម្ភៈ ឆ្នាំ១៩៧៦ លោកមិនបាន -- មិនដែលធ្លាប់ឮថាមានឯកសារត្រូវគេក្លែងបន្លំទេ?

**ឆ៖** អត់ទេ អត់បានឮទេ។

[០៩:៣៦:១៨]

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត លោកពេជ្រ ជឹម។ គឺចម្លើយដែលកម្មាភិបាលម្នាក់មកពីស្រុកត្រាំកក់បានឆ្លើយ ហើយក្រោយមកគេក៏ផ្លាស់គាត់ទៅតំបន់២៥។ ហើយខ្ញុំសូមអានចម្លើយរបស់គាត់ឲ្យលោកស្ដាប់ ហើយសួរមើលថាតើលោកយល់ថាជាដូចម្ដេចដែរ? នេះគឺឯកសារ E127/7.1.8, ERN ភាសាអង់គ្លេស 00901570, ខ្មែរ 00893276 ដល់ 77 ហើយបារាំង 008--

**អ្នកបកប្រែ៖**

បាទ តាមលេខឯកសារអត់ទាន់ទេលោកប្រធាន គាត់ -- មេធាវីអានលេខ ERN ញាប់ពេក។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[០៩:៣៧:៣៧]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អានបញ្ជាក់អ្នកនូវលេខ ERN សាជាថ្មីម្ដងទៀត ព្រោះអ្នកបកប្រែបកអត់ទាន់ទេ។ សូមឲ្យយឺតៗ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមទោសលោកប្រធាន។ ខ្មែរគឺ00893277, ERN ជាភាសាអង់គ្លេស 00901569 ហើយនិងភាសាខ្មែរ 00978648។ សំណួរទៅកាន់កម្មាភិបាលនេះគឺដូចតទៅត្រង់សំណួរលេខ៥៖ “ក្នុងនាមតួនាទីជាគណៈឃុំកំពង់ស្វាយ តើលោកមានតួនាទីបញ្ជាពីថ្នាក់លើឲ្យចាប់មនុស្សដែរឬទេ? ឆ្លើយ៖ ក្នុងតួនាទីខ្ញុំជាគណៈឃុំ ខ្ញុំមិនមានចិត្ត និន្នាការនេះអ្នកណាម្នាក់ដែលធ្វើខុសនោះទេ។ ខ្ញុំមានសិទ្ធិវាយ-

ការណ៍ទៅថ្នាក់លើ ដូចជាពេលណាប្រជាជនមិនមានចំណីអាហារហូបគ្រប់គ្រាន់ ហើយនៅពេលដែលយើងធ្វើ -- ប្រជាជនធ្វើស្រែបានតែ ២តោនក្នុង១ហិកតា។ ក្នុងបញ្ហានេះ តាម៉ុក បានដាក់បញ្ហាថាត្រឹមថ្នាក់ឃុំ ស្រុក និងតំបន់ គឺគ្មានសិទ្ធិបញ្ជាឲ្យចាប់ ឬសម្លាប់មនុស្សទេ។ សំណួរ៖ តើថ្នាក់ឃុំមានសិទ្ធិរាយការណ៍ទៅថ្នាក់ណា? ថ្នាក់ឃុំមានសិទ្ធិរាយការណ៍ទៅថ្នាក់ស្រុក ប៉ុន្តែដើម្បីរាយការណ៍អំពីបុគ្គលណាម្នាក់ ថ្នាក់ឃុំដែលមានសមាជិកប្រាំនាក់ទៅ ប្រាំពីរនាក់ទៅប្រជុំដើម្បីសម្រេចឯកភាពគ្នា មុននឹងរាយការណ៍ទៅស្រុក។ សួរ៖ លោកថា តាម៉ុក និយាយថា ថ្នាក់ស្រុក និងតំបន់ គ្មានសិទ្ធិសម្លាប់មនុស្សទេ។ ហេតុអ្វីប្រជាជនជាច្រើនត្រូវបានគេសម្លាប់នៅតាមថ្នាក់ស្រុកនិងតំបន់? ឆ្លើយ៖ ខ្ញុំមិនដឹងដែរចំពោះការអនុវត្តនៅតាមតំបន់ និងស្រុកនានា។ តែខ្ញុំចាំច្បាស់នូវពាក្យសម្តីរបស់ តាម៉ុក។ សួរ៖ តើតាម៉ុក ជាគណៈភូមភាគិនិរតីឬ? ឆ្លើយ៖ បាទ”។ ឥឡូវចូលដល់ផ្នែកសំខាន់មួយទៀត លោក ពេជ្រ ជឹម។ “សួរ៖ តើ តាម៉ុក ធ្វើការប្រកាសនេះនៅពេលណា? ឆ្លើយ៖ តាម៉ុក បានធ្វើការប្រកាសនេះនៅមុនឆ្នាំ១៩៧៥ នៅពេលមានកិច្ចប្រជុំបូកសរុប ដែលត្រូវបានធ្វើឡើងនៅក្នុងព្រៃ មួយឆ្នាំម្តងដោយមានការចូលរួមពីគណៈឃុំ ស្រុក ខេត្ត និងកងវរៈ។ ក្រោយឆ្នាំ១៩៧៥ មានការប្រជុំម្តងទៀតនៅទីរួមខេត្តតាកែវ ដោយមាន តាម៉ុក ចូលរួម ហើយឈ្មោះ សោម ដែលជាគណៈតំបន់១៣ បានធ្វើការប្រកាសថា ហាមប៉ះពាល់ទាហានរបបលន់នល់ ពីស័ក្តិ១ ដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់ទេ។ សួរ៖ តើលោកមានន័យថា មិនមានការចាប់ចងទាហានលន់នល់ ពីស័ក្តិ១ ដល់ស័ក្តិ៥ ទេឬ? ឆ្លើយ៖ ខ្ញុំមិនដឹងដែរពីព្រោះតំបន់ផ្សេងៗមានការអនុវត្តផ្សេងគ្នា”។ បញ្ចប់ការដកស្រង់។

លោក ពេជ្រ ជឹម កម្មាភិបាលមកពីភូមិភាគនិរតីម្នាក់នេះ ដែលបានធ្វើការនៅតំបន់២៥ បាននិយាយអំពីការប្រជុំពីរលើកដែលនៅក្នុងការប្រជុំទាំងពីរលើកនេះ តាម៉ុក បានប្រកាសថាទាហាន ចាប់ពីស័ក្តិ១ ដល់ស័ក្តិ៥ គឺមិនត្រូវប៉ះពាល់ទេ។ សំណួរខ្ញុំ តើនៅក្នុងកិច្ចប្រជុំទាំងពីរលើកនេះ លោកមានវត្តមានដែរឬទេ?

[០៩:៤១:៥៤]

**លោក ខេល លីសាក់៖**

ជំទាស់របស់ខ្ញុំគឺថាគាត់បានអាន -- សាក្សីបាននិយាយថា កិច្ចប្រជុំមួយអ្នកណាមានសិទ្ធិ ហើយកិច្ចប្រជុំទីពីរ -- គឺមានកិច្ចប្រជុំពីរនេះ វាមិនពាក់ព័ន្ធទៅនឹងអ្នកដែលមានពាក់ស័ក្តិទាំងពីរលើកនោះទេ ប៉ុន្តែគាត់និយាយពីកិច្ចប្រជុំទាំងពីរលើក។

**សួរដោយលោក វិ៉ចទ័រ កូប៉េ៖**

**ស៖** លោក ពេជ្រ ជឹម កម្មាភិបាលភូមិភាគនិរតីមកពីតំបន់២៥ម្នាក់នេះ និយាយអំពីកិច្ចប្រជុំពីរលើក។ កិច្ចប្រជុំមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៥។ តើលោកនៅចាំថាលោកបានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយក្នុងកិច្ចប្រជុំទាំងពីរ ឬក៏បានចូលរួមក្នុងកិច្ចប្រជុំទាំងពីរលើកនេះដែរឬទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ខ្ញុំបានចូលរួមកិច្ចប្រជុំក្រោយ៧៥ នៅសាលាបក្ស ក្រោយសន្និបាតដែល តាម៉ុក មកចូលរួម បក្សតំបន់។ ប្រកាសអ៊ីចឹង សំណើអ៊ីចឹង។ អាលើកទី១ តាមព្រៃមិនបានចូលរួម។ អាច ខុម ចូលរួម ឬអ្នកណាទៀត ព្រោះពេលដែលជំនាន់នោះ មិនងាយធ្វើបានមូលទាំងអស់គ្នាទេ ដឹងមួយផ្នែក។ ចាំដឹងតតាមគ្នា។ សូមអស់។

[០៩:៤៣:៣៩]

**ស៖** មិនថ្វីទេ ខ្ញុំនឹងផ្ដោតទៅលើការប្រជុំលើកទី២ នៅទីរួមខេត្តតាកែវ។ កម្មាភិបាលម្នាក់នេះនិយាយអំពីកិច្ចប្រជុំនៅក្រោយឆ្នាំ១៩៧៥។ តើលោកអាចរៀបរាប់ឲ្យបានច្បាស់លាស់បន្តិចថាតើ កិច្ចប្រជុំនេះប្រារព្ធធ្វើឡើងនៅទីណាដែរ? ធ្វើនៅតាកែវ នៅពេលដែលមានវត្តមាន តាម៉ុក និងតាសោម ឬក៏អត់ទេ?

**ឆ៖** នៅតាកែវក្រោយរំដោះ ដូចច្រឡំទៀតតាមមើល។ បើនៅតាកែវ ក្រោយរំដោះហើយ មិនមែនមុនទេ។ ក្រោយ៧៥ ធ្វើនៅចាស់ មាត់ទឹក ខាងជើងក្រុង ហ្នឹងធ្វើហ្នឹង។ ធ្វើហ្នឹង រៀនសូត្រហ្នឹងទ័ពទាំងអស់ ទ័ពទាំងមេទ័ព ទាំងភូមិភាគទាំងអស់ចូលរួម គណៈតំបន់ទាំងអស់ ស្រុកទាំងអស់ ប៉ុនលក្ខណៈដែលជាបុគ្គលណាមានភារកិច្ចផ្សេងអាហ្នឹងអវត្តមានទៅ។ ប៉ុនធ្វើៗនៅហ្នឹង ហើយប្រកាសអ៊ីចឹងមែន។ អស់។

**ស៖** លោក ពេជ្រ ជឹម ពីម្សិលមិញយើងបាននិយាយអំពីកិច្ចប្រជុំរយៈពេលបួនថ្ងៃ នៅក្នុងខែឧសភា ១៩៧៥ នៅភ្នំពេញ។ គឺកិច្ចប្រជុំនៅថ្ងៃទី២០ ទៅដល់ទី២៤ ឧសភា។ កិច្ចប្រជុំនៅក្នុងខេត្តតាកែវ តើជាកិច្ចប្រជុំមួយក្រោយពីលោកបានចូលរួមកិច្ចប្រជុំនៅភ្នំពេញ នៅថ្ងៃទី២០ ឧសភា ១៩៧៥ អាហ្នឹងជាកិច្ចប្រជុំបន្ទាប់ពីហ្នឹង ឬក៏យ៉ាងណាដែរ?

[០៩:៤៥:៥៥]

**ឆ៖** នៅតាកែវក្រោយ ក្រោយពីប្រជុំនៅភ្នំពេញ។ សូមបញ្ជាក់ច្រើន អត់មានធ្វើបញ្ជីប្រជុំ

ជួនកាល នេះហៅ នោះហៅ។ ពីនោះមកដល់នេះ ឆ្លើយក៏វង្វេងដែរ ខ្លះត្រូវ អាចខ្ញុំឆ្លើយខុស។ សួរអាមុន អាក្រោយ បន្ទាប់ដូចលេខរៀងសៀវភៅ ធ្វើការហ្នឹង គ្មានសៀវភៅឯណា កត់គោល១មួយមាត់ៗ អត់ចាំ កន្លែងណាដែលធ្វើញឹកដែងង ចាំ។ គ្រាន់តែចូលប្រជុំៗ ហើយផែនការផ្សាយអស់ ទៅទទួលមួយទៀត ផ្សាយទៀត មិនចាំទាំងអស់ទេ។ សូមអរគុណ សូមអត់ទោស សូមអស់។

**ស៖** ប៉ុន្តែលោកអាចបញ្ជាក់អះអាងបានទេ ថាចម្លើយរបស់កម្មាភិបាលមកពីភូមិភាគនិរតីម្នាក់នេះដែលបានប្រាប់ទៅអ្នកស៊ើបអង្កេត ថា តាម៉ុក បានប្រកាសថា ទាហានចាប់ពីស័ក្តិ១ ដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់។ តើលោកនៅតែប្រកាន់ ឬក៏បញ្ជាក់ថាដូចសម្តីរបស់កម្មាភិបាលម្នាក់ ឬក៏យ៉ាងណា?

**ឆ៖** អឺចឹងមែន។ ប៉ុន្តែជួនគាត់ទៅប្រកាសនោះទៀត កន្លែងនោះទៀត។ អឺចឹងរកកំណត់ជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ប៉ុន្មានដង អាណាមុនអាណាក្រោយ មិនបាន។ ប៉ុនពាក្យហ្នឹង ត្រឹមត្រូវហើយ។ សូមអស់។

[០៩:៤៨:០៥]

**ស៖** តើលោកមានចាំថា មានកម្មាភិបាលផ្សេងទៀតមកពីស្រុក១០៥ មានវត្តមានក្នុងកិច្ចប្រជុំនេះទេ? ជាពិសេស តើលោកចាំថា ហឿន នេះ មានវត្តមាននៅក្នុងកិច្ចប្រជុំមួយនេះដែរទេ?

**ឆ៖** មិនមានទេ។ ហ្នឹងនិយាយពីប្រជុំតាកែវ ហឿន មិនមានទេ។ ហើយគាត់ទៅនិយាយនៅ២៥ ហ្នឹងគាត់ដឹងតតាមគេមក គាត់ទៅនិយាយបន្តទៀត។ ហ្នឹងក៏ជាការត្រូវ មិនខុសទេ។

**ស៖** ខ្ញុំឮការបកប្រែជាភាសាអង់គ្លេស ថាគាត់ ក៏ប៉ុន្តែយើងនិយាយបុគ្គលម្នាក់នេះគឺស្រី គឺ ហឿន តើត្រឹមត្រូវទេ?

**ឆ៖** ហឿន ឬក៏ ពឿន ដែលនិយាយថា រាយការណ៍ហ្នឹង ថាតើ ហឿន ឬពឿន? សូមបញ្ជាក់ឡើងវិញ។

**ស៖** ឈ្មោះ ហឿន គឺស្ត្រីម្នាក់ដែលយើងបាននិយាយពីខាងដើម ដែលខ្ញុំសុំឲ្យធ្វើការប្រៀបធៀបជាមួយនឹងនារី ខុម នោះ?

[០៩:៤៩:៤៦]

**ឆ៖** បាទ។ អឺចឹង ហឿន ហ្នឹងមាន កាលប្រជុំនៅតាកែវហ្នឹង មាន ហឿន ដែរ។ សម្តីហ្នឹងត្រឹមត្រូវហើយ ប៉ុន្តែលោកថាមកប្រជុំនៅតំបន់២៥ ឈ្មោះ ពឿន ផ្សេងទៀត ប្រុស។ ពឿន ហ្នឹងធ្វើប្រធានមន្ទីរទេ ពេលខ្ញុំចេញហួសទៅ ប៉ុន្តែមិនដឹងក្រោយ ផ្លាស់ធ្វើអីខ្លះ អត់ដឹង។ សូមអស់។

**ស៖** លោកនៅចាំទេមានកម្មាភិបាលប្រហែលប៉ុន្មាននាក់ចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំមួយហ្នឹង?

**ឆ៖** ប្រហែលពី៥០ ទៅ ៦០នាក់ ខាងយោធា ខាងមូលដ្ឋាន។ មន្ទីរមិនមានទេ ព្រោះ តាម៉ុក ក៏អត់មានធ្វើមន្ទីរជុំវិញគាត់ មានហៅអ្នកណាមកចូល! មន្ទីរគាត់ គាត់និយាយទៅចេញឃុំ បន្ទាប់ចេញទៅមេកងពល កងពលតូច កងពលធំ វរសេនាធំ វរសេនាតូចអត់មកទេ។ ត្រឹមប៉ុណ្ណឹង ហើយនិងស្រុក សមាជិកស្រុក។ ឃុំខ្លះ មិនទាំងអស់ទេ ស័ក្តិប៉ុនគ្នា ប៉ុន្តែភារកិច្ចខុសគ្នា ឃុំខ្លះចូល ឃុំខ្លះអត់បានចូលទេ។ ឃុំដែលអត់បានចូលចាំទទួលពីស្រុក រួមជាមួយអ្នកដែលបានចូលហើយ។ វាមានការលក្ខណៈពិសេសអ៊ីចឹងក៏មាន។ សូមអស់។

[០៩:៥២:១១]

**ស៖** លោកនៅចាំបានទេថា មាស មុត មានវត្តមាននៅក្នុងកិច្ចប្រជុំមួយហ្នឹងដែរទេ កិច្ចប្រជុំធ្វើឡើងនៅទីរួមខេត្តតាកែវហ្នឹង?

**ឆ៖** ថ្ងៃនោះ អត់មាន មាស មុត ទេ។ មានតែ ភ្លេចឈ្មោះហើយ ងាប់បាត់ហើយ។ កូនប្រសាតាម៉ុក មានលោក រ៉ែន កងពលធំ ហ្នឹងមាន។ មាស មុត អត់ទេ។ ថ្ងៃប្រជុំនោះ អត់មាន មាស មុត ទេ គាត់ជាប់ការងារកងពលទី២ នៅផ្លូវលេខ៤ ចេញពីចោមចៅ រហូតកំពង់សោម។ ហើយលោក សឿង មានមុខ។ លោក រ៉ែន ដែលភារកិច្ចក្រុងផែកំពង់សោម ជើងទឹកមានមុខ។ ក្រៅពីហ្នឹងកងពលៗមានទាំងអស់ ផ្នែកខាងត្បូង អ្នកនៅខាងជើង អត់ទេ។

**ស៖** សូមអរគុណលោក ពេជ្រ ជឹម។ ខ្ញុំសាកសួរទៅលោក ប្រហែលជាពិបាកចងចាំបន្តិចហើយ ប៉ុន្តែសូមឲ្យលោកប្រាប់ខ្ញុំ អំពីអ្នកចូលរួមក្នុងកិច្ចប្រជុំនេះ។ តើលោកនៅចាំអ្នកណាផ្សេងទៀត ឬក៏អ្នកកម្មាភិបាលណាដែលសព្វថ្ងៃនៅរស់នៅឡើយ ហើយបានចូលរួមប្រជុំ ហើយបាននិយាយប្រាប់លោកអំពីកិច្ចប្រជុំហ្នឹង ថាគេនិយាយពីអ្វីខ្លះទេ?

[០៩:៥៤:៥៥]

**ឆ៖** អត់ចាំទេ។ ចាំបានខាងលើមាន តាម៉ុក, មានសោម, ផែន។ ថ្ងៃនោះ ខុម អត់បានចូលរួម គាត់ទៅលេងគ្រួសារ។ ហើយក្រៅពីថ្នាក់តំបន់ មានតែតំបន់១៣ហ្នឹងប៉ុណ្ណឹង ហើយកងពលជុំវិញ បើមេកងពលធំទៅអស់ហើយ មានពលតូចណាទៀត។ អត់ចាំ ចាំអត់អស់។ អត់លោក មុត អត់មាន ប៉ុន្តែមានលោក រ៉ែន។ មានលោក ០៥ ហៅស្អី លោក រឿន ហៅ ០៥។

**ស៖** លោក ពេជ្រ ជឹម កាលពីម្សិលមិញលោកបាននិយាយអំពីបញ្ហាការសម្លាប់ដោយការសង

សឹក។ គឺការសម្លាប់ទាហាន លន់ នល់ ដោយសារតែការចងកំហឹង ដោយការសងសឹក តើការសម្លាប់នេះគឺការសងសឹកនេះដោយសារតែសង្គ្រាមហ្នឹងឬក៏យ៉ាងម៉េចដែរលោក?

**ផ៖** ដោយសារសង្គ្រាម មិនមែនដោយរឿងបុគ្គលទេ។

**ស៖** ប៉ុន្តែសង្គ្រាមវាចប់ទៅហើយ ហើយកិច្ចប្រជុំនេះប្រហែលជាធ្វើឡើងក្រោយខែឧសភា ១៩៧៥។ តើបញ្ហាការសម្លាប់ដោយសារសងសឹកនេះ មាននិយាយនៅក្នុងអង្គប្រជុំហ្នឹងដែរទេ?

**ផ៖** អត់មានទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងកិច្ចប្រជុំមួយនេះ លោកបានបញ្ជាក់ថា តាម៉ុក បាននិយាយ បានប្រកាស ហើយធ្វើការណែនាំទាក់ទងទៅនឹងទាហានលន់ នល់ ដែលមានពាក់ឋានន្តរសក្តិ។ តើ សោម ក៏មាននិយាយនៅក្នុងកិច្ចប្រជុំហ្នឹងដែរទេ?

**ផ៖** ថា តាម៉ុក និយាយហើយ សោម គាត់អត់និយាយទេ ដល់អត់បានគាត់លើកហេតុផលបញ្ជាក់។ ក្រឹត្យក្រមអ៊ីចឹង មេមកនិយាយហើយ ឯងនិយាយសង្កត់ទៀត គាត់ម៉េចនិយាយ។ អ៊ីចឹង សោម ក៏អត់ នរណាក៏អត់ដែរ។ គ្រង់វិធានការមួយៗគឺកត់យកទៅអនុវត្តទៅ។ នេះចាំនៅ បញ្ជាក់ទៅទៀត បាទ ចាំហើយ។ កត់ឬនៅ? កត់ហើយ។ ហ្នឹងម៉ឹងម៉ាត់។ សូមអស់។

[០៩:៥៨:៥០]

**ស៖** ទាក់ទងទៅនឹងចម្លើយចុងក្រោយ ពេលដែលកិច្ចប្រជុំចប់ទៅលោកក៏ចាកចេញពីការប្រជុំ ហើយច្បាស់ណាស់សម្រាប់លោកគឺថា ពេលហ្នឹងគឺថាមានការណែនាំ មិនឱ្យប៉ះពាល់ដល់មន្ត្រីទាហានដែលមានពាក់ឋានន្តរសក្តិនោះទេ។ តើជាការត្រឹមត្រូវដែរទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ជាថ្មីម្តងទៀតគឺមេធាវីការពារក្តី គឺសួរនាំមុខ ហើយបាននាំឱ្យសាក្សីយល់ខុសផង។ ការណែនាំឱ្យប៉ះពាល់ មិនឱ្យហាមអ្នកដែលពាក់ព័ន្ធពីស័ក្តិ១ ទៅដល់ស័ក្តិ៥ទេ មានឋានន្តរសក្តិ៥ ខ្ពស់ជាងស័ក្តិ៥ ហើយប្រាំថ្នាក់ទៀតនៅខាងក្រោមស័ក្តិ១។ អ៊ីចឹងរាល់មន្ត្រីដែលមានឋានន្តរសក្តិនេះ ប៉ុននេះគឺថាយើងត្រូវកោះហៅសាក្សីនេះមកបញ្ជាក់។ ដោយសារព័ត៌មាននេះគឺថាវាមិនច្បាស់លាស់ទាល់តែសោះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លោកមិនគួរសាកសួរតែកម្រិតៗ តែចំពោះឋានន្តរសក្តិដែលគេបានកំណត់

នេះបានហើយ មិនអាចសួរទៅលើឋានន្តរសក្តិទាំងអស់នោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែខ្ញុំគិតឃើញថាស័ក្តិ១ហ្នឹងវាតូចណាស់។

[១០:០០:៣៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំសូមសួរឲ្យច្បាស់ឡើងវិញ។ លោក ពេជ្រ ជឹម តើលោកយល់ច្បាស់ទេ ក្រោយចុងបញ្ចប់នៃកិច្ចប្រជុំ ដែលថាទាហាន ដែលពាក់ស័ក្តិ១ ដល់ស័ក្តិ៥ មិនឲ្យមានការប៉ះពាល់នោះ។ តើលោកយល់ច្បាស់ថាអ៊ីចឹងទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** កាលនោះ និយាយអ៊ីចឹងមែន ហើយយល់ច្បាស់អ៊ីចឹង។

**ស៖** ហើយបើសិនជាទាហានដែលពាក់បណ្តាស័ក្តិប៉ុណ្ណឹង មិនឲ្យមានការប៉ះពាល់ តើមានន័យថាទាហានដែលមានឋានន្តរសក្តិទាបជាងនេះ ក៏មិនត្រូវប៉ះពាល់ដែរ ឬក៏យ៉ាងម៉េច?

**លោក ខេល លីសាក់៖**

ខ្ញុំ-- គាត់សួរនាំមុខសាក្សីទៅទៀតហើយ ដោយគាត់-- គឺថាយកពាក្យនេះ មកឲ្យសាក្សីឆ្លើយតែម្តង។

**លោក វ៉ិចទ័រ កូប៉េ៖**

ការអនុវត្តនៅក្នុងតុលាការនេះ គឺថា ខ្ញុំគួរតែត្រូវបានអនុញ្ញាតថា បើសិនជាសួរអ៊ីចឹង តើវាបង្កប់ន័យថាយ៉ាងដូច្នេះដែរឬក៏អត់? អ៊ីចឹងដូច្នេះ ខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរសំណួរបែបនេះ។

[១០:០២:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធ មិនអនុញ្ញាតឲ្យសួរសំណួរបែបនេះទេ។ សំណួរបែបនាំមុខ ហើយសំណួរបែបនាំឲ្យសាក្សីផ្តល់នូវចម្លើយបែបការសន្និដ្ឋាននេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ពីអត្ថន័យនៃសំណួរនាំមុខនោះទេ អ៊ីចឹងប្រហែលជាខ្ញុំសួរ-ចម្លើយ។ គឺថា សារចេញពីចម្លើយហ្នឹង គឺគ្រាន់តែយកចម្លើយរបស់សាក្សីម្នាក់ ហើយមកសួរបញ្ជាក់ឡើងវិញតែប៉ុណ្ណោះ តើវាជា

សំណួរនាំមុខ ឬក៏យ៉ាងណាទេ? ដូច្នេះ ខ្ញុំចង់បានការណែនាំពីអង្គជំនុំជម្រះ ថាតើសំណួរបែបនេះ វាជាសំណួរនាំមុខ ឬក៏អត់នោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ ច្បាស់លាស់ អង្គជំនុំជម្រះគិតថាវាជាសំណួរនាំមុខ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តី នួន ជា ទេ ព្រោះវាជាសំណួរនាំមុខ។

[១០:០៣:២៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ពេជ្រ ជឹម ខ្ញុំរៀបសំណួរឡើងវិញ។ សេចក្តីណែនាំចេញពី តាម៉ុក ពាក់ព័ន្ធទៅនឹងទាហានពាក់ស័ក្តិ១ដល់ស័ក្តិ៥ អ្នកទាំងនេះ គឺថាមិនត្រូវប៉ះពាល់គេទេ វាច្បាស់ហើយ។ ប៉ុន្តែតើចំណាប់អារម្មណ៍របស់លោក ឬក៏ការយល់របស់លោកនៅពេលនោះ តើលោកយល់យ៉ាងម៉េចដែរ ចំពោះកូនទាហាន ឬក៏នាយទាហានដែលមានឋានន្តរសក្តិទាបជាងសេចក្តីប្រកាសនោះ។ លោកយល់ថាម៉េចដែរ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** អ្នកដែលមានស័ក្តិទាបមកទៀត រត់រួចហើយ បើស័ក្តិ៥ ស័ក្តិ១ ដល់ស័ក្តិ៥ រួចហើយ ក្រោមហ្នឹងវាមហារួចទៅហើយ។ សូមអស់។

**ស៖** ចុះអតីតទាហានដែលមានឋានៈខ្ពស់ជាងវរសេនីយ៍ឯក តើយ៉ាងម៉េចដែរ?

**ឆ៖** មិនដឹង។ ទាហានមកដល់សហករណ៍មិនមានអ្នកវរសេនីយ៍ឯក ឬស័ក្តិ៥ ស័ក្តិ៤ អីមកដល់ទេ ហ្នឹងជម្រាបត្រង់ ច្រើនអ្នកមេម៉ាយ ហើយមនុស្សធម្មតា ទទួលរៀបចំអីចឹង។ ឯអ្នកដទៃទៀតមិនដឹង ឆ្លើយអត់កើត អត់ដឹង អត់ឃើញ។ បើដឹង បើឃើញ បានឆ្លើយកើត។ ដល់ឆ្លើយស្មាន អត់ត្រូវ។ សូមអស់។

[១០:០៥:៥៨]

**ស៖** សូមអរគុណលោក ពេជ្រ ជឹម ដែលបានផ្តល់ចម្លើយនេះ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មី។ ខ្ញុំមានសំណួរប្រហែលតែមួយពីរទៅលើប្រធានបទនេះ គឺការប្រព្រឹត្តចំពោះជនជាតិចាមនៅក្នុងស្រុករបស់លោក។ យើងបានស្តាប់សក្ខីកម្មប៉ុន្មានសប្តាហ៍កន្លងមក គឺអំពីស្ត្រីម្នាក់ដែលគាត់រស់នៅក្នុងស្រុកត្រាំកក់។ គាត់គឺជាជនជាតិចាម ហើយគាត់ផ្តល់សក្ខីកម្មថា មានពេលខ្លះ គេបង្ខំគាត់ឲ្យហូបសាច់

ជ្រូក គឺកម្មាភិបាលមូលដ្ឋាន គឺបង្ខំឲ្យគាត់ហូបសាច់ជ្រូក។ តើលោកដឹងទេថាមានកម្មាភិបាលថ្នាក់ទាបនៅក្នុងមូលដ្ឋានដែលបង្ខំឲ្យជនជាតិចាមនៅក្នុងស្រុកត្រាំកក់ហ្នឹងហូបសាច់ជ្រូក តើមានទេ?

**ឆ៖** អានោះមាន ន៎ៃ ឮបញ្ហាលើកឡើងនៅក្នុងប្រជុំដែរ។ ហើយចុះ យើងបាយរួមសម្លរួមដាក់នឹងខ្ទះទៅ បើដាក់សាច់ជ្រូកទៅ ចុះចាមបានអីហូប។ សួរគាត់មើល គាត់ហូបអត់។ គាត់អត់ហូបអត់ហូបរកអីឲ្យគាត់ហូបក្រៅពីហ្នឹងបន្តិចទៅ។ ដោះស្រាយអ៊ីចឹង មិនមានបង្ខំទេ។ រកអីឲ្យគាត់ហូបក្រៅពីហ្នឹង ស្លអីផ្សេងជាមួយត្រីជាមួយអីទៅ បើអត់ត្រី ដាក់តាមជាក់ស្តែងហ្នឹងទៅ។ ឲ្យតែមានហូបគ្រាន់បើ វីវរអត់ទៀត សភាពការណ៍កាលនោះ បានដោះស្រាយអ៊ីចឹង ហើយថាឲ្យអ្នកណាបង្ខំណាអីក្រែងមានបង្ខំក៏ខ្ញុំមិនដឹង ព្រោះជាមួយអ្នកក្តាប់ផ្ទាល់ គេថាអ៊ីចេះអ៊ីចុះទៅ ប៉ុន្តែសម្តីខ្ញុំនៅដោះស្រាយនៅតែកណ្តាល អត់ឲ្យប៉ះពាល់ទេ។ សូមអស់។

[១០:០៨:២២]

**ស៖** សូមអរគុណលោក ពេជ្រ ជឹម។ ប្រធានបទមួយទៀត គឺថាតើលោកអាចប្រាប់យើងបានទេ អំពីការប្រព្រឹត្តចំពោះជនជាតិវៀតណាមដែលរស់នៅក្នុងស្រុកត្រាំកក់ គឺចន្លោះថ្ងៃ ចន្លោះខែមេសា ៧៥ រហូតដល់ពេលដែលលោកចាកចេញពីត្រាំកក់ នៅក្នុងខែ -- ក្នុងឆ្នាំ៧៦ ម៉្លខែ២ ខែ៣នោះ។ តើលោកអាចប្រាប់បានទេ?

**ឆ៖** ជនជាតិវៀតណាមដោះស្រាយហើយ តែវៀតណាមទៅវិញឲ្យទៅជាមួយ។ ហើយអ្នកដែលមានជាប់ប្តីជាវៀតណាម វៀមណាមក៏សុខចិត្តទៅវិញ ទុកប្រពន្ធនៅនេះ។ ទៅទាំងអស់គ្នាក៏បាន។ ខ្លះចែកកូនមួយម្នាក់ ដោយព្រម ដោះស្រាយអ៊ីចឹងកាលនោះ។ ឯមកដោះស្រាយតមកទៀតមកមិនមាន។ បើមានក៏នៅតែយកគោលការណ៍ហ្នឹងដដែល បើប្តីគ្នាព្រមនៅនេះហើយ ក៏ឲ្យនៅ។ ហ្នឹងជាគោលការណ៍ ដោះស្រាយអ៊ីចឹង។ ខ្ញុំបញ្ជាក់ម្សិលមិញអស់ហើយ។ មែនមិនទាន់ច្បាស់ទេ ច្បាស់ហើយ។ ប៉ុន្តែអនុវត្តគោលការណ៍ហ្នឹងឲ្យត្រឹមត្រូវ ល្អទាំងអស់។ ខ្ញុំកំពុងធ្វើ ខ្ញុំនៅហ្នឹង ក៏វាមិនល្អទាំងអស់វាខ្វះខាតដែរ ធ្វើទាំងអស់គ្នា។ ដល់ខ្ញុំចេញទៅ គេប្រែយ៉ាងម៉េចក៏ខ្ញុំមិនដឹង។ អាហ្នឹង សភាពការណ៍ វាអត់នៅហ្នឹងថ្កល់ វាអត់ប្រែប្រួល វាដោះស្រាយទៅផ្សេងទៀត យើងកំណត់អត់បាន។ សូមអស់។

**ស៖** ក្នុងពេលដែលលោកធ្វើការនៅស្រុកត្រាំកក់ តើលោកដឹងអំពីការធ្វើបាប ឬក៏ការសម្លាប់ជនជាតិវៀតណាមនៅស្រុករបស់លោកនោះដែរឬទេ?

[១០:១១:២៣]

**ធ៖** អត់មានទេ។ កាលនោះ របបលន់នល់ លេងខ្លាំង វាយទម្លាក់ដេញទៅក្រោម ហ្នឹងមាន។ ដល់យើងគ្រប់គ្រងមក វៀតណាមចូលមក ចុះគេជាមិត្ត។ បងសោម គាត់ចារណសិរ្សជាមួយវៀត-ណាម ថ្នាក់តំបន់។ ដល់ពេលឲ្យគេទៅវិញ និយាយត្រឹមតែពីរថ្ងៃ គេទៅឈ្លូ ស្រួល ឃើញចំណុចល្អ អីចឹង និយាយត្រូវគេទៅ ថាលោកមកជួយខ្ញុំ ឥឡូវប្រទេសខ្ញុំអស់មានរឿងអីហើយ សូមលោកអញ្ជើញទៅប្រទេសលោកវិញចុះ។ ហើយបងប្អូនវៀតណាមដែលមកជាមួយ ជាប្រជាជន ជាអីសូមឲ្យទៅវិញជាមួយគ្នាចុះ! គេទៅ។ ក្នុងហ្នឹងមាន តាម៉ុក គាត់ធ្វើការខាងលើ។ តំបន់ ដោះស្រាយ គេទៅៗ។ ហើយពីមុនមាន អង្គាល់របបលន់នល់ មានមែន។ មែនហ្នឹង មិនបានឃើញមែន គ្រាន់តែឮថា វាយយួនទម្លាក់ទឹក ដេញម៉េចៗហ្នឹង ចេះតែឮ ទាហានអ្នកធ្វើ មិនមែនស៊ីវិលទៅធ្វើអីកើត។ សូមអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនោះ នៅក្នុងអំឡុងពេលឈប់សម្រាប និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១០:១៣នាទី ដល់ម៉ោង១០:៣២ នាទី)*

[១០:៣២:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ក្នុងពេលឈប់សម្រាកខ្ញុំដឹងថា មិនមានការ -- គឺខ្ញុំមានពាក់ព័ន្ធទៅនឹងឯកសារដែលមានកោសលុប ហើយសហព្រះរាជអាជ្ញារងអន្តរជាតិក៏បានលើកឡើងអំពីបញ្ហានេះហើយ ប៉ុន្តែមិនមានអ្វីដែល

អាចរាំងខ្ញុំមិនឲ្យតាំងសំណួរពាក់ -- ទៅនឹងឯកសារនេះទៅកាន់សាក្សីនោះទេ។ ហើយខ្ញុំសូមសួរសំណួរដដែលគឺថា ដើម្បីចង់បានចម្លើយដូចដែលគាត់បានឆ្លើយដូចជូនអ្នកស៊ើបអង្កេត។

**ស៖** លោក ពេជ្រ ជីម ហើយលោកប្រធាន គឺខ្ញុំយោងទៅលើឯកសារ E127/7.1.4 គឺសំណួរចម្លើយលេខ៥៥។ ខ្ញុំសួរសំណួរនេះឡើងវិញ ហើយសង្ឃឹមថាលោកអាចនឹងផ្តល់ដូចគ្នា។ សំណួរសួរថា លោក ពេជ្រ ជីម តើលោកមានស្គាល់អ្នកណាម្នាក់ដែលអាចជម្រាបជូនអង្គជំនុំជម្រះឲ្យបានកាន់តែច្រើនអំពីរចនាសម្ព័ន្ធរបស់តំបន់១៣ ដែរទេ?

**លោក ពេជ្រ ជីម៖**

**ឆ៖** ស្លាប់អស់ហើយ។ នៅលោក មុត គាត់ទទួលតំបន់១៣ ជាមួយលោក សោម។ លោក សោម ស្លាប់។ ជាតិ នៅរស់, លោក មុត នៅរស់ ក្រៅពីហ្នឹងអស់។

**ស៖** តើឈ្មោះ មាស មុត នេះគឺជាឈ្មោះដែលលោកបានប្រាប់ទៅអ្នកស៊ើបអង្កេត។ ខ្ញុំសុំមិនសួរសំណួរនេះទេ។

**លោក ឌេល លីសាក់៖**

សូមបញ្ជាក់ថា អ្វីដែលមិនគួរធ្វើនៅទីនេះ គឺមិនត្រូវភ្ជាប់ព័ត៌មានទៅនឹងអ្វីដែលថាចម្លើយនោះមកពីណានោះទេ។ ខ្ញុំមិនយល់ថានៅក្នុងទម្រង់ណាមួយលោកមិនត្រូវសួរសំណួរបែបនេះនៅក្នុងបរិបទបែបនេះ។

[១០:៣៦:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមអធ្យាស្រ័យលោកសហព្រះរាជអាជ្ញារង លោកត្រឹមត្រូវហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមដកសំណួរចុងក្រោយចេញវិញ។ លោក ពេជ្រ ជីម សំណួររបស់ខ្ញុំគឺ លោកនៅស្គាល់អតីតកម្មាភិបាលណាមកពីភូមិភាគឧត្តរ ឬក៏និរតីដែលនៅរស់រាននៅឡើយ? ហើយរស់នៅឯខេត្តឧត្តរមានជ័យនោះទេ?

**លោក ពេជ្រ ជីម៖**

**ឆ៖** ខ្ញុំជូនទៅអស់ច្រើនហើយ។ ទៅសួរដល់ផ្ទះខ្ញុំ ឲ្យជូនមក ពីរឆ្នាំ បីឆ្នាំហើយ។ អ្នកដែលនៅសល់ប៉ុន្មានហ្នឹង ដែលធ្លាប់ទៅជាមួយខ្ញុំទៅធ្វើការនៅភាគកណ្តាល ខ្លះគេហួសទៅបាត់ទៅ ខ្លះស្លាប់។

ក្រៅពីនោះ មានតែមេទ័ពៗគេនៅធ្វើការក្នុងរបបរាល់ថ្ងៃ អាហ្នឹងនិយាយទៅដល់នោះទៀត វាវែងពេក។ គឺមានមុខងាររាល់ថ្ងៃ។ សូមអស់ហើយ។

[១០:៣៧:៤២]

**ស៖** ខ្ញុំពេញចិត្តនឹងចម្លើយរបស់លោកទេ ប៉ុន្តែតើលោកអាចមានសន្តានចិត្តប្រាប់មកដល់ខ្ញុំ ថាមានអតីតកម្មាភិបាលណាម្នាក់មកពីនិរតី ឬក៏ភូមិភាគឧត្តរនៅរស់រាននៅឡើយ ហើយសព្វថ្ងៃរស់នៅឯខេត្តឧត្តរមានជ័យនោះទេ?

**ឆ៖** ក្រៅពីដែលខ្ញុំជម្រាបប្រាប់អស់ហើយ នឹកមិនឃើញមានទៀត ដែលមាននៅខ្លះៗហ្នឹង ខ្ញុំរាយឈ្មោះជូនហើយអស់ហើយ ប្រាប់អស់ហើយ។

**ស៖** សំណួរផ្សេងទៀត ដែលខ្ញុំត្រូវសួរទៅលោកនោះគឺ សំណួរពាក់ព័ន្ធទៅនឹងការចាប់ខ្លួនឈ្មោះសែ ហៅ កង ចាប។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីការចាប់ខ្លួនឈ្មោះ សែ បាទ គឺឈ្មោះ សែ?

**ឆ៖** ឈ្មោះ សែ ហៅ កង ចាប នេះទៅជាមួយខ្ញុំ។ ទៅដល់ខ្ញុំនៅចម្ការកៅស៊ូ អាន់ នៅជាមួយបងពក ធ្វើតំបន់៤១។ សែ ហៅ ចាប ទៅសៀមរាប ហ្នឹងពីដើមតំបន់ ឧត្តរចាស់។

[១០:៤០:០២]

**ស៖** លោកដឹងទេ ហេតុអីជាបានជា សែ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** មិនដឹង។ ទៅសៀមរាបបានប្រហែលប៉ុន្មានខែទេ មិនចាំទៀត ខ្ទង់បីបួនខែ គេចាប់។ ចាប់បងពក ប្រាប់ខ្ញុំ “សែ គេចាប់ហើយ” “ចាប់រឿងអីអ្នះ?” “ខាងលើ” និយាយតែប៉ុណ្ណឹង។ ដល់ឮហើយយើងស្ងៀម។ នេះ រឿងគេ គេធ្វើ។ ឯងខំធ្វើការ ប្រមូលជ័រឲ្យបានច្រើន។ ប្រមូលកម្លាំង រឿងជ័រ រៀបចំធ្វើការ។ សួរគាត់ប៉ុណ្ណឹង ថាៗខាងលើ។ ខាងលើដកហើយ។ សុំអស់។

**ស៖** តើមានពេលណាមួយ ក្រោយមកដែលលោកដឹងថា សែ ឆ្លើយទម្លាក់មកលើលោក ហើយនិងបងប្រុសរបស់លោកថា ជាខ្សែរបស់គាត់នុ៎ងដែរទេ?

**ឆ៖** មិនបានដឹងទេ។ ទើបឮថ្ងៃនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ តើលោកអាចប្រាប់បានទេថា លោកទទួលព័ត៌មាននេះមកពីណា? ប្រសិនបើជាចម្លើយសារភាពមកពីស-២១ នោះ សូមលោកបញ្ជាក់។

[១០:៤២:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថា ខ្ញុំគ្រាន់សួរគាត់ជាទូទៅទេ ខ្ញុំមិនដឹងថាវាជាចម្លើយបានមកពីចម្លើយសារភាព ឬក៏យ៉ាងណានោះទេ។ ខ្ញុំសួរសំណួរទូទៅទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សុំទោស គឺខ្ញុំជាអ្នកសួរទៅលោក ថាលោកទទួលបានព័ត៌មានហ្នឹងមកពីណា បានប្រភពមកពីណា សូមលោកបញ្ជាក់មើល៍?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានព័ត៌មានមកពីសំណុំរឿង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមកុំឲ្យសើចចំអកចំពោះយើង។ លោកមានព័ត៌មានយ៉ាងណា ដែលធ្វើឲ្យលោកអះអាងបែបហ្នឹងនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានអះអាងថា ព័ត៌មានហ្នឹងមកពីណាទេ ខ្ញុំគ្រាន់តែសួរថាតើគាត់ដឹងដែរឬក៏អត់ថា សែមានឆ្លើយដាក់គាត់ថា គាត់ជាខ្សែរបស់ សែ ហ្នឹងដែរឬអត់តែប៉ុណ្ណោះ។ ខ្ញុំ គឺថាមានសិទ្ធិអាចសួរបែបនេះបាន លោកចៅក្រម។

[១០:៤៣:១៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ជាមេធាវី គឺថាសួរថា លោកបានមូលដ្ឋាននេះមកពីណា?

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែ ខ្ញុំក៏មានសិទ្ធិមិនឆ្លើយទៅនឹងសំណួររបស់ចៅក្រមនេះវិញដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:៤៣:៤៣]

**លោក ខេល លីសាក់៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំអាចឆ្លើយទៅនឹងសំណួរនេះបាន។ គាត់យោងទៅចម្លើយសារភាពពីមន្ទីរស-២១ របស់ កង ចាប គឺឯកសារ E3/2792 មានបញ្ជីអ្នកទោសមានឈ្មោះ -- បញ្ជីវែងមួយទៀត មានមនុស្សដល់រាប់រយនាក់។ ហើយក្នុងបញ្ជីនេះ គឺអ្នកទោសដែលមានលេខរៀង៤៧។

ខ្ញុំសូមបញ្ជាក់ថា ពីខាងដើម មេធាវីក៏មានបំណងតាំងសំណួរនេះមកកាន់សាក្សី គឺចេញមកពីចម្លើយសារភាពនៅស-២១។ បើគាត់សួរថា តើ ជូ ជេត ឬក៏ កង ចាប មាននិយាយថា សោម ត្រូវបានចាប់ខ្លួន ឬក៏យ៉ាងណានោះ ការតាំងសំណួរនៅចំពោះមុខអង្គជំនុំជម្រះ ដោយយកព័ត៌មានដែលជឿជាក់ថា អាចបានមកពីចម្លើយសាក្សី គឺថាមិនជាការសមស្របនោះទេ។ ប៉ុន្តែបើៗសួរថា ទាក់ទងទៅនឹងសំណួរដែលគាត់សួរនេះ ខ្ញុំគិតថាវាមានសំណួរមួយសមស្របទៅតាមផ្លូវច្បាប់ ហើយដោយសារថាមានមនុស្សរាប់រយនាក់ត្រូវបានគេចាត់ទុកថាពួកក្បត់ ហើយត្រូវបានគេវាយដំសួរចម្លើយ។ អ្វីដែលយើងចង់ដឹងនោះ គឺថាតើព័ត៌មាននេះ វាមាន កែ ពក មានអីឆ្លើយ ឬក៏យ៉ាងណានោះទេ។ ហើយតើថាចម្លើយសារភាពនេះ ក្រោយមកត្រូវបានគេប្រើប្រាស់ដើម្បីឆ្លើយដាក់ទៅអ្នកណានៅក្នុងរបបនោះហ្នឹងទើបជាការសមស្រប។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ជំហររបស់យើងតែប៉ុណ្ណោះ។ បើសិនណាជាមេធាវីចង់យកចម្លើយសារភាពពីស-២១ យើងត្រូវបាន -- ត្រូវតែមានការអនុញ្ញាតដើម្បីសាកសួរយកចម្លើយសារភាពពី ស-២១ ដើម្បីយកមកតាំងសំណួរបាន។

[១០:៤៦:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ខ្ញុំសូមឲ្យមានការសម្រេចមួយឲ្យបានច្បាស់លាស់ពីអង្គជំនុំជម្រះ ខ្ញុំមិនយោងទៅឯកសារណាមួយនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថាតើសាក្សីរូបនេះ អ្នកណាម្នាក់ឆ្លើយទម្លាក់មកលើគាត់ដែរឬក៏អត់? នេះជាសំណួរទូទៅ ដែលខ្ញុំបានរៀបចំឡើង ហើយការរៀបចំសំណួបែបនេះ គឺថាគួរតែត្រូវបានអនុញ្ញាត។ ខ្ញុំចង់បានសម្រេចមួយប្រកបទៅដោយសំអាងហេតុ មានហេតុផលត្រឹមត្រូវ នៅពេលដែលយើងប្រឈមមុខទៅនឹងបញ្ហាបែបនេះ។ ជៀសវាងកុំឲ្យមានបញ្ហាបែបនេះទៀតនៅពេលរសៀលនេះ និងនៅពេលខាងមុខផង។ ដូចដែលសហព្រះរាជអាជ្ញាក៏បានដឹងដែរ គឺយើងមានចំណុចដែលត្រូវធ្វើការប្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ហើយដែលត្រូវអង្គជំនុំជម្រះត្រូវយកទៅ

-- សាលាកំពូលយកទៅពិចារណាសម្រេច ថាតើត្រូវអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយណាមួយចេញពី ស-២១ បានដែរឬក៏អត់? មិនមែនយកមកប្រើប្រាស់មកប្រឆាំងទៅនឹងជនជាប់ចោទទេ ក៏ប៉ុន្តែគ្រាន់តែជាមូលដ្ឋានសម្រាប់ការតាំងសំណួរ។ ហើយខ្ញុំជឿជាក់ថាតុលាការកំពូលនឹងពិភាក្សាសម្រេចឆាប់ៗនេះ។ ដូច្នេះ សម្រាប់សំណុំរឿង០២/០២ គឺថាខ្ញុំស្នើសុំឲ្យមានសេចក្ដីសម្រេចពីអង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហានេះ។

[១០:៤៧:៥៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកចង់ប្រើប្រាស់ចម្លើយសារភាពដែលឆ្លើយពាក់ព័ន្ធទៅអ្នកណាម្នាក់ ឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើអត់ទេ ដើម្បីបញ្ជាក់ហ្នឹង គឺខ្ញុំសូមឲ្យលោកដាក់សំណើជាលាយលក្ខណ៍អក្សរមក ដើម្បីឲ្យយើងធ្វើការឆ្លើយបញ្ជាក់ទៅនឹងសំណើរបស់លោក។ ភស្តុតាងប្រឡាក់ប្រឡូកនេះ គឺថាមានការហាមឃាត់មិនឲ្យប្រើប្រាស់បែបនេះ ហើយយើងទាំងអស់គ្នាក៏យល់ស្របថាបើ -- ដូចដែលខ្ញុំបាននិយាយ គឺថាលោកដាក់សំណើជាលាយលក្ខណ៍អក្សរមក តើលោកចង់ឲ្យអង្គជំនុំជម្រះបញ្ជាក់ចំណុចណាពីព្រោះវាទូលំទូលាយពេក។ កាលលោកមិនដឹងដោយចំណុចណាដោយច្បាស់លាស់ ហើយសម្រេច ផ្ទាល់មាត់ គឺវាទូលំទូលាយណាស់។

[១០:៤៨:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

អង្គជំនុំជម្រះបានជ្រាបច្បាស់ហើយ ពេលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ភស្តុតាងដែលមានការប្រឡាក់ប្រឡូសបែបនេះ។ អ្វីដែលខ្ញុំចង់ដឹងនៅពេលនេះ គឺសុំឲ្យមានសេចក្ដីសម្រេចថ្ងៃនេះតែម្ដង។ ថាតើឲ្យខ្ញុំត្រូវបានអនុញ្ញាតឲ្យសួរសំណួរជាក់លាក់ណាដែរឬក៏អត់។ ដូច្នេះ សំណួររបស់ខ្ញុំនោះ ខ្ញុំបានសួររួចទៅហើយ ហើយខ្ញុំក៏បានស្ដាប់ចម្លើយរួចហើយដែរ។ ប៉ុន្តែខ្ញុំសួរបញ្ជាក់ ថាតើអនុញ្ញាតឲ្យខ្ញុំសួរសំណួរបែបនេះ ឬក៏អត់?

**លោក ខេឌ លីសាក់៖**

ដំបូង ចង់ដឹងសំណួរសិន តើសំណួរយ៉ាងម៉េច? តើសំណួរស្ថិតនៅក្នុងទម្រង់ណាមួយ? ជាសំណួរផ្តល់តម្រុយទៅឲ្យសាក្សី ឬក៏យ៉ាងដូចម្តេច? តើគាត់ជាផ្នែកមួយនៃចម្លើយពាក់ព័ន្ធនេះ ឬក៏អត់ ហ្នឹងខ្ញុំសូមជំទាស់ហើយ។ តើ -- បើសិនណាជាថា លោកត្រូវបានគេឆ្លើយពាក់ព័ន្ធនៅក្នុងចម្លើយសារភាពនៅ ស-២១ អាហ្នឹងវាជាត្រឹមត្រូវ មិនប៉ះពាល់អីទេ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំមិនមែនសួរដោយបង្កប់ន័យបែបនេះទេ ខ្ញុំសួរថា តើគាត់ដឹងថា សែ មានបានឆ្លើយដាក់មកលើគាត់ដែរ ឬអត់។ ខ្ញុំសួរតែប៉ុណ្ណេះឯង។ អ៊ីចឹងហើយបានខ្ញុំសួរថា តើសំណួរបែបនេះអនុញ្ញាតឲ្យខ្ញុំសួរ ឬក៏អត់?

[១០:៥០:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៤:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចដូច្នេះថា បញ្ហានេះទុកឲ្យអង្គជំនុំជម្រះពិចារណា និងសម្រេចនៅក្នុងអំឡុងពេលនៃការសម្រាកអាហារថ្ងៃត្រង់។ ហើយសូមលោកមេធាវី បើមានសំណួរអីបន្ថែមផ្សេងទៀត សូមតាំងសំណួរទៅមុខទៀតចុះ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំមានសំណួរទៅមុខទៀត។ គឺប្រធានបទចុងក្រោយ សំណួរដំបូងពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកនៅក្នុងឯកសារ E319.1.18 សំណួរ-ចម្លើយលេខ២៤៤។ សំណួរដែលសួរទៅលោកគឺដូចតទៅ "តើលោកបានដឹងថា មានអ្វីកើតឡើងចំពោះខ្មែរក្រោមទេនៅពេលដែលពួកគេមកដល់ស្រុកគិរីវង់? ចម្លើយរបស់លោកថា៖ "ខ្ញុំមិនមានការបារម្ភពីខ្មែរក្រោមមកស្រុកគិរីវង់ ព្រោះពួកគេត្រូវឃ្លួនធ្វើបាប ហើយរត់មករស់នៅប្រទេសកម្ពុជាវិញ"។ តើលោកអាចពន្យល់ឲ្យបានល្អិតល្អន់ទៅវិញ -- ពន្យល់ល្អិតល្អន់បន្តិចបានទេថា ម៉េចបានលោកដឹងថាប្រជាជនខ្មែរក្រោមត្រូវបានវៀតណាមធ្វើបាប?

[១០:៥៦:២៨]

**លោក ពេជ្រ ជឹម៖**

**ឆ៖** ដំណឹងតៗ គឺពេលនោះគឺ តាម៉ុក ដើរប្រកាសវៀតណាមធ្វើបាបខ្មែរក្រោម ឥឡូវមកពេញគិរីវង់។ គាត់និយាយប្រាប់អ៊ីចឹង "វ៉ៃៗ" សម្ដីគាត់អ៊ីចឹង វ៉ៃៗ។ អ្នកខ្លះ ម៉ែគាត់ ហ្នឹងចាញ់យួនហើយ បានឡូឡាហ្នឹង ចាញ់យួន! រឿងប៉ុណ្ណឹងបញ្ជាក់ថា អ្នកតាកែវ អ្នកកំពត ព្រៃវែង ស្វាយរៀង នរណាមិនដឹងថា យួន ធ្វើបាបខ្មែរ។ អស់លោកក៏អាចដឹងទេដឹង! ដូចនេះ ស្អប់ ដូនតាយើងមកស្អប់មិនសូវពេញចិត្តប៉ុន្មានទេ ស្អប់ណាស់។ សូមប៉ុណ្ណឹងចុះ។

**ស៖** ហើយតើប្រជាជនខ្មែរក្រោមទាំងអស់ហ្នឹងជាជនរងគ្រោះ ដោយការធ្វើបាបដោយវៀត-ណាមនោះមានបានប្រាប់មកលោក ឬក៏ប្រាប់អ្នកដទៃទៀតថា ហេតុអ្វីបានជាពួកគាត់ត្រូវបានវៀតណាមធ្វើបាបដែរទេ?

**ឆ៖** អត់ទេ ប៉ុន្តែឃើញឡើងមក ហើយមកប្រកាសប្រាប់តៗគ្នា។ ហើយអ្នកដែលជាតិខ្មែរឈាមខ្មែរនៅជាមួយគេជាប់ ២០០ឆ្នាំ ជិត ២០០ឆ្នាំហើយ ហើយគេធ្វើបាបឈឺចាប់ដែរ ហើយខឹងហ្នឹងប៉ុន្តែត្រូវតែធ្វើអី ត្រូវវ៉ៃគេ តប់អីអត់មានទេ។ ធ្វើ -- ថានៅនឹងផ្ទះទេ។ ហើយជឿថារឿងហ្នឹងដោះស្រាយ ភាគសម្រេច តំបន់សម្រេច គឺស្រុកនៅជាប់ហ្នឹង ដោះស្រាយស្បៀងអាហារ សុខទុក្ខអីទាំងអស់ ខាងខ្ញុំនេះអត់ទេ ឆ្ងាយ បើសុំមកជួយជាអង្ករ ជាប្រេង បន្លែ ម្ហូបបាន។ សូមអស់ប៉ុណ្ណឹង។

[១០:៥៩:០៦]

**ស៖** តើខ្មែរក្រោមណាខ្លះក្នុងចំណោមខ្មែរក្រោមទាំងអស់នេះ ដែលមកពីវៀតណាមត្រូវបានគេប្រព្រឹត្តមិនល្អមកលើពួកគាត់ ដោយសារតែពួកគាត់ហ្នឹងជាជនជាតិខ្មែរក្រោម ឬយ៉ាងម៉េច?

**ឆ៖** ត្រង់ហ្នឹងអត់ដឹងទេ នៅឯនោះ ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំសួរឡើងវិញ តើមានគោលនយោបាយណាមួយទាក់ទងទៅនឹងខ្មែរក្រោមដែលទើបតែមកពីវៀតណាម។ ឧទាហរណ៍ថា មានគោលនយោបាយថាត្រូវប្រព្រឹត្តជាមួយអ្នកហ្នឹងយ៉ាងម៉េចដែរ ត្រូវផ្ដល់ចំណីអាហារ ជម្រក ឬក៏យ៉ាងម៉េចដែរ? តើប្រជាជនខ្មែរក្រោមទាំងអស់ហ្នឹង ត្រូវបានគេប្រព្រឹត្តដូចទៅនឹងប្រជាជនខ្មែរដទៃទៀតដែរទេ?

**ឆ៖** តាមគំនិត និងគោលការណ៍ គឺត្រូវតែមាននយោបាយចំពោះខ្មែរក្រោម ដោយកក់ក្ដៅបំផុត ព្រោះអត់ឃ្លាន ឈឺចាប់ គេធ្វើទុក្ខបុកម្នេញ មិនមែនសម្លាប់ ប៉ុនធ្វើទុក្ខបុកម្នេញឲ្យលំបាករត់ចោល

ស្រុក ចោលផ្ទះសម្បែងមកនៅ ជាទស្សនៈ ខ្ញុំរីករាយពេញចិត្តនិងជួយដោះស្រាយ ព្រោះមានការឈឺចាប់ អាក់អន់ចិត្តនឹង--

**សៈ** តើត្រឹមត្រូវដែរទេថា ទាំង អៀង សារី ទាំង សុន សេន ក៏មានប្រភពដើមចេញមកពីវៀតណាមដែរនោះ លោកដឹងថាអ៊ីចឹងដែរទេ? មកពីកម្ពុជាក្រោមដែរទេ លោកដឹងអ៊ីចឹងទេ?

**ផៈ** អត់ដឹងទេ អត់ដឹងប្រវត្តិរូបគាត់ច្បាស់។

[១១:០១:១៩]

**សៈ** ដូច្នេះលោកមិនដឹងទេ ថា សុន សេន ហើយនិង អៀង សារី មានប្រភពដើមចេញពីកម្ពុជាក្រោមនោះទេ។ លោកអត់ដឹងអ៊ីចឹងទេ មែនទេ?

**ផៈ** អត់ទេ អត់បានដឹងច្បាស់ទេ។

**សៈ** ប្រធានបទមួយផ្សេងទៀតគឺ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីការខុសសីលធម៌។ តើពាក្យថា ខុសសីលធម៌ មានន័យថាយ៉ាងដូចម្ដេចដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ផៈ** មានន័យច្រើន ខុសសីលធម៌ ដោយការប្រព្រឹត្តពាក្យសម្ដីមិនសមរម្យទៅចាស់ព្រឹទ្ធាចារ្យហ្នឹងមួយ។ ជេរប្រទេចគេហ្នឹងពីរ។ រវាងបុរសមើលងាយធ្វើបាបនារីភេទហ្នឹងបី។ ហើយនារីភេទ ហ្នឹងក៏ខុសសីលធម៌ទៅមើលប៉ះពាល់គ្រួសារប្ដីសីគេហ្នឹងក៏ដូចគ្នា។ ទាំងអស់ហ្នឹងហៅថា ខុសសីលធម៌។

**សៈ** តើលោកធ្លាប់បានដឹងអំពីហេតុការណ៍ណាមួយនោះ ដែលកម្មាភិបាលហ្នឹងមានការរុកកួនផ្លូវភេទទៅលើស្ត្រីណាម្នាក់ដែរទេ? ហើយប្រសិនណាជាមានតើកម្មាភិបាលនោះត្រូវបានគេដាក់ទណ្ឌកម្មដោយអំពើរបស់ខ្លួនហ្នឹងដែរឬទេ?

[១១:០៣:០៣]

**ផៈ** ក្នុងកម្មាភិបាលគ្រប់គ្រងកន្លងមក ខ្ញុំមិនមានដែលឃើញកម្មាភិបាលរបស់ខាងផ្នែកខ្ញុំគ្រប់គ្រង មានខុសប៉ះសីលធម៌ជាមួយនារីទេ មានម្នាក់ អ្នកនោះតស៊ូមកពីភ្នំ មកដល់អត់មានចាត់តាំងឲ្យចូលស្រុកទេ ដាក់មន្ទីរមួយនៅព្រៃក្លួចឯណោះនឹងខ្មែរក្រហមចាស់។ តាមមើលឲ្យធ្វើស្រុកក៏មិនកើត ធ្វើឃុំក៏មិនកើត ដាក់នៅហ្នឹងទៅ។ ហើយក្រោម -- មិនមែនក្រោមការគ្រប់គ្រងរបស់ខ្ញុំទេ ដោយឡែក។ មិនដឹងទេ ស្រាប់តែឮប្អូនគាត់មកសួរ ថាម៉េច តាមមើល ហ្នឹងអត់មានការងារធ្វើ។ ដល់អ៊ីចឹងបានខ្ញុំភ្ញាក់ដឹងស្មានតែនៅនោះមានការងារធ្វើ។ ដល់តាមដានសួរទៅគាត់មានការប៉ះពាល់ស្ត្រីជាមេម៉ាយរបស់គ្រួសារទាហាន ទៅគេដកគាត់ចេញ។ មិនមែនខ្ញុំធ្វើទេកាលនោះ ខាងលើគេធ្វើ។ មានប៉ុណ្ណឹង

មានមួយនាក់ហ្នឹង។ ឥឡូវ ស្លាប់បាត់អស់ហើយ។

**ស៖** តើលោកដឹងទេថា មានគោលនយោបាយ ឬក៏មានការណែនាំដែលថា កម្មាភិបាលដែលប្រព្រឹត្តខុសសីលធម៌ទៅលើស្ត្រី នឹងត្រូវទទួលរងការដាក់ទារុណកម្ម ពីបទខុសសីលធម៌ហ្នឹង តើមានដែរឬទេ?

**ឆ៖** មានបែបបទកំណត់ ប៉ុន្តែឲ្យកំណត់ពេលវេលា អត់ច្បាស់ អត់មានទេ។ ន័យថា "អប់រំ" ហ្នឹង យកការគ្រប់គ្រងរបស់គេទៅ យកទៅធ្វើនឹងគេទៅ។ ហើយចាត់ចែងប្រើទៅ បង្កបង្កើនផល ដាំគ្រឿង ដាំជី ចិញ្ចឹមជ្រូកអីចឹងទៅ។ ប៉ុន្មានឆ្នាំរួច ប៉ុន្មានខែរួច អត់កំណត់ទេ។ កំណត់រួច មិនរួច ជាក់ស្ដែង តើអ្នកហ្នឹងភ្លឺថ្លាវិញហើយឬនៅ។ កសាងខ្លួន លែងឲ្យខុសអីចឹងទៀតឬនៅ ដឹងថាខ្លួនធ្វើហ្នឹងឬនៅ។ ពេលហ្នឹង គឺរួចហើយ។ សូមអស់។

[១១:០៦:៤១]

**ស៖** តើលោកអាចនិយាយជាទូទៅ អំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយអំពីសិទ្ធិស្ត្រី ឬក៏សិទ្ធិនារីជាទូទៅបានដែរឬទេ? តើលោកអាចធៀបជាមួយនឹងគោលនយោ-បាយមុនរបបកម្ពុជាប្រជាធិបតេយ្យនិងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើមានលក្ខណៈយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំមិនឃើញមានអីប្លែក។ គោលនយោបាយរបស់យើង ជាតិយើង តាំងពីដូនតាមកតែមួយហ្នឹង។ ប្រពៃណី អ្នកណាខុសប្រពៃណី ខុសហើយ។ ស្រីក៏ខុស ប្រុសក៏ខុសដែរ ឪក៏ខុស កូនក៏ខុស។ អ្នកណាល្អ ល្អ។ ហើយពីមុនក៏អីចឹង រាល់ថ្ងៃ ក៏អីចឹង។ សូមឆ្លើយខ្លីប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកម្យ៉ាងទៀត។ តើបុរស ហើយនិងស្ត្រី មានសិទ្ធិស្មើគ្នាដែរឬទេនៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជានៅក្នុងការរស់នៅប្រចាំថ្ងៃ នៅក្នុងស្រុករបស់លោក?

**ឆ៖** និយាយពីសិទ្ធិ សិទ្ធិស្មើគ្នា។ ធ្វើការភូមិ ឃុំ ស្រុក ខេត្ត ដូចគ្នា។ ប្រុសក៏ធ្វើ ស្រីក៏ធ្វើ កន្លងមកនេះ។ មេកងខាងនារី ផ្សេង មេកងខាងបុរស ផ្សេង។ គេចែកដាច់ៗគ្នាផ្នែកអីចឹង បានថាមិនសូវមានរឿងសីលធម៌ទេ ហ្នឹងចំណុចល្អ អត់សូវមានសីលធម៌ទេ។ ចំណុចមិនល្អ គឺត្រង់កម្មាភិបាលយើងនៅក្មេង ទើបនឹងរៀនធ្វើ។ អត់ទាន់ចេះ និងនៅល្ងង់។ ម៉្លោះហើយ ការដឹកនាំធ្វើការមានទំនាស់ចាក់ស្រេះខ្លះ ប៉ះគ្នាទៅវិញទៅមក អត់ទាន់ប្រសប់។ សូមអស់ហើយ។

[១១:០៩:៤៨]

**ស៖** សូមអរគុណ លោក ពេជ្រ ជឹម ។ ឥឡូវនេះ ខ្ញុំបន្តទៅប្រធានបទថ្មីមួយ លោកបានផ្តល់សក្ខីកម្មដោយខ្លី អំពីទំនាស់នៅក្នុងឆ្នាំ៧៥, ៧៦ រវាងបក្សស្រុក និងរណសិរ្សស្រុក។ ហើយខ្ញុំចាំថាមានមួយពេលនោះ តាសោម បានប្រកាសថាមិនមានភាពខុសគ្នាទេ រវាងរណសិរ្ស ហើយនិងបក្ស។ តើលោកអាចប្រាប់បានទេ អំពីលក្ខណៈនៃទំនាស់ ឬក៏លក្ខណៈនៃជម្លោះរវាងបក្ស ហើយនិងរណសិរ្សនោះ?

**ឆ៖** សូមជម្រាបថាមិនមានជាជម្លោះទេ។ កាលនោះ រណសិរ្សជាអ្នកនៅមុខ បក្សអ្នកនៅក្នុងធ្វើការអ៊ីចឹង។ ឯប្រជាជនមើលមក ឃើញថាអ្នកនៅមុខធ្វើ។ អ៊ីចឹងពួករណសិរ្សហ្នឹង អីគឺរណសិរ្សទាំងអស់ហ្នឹង ពួកហ្នឹងទាំងអស់ ហើយជាក់ស្តែងបក្សនៅខាងក្នុងនោះ។ យើងជាដៃជាជើង គេប្រើឱ្យធ្វើអី ធ្វើហ្នឹង។ ក្រោយមានលេង មានពាក្យលេង លេងទៅ វាបន្តុំមែន។ មានម្នាក់ គាត់នៅជាប់ តាគារ។ តាគារ ធ្វើការងារបក្ស, ខុម ធ្វើការងារបក្ស, ខ្ញុំ និងញ៉ៅ ធ្វើការរណសិរ្ស។ គាត់និយាយក្រោយខ្នងវ៉ៃប្រហារថា "អ្ហឺ! វាទៅមិនហួសពីកងឈ្លបទេ រណសិរ្ស។ វាបានត្រឹមរណសិរ្សហ្នឹងឯង"។ ថាហ្នឹងរឿងខឹងរឿងអីផង ប៉ុន្តែខ្ញុំអត់មាត់។ ឈ្មោះ ហួន ស្តាប់បាត់ហើយ។ ខ្ញុំជម្រាប បងសោម "អ្ហឺ! គាត់លើកតែមួយមាត់ថា រណសិរ្សៗរបស់បក្ស" ហើយវែកញែកប៉ុណ្ណឹង។ ថារណសិរ្ស ប៉ុន្តែរណសិរ្សរបស់បក្ស។ ប៉ុណ្ណឹង ក៏ពាក្យហ្នឹងស្ងាត់ទៅហើយទាំងអស់គ្នា។ វាចង់បែកជាទូទៅហើយ អាថាហ្នឹងផ្សេង អ្ហឺ! យើងពួករណសិរ្សទេ។ "អ្ហឺរណសិរ្ស!" ថាអ៊ីចឹង។ ថាអ៊ីចឹងវាទៅថា ពួករណសិរ្សផ្សេង បក្សនោះមិនដែលចេញណា។ អ៊ីចឹង បក្សនៅក្រោយ វាឮ វាខឹង។ ហើយដល់សម្រួលត្រឹមហ្នឹង បាត់វិញទៅ។ សូមអស់ប៉ុណ្ណឹង។

[១១:១៣:១៦]

**ស៖** សូមអរគុណលោក ពេជ្រ ជឹម ហើយខ្ញុំមានចំណុចបន្តទៀតដែលត្រូវសួរលោក។ ទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយនៅក្នុង E3/401, អង់គ្លេសមានលេខ 00381025, មានលេខ 00373475 និងបារាំងមានលេខ 00426214។ គេបង្ហាញជូនលោកនូវឯកសារ ដែលមានហត្ថលេខារបស់អាន់ ហើយនិងនៅខាងលើនៃឯកសារនោះបាននិយាយថា "កម្ទេច"។ ដូច្នេះ ខ្ញុំចង់សួរលោកឱ្យលោកបញ្ជាក់បន្ថែមបន្តិចទៅលើចំណុចនេះ។ លោកបាននិយាយថា បើសិនជាឈ្មោះនៅក្នុងចម្លើយសារភាពត្រូវបានគេគូសខ្វែងដោយប៊ិកក្រហម គឺមានន័យថាបុគ្គលនោះនឹងត្រូវគេបោសសម្អាត។ ដូច្នេះ ខ្ញុំសួរលោកអំពីពាក្យថា "ខ្វែង" នេះ គូសខ្វែងដោយ ហើយនិងពាក្យថា "ប៊ិកក្រហម" ហ្នឹង។ តើគេគូស

ឈ្មោះគ្រប់ពេល ហើយគេប្រើប៊ិកក្រហមរហូត ឬក៏មួយយ៉ាងម៉េចដែរ? សូមលោកផ្ដល់ព័ត៌មានលម្អិតបន្ថែមទៅលើចំណុចនេះ។

[១១:១៥:០៦]

**ផ:** សូមបញ្ជាក់ ការខ្វែងស្រេចតែមេគេសម្រេច។ អាហ្នឹង ខ្ញុំបញ្ជូនម្ដង បញ្ជូនទៅលោក មុត លោកមុត បញ្ជូនទៅ ខុម។ មុត និង ខុម មួយគ្នាប្ដីប្រពន្ធហ្នឹង។ ខុម មិនដឹងបានជូនទៅតំបន់ ឬក៏អត់ទេ។ ហ្នឹង អាន់ វាយការណ៍មក។ ដល់ឃើញមកវិញ អត់ដាក់ស្រោម។ ខ្លះខ្វែង អាខ្លះអត់ – ខ្លះខ្វែង អាខ្លះអត់។ ការខ្វែងហ្នឹងមិនទៀងទេ គឺស្រេចនឹងគេខ្វែងទេ។ ហើយខ្ញុំជូនទៅ ខុម វិញ។ ខុម បញ្ជូនទៅបងសោម។ ខុម ថា "ពូដាក់ស្រោមជាថ្មី ហើយឲ្យនីរសាយកទៅចុះ"។ អាហ្នឹងឯកភាពគ្នា ក៏បញ្ជូនទៅ។ តាមរយ:ហ្នឹង ខ្ញុំឃើញឈ្មោះអត់ខ្វែងប៉ុន្មាននាក់ ឆក់ឱកាស ខ្ញុំទៅជួប បងសោម។ សូមបន្ធូរខ្លះអ្នកដែលឈ្មោះឲ្យទៅទាំងប៉ុន្មានហ្នឹង សូមបន្ធូរ ឲ្យបានរួចខ្លួន បាន១៥នាក់។ គាត់ឲ្យទៅយក។ "ហើយមិត្តឲ្យអង្ករឲ្យអី ហើយមើលពួកហ្នឹងបោសច្រាសសម្អាតកន្លែងអាម៉េច។" បានដឹងត្រឹមហ្នឹង។ ដឹងថាមានក្រាំងតាចាន់ត្រង់ហ្នឹង។ កាលមុនថានៅលើៗ ស្មានតែភ្នំឯណោះ។ អាហ្នឹងជម្រាបត្រង់ហើយ មិនលាក់អីទេ។ ធ្វើការខាងក្រោម កាលណោះ គេមានថ្នាក់ លាក់ការណ៍ៗ គេឲ្យដឹងមួយថ្នាក់។ មួយថ្នាក់ទៀតគេមិនឲ្យដឹង គេឲ្យដឹងត្រឹមនេះ។ ហើយយូរហើយបានគេឲ្យដឹងដល់នោះ បើយើងចង់ដឹងលឿនពេក គេសម្គាល់។ អស់ហើយសូមប៉ុណ្ណឹង។

**ស:** អ៊ីចឹងមានន័យថា វាចាំបាច់ដែលថាគេប្រើប៊ិកក្រហមដើម្បីគូសខ្វែងទៅលើឈ្មោះ។ អ៊ីចឹងបានន័យថា លោកឃើញតែឈ្មោះហ្នឹងគេគូសខ្វែងប៊ិកក្រហម។ អ៊ីចឹងមានន័យថា បុគ្គលដែលមានប៊ិកក្រហមគូសហ្នឹង គឺជាបុគ្គលដែលត្រូវគេបោសសម្អាត អ៊ីចឹងមែនទេ?

[១១:១៧:៤១]

**ផ:** សំណួរហ្នឹងសួរប្រហែល២០ដងហើយ ទៅដល់ផ្ទះ សូមឆ្លើយប៉ុណ្ណឹង។ អ៊ីចឹងសំណូមពរខ្ញុំក៏អត់ចាំច្រើនដែរ ហើយសំណួរខ្ញុំជូនមកពីមុនមកច្រើនហើយ សូមអង្គការ តុលាការយកសំណួរហ្នឹងទៅផ្គុំចុះ ខ្ញុំឆ្លើយបានកម្រិតណា ក្រែងវាខុស វាមិនដូចដើមទៅ នាំបាត់គុណភាព។ ឥឡូវថ្ងៃទី៥ហើយដែលខ្ញុំឆ្លើយ។

**ប្រធានអង្គជំនុំ:**

លោក ពេជ្រ ជឹម លោកមានកាតព្វកិច្ចត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរ។ នេះបញ្ហាទី១

ក្នុងនាមជាសាក្សី។ បញ្ហាទី២ ភស្តុតាងដែលតុលាការនឹងយកពិចារណា ថ្លឹងថ្លែងដើម្បីចេញសាលក្រម គឺភស្តុតាងដាក់ដេញដោលនៅក្នុងសវនាការ។ អ៊ីចឹងហើយបានមានរឿងដែលត្រូវបញ្ជាក់សួរដេញដោលជាផ្លូវការនៅទីនេះ ដើម្បីឱ្យតម្លៃនៃភស្តុតាងនោះអាចតុលាការយកទៅពិចារណា ចេញសាលក្រមតាមផ្លូវច្បាប់បាន។ រឿងអ្វីដែលលោកផ្តល់ព័ត៌មានពីមុន ជាមូលដ្ឋានដែលឱ្យឈានដល់ការពិភាក្សាដេញថ្ងៃនេះ យកលទ្ធផលនៃចម្លើយបញ្ជាក់របស់លោកនេះយកទៅវិភាគពិចារណាជាផ្លូវការ។ ដូច្នេះ មិនអាចលើកពីមុនមក ថាបើមានយកតែឯកសារភស្តុតាងពីមុនមក ធ្វើជាមូលដ្ឋានបាន ទំនងជាអង្គជំនុំជម្រះមិនចាំបាច់បើកសវនាការដើម្បីពិភាក្សាដេញដោលជាសាធារណៈនេះឡើយ។ នេះជាតម្លៃនៃភស្តុតាងដែលអង្គជំនុំជម្រះនឹងយកទៅពិចារណា និងសរសេរចេញសាលក្រម។ សូមលោកយល់ពីបញ្ហានេះ។

[១១:១៩:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំសួរសំណួរនេះទៅលោក ព្រោះថាដោយសារយើងមិនមានឯកសារច្បាប់ដើម ហើយយើងមិនអាចដឹងថា ឯកសារដែលកូពីហ្នឹងវាប៊ិកពណ៌ក្រហម ឬក៏ពណ៌ខៀវ ហើយក៏មិនច្បាស់ថាតើគូសខ្វែងឬក៏យ៉ាងម៉េចដែរ ដូច្នេះហើយទើបខ្ញុំចង់ឱ្យលោកបញ្ជាក់ច្បាស់អំពីការអនុវត្តជាក់ស្តែង។ អ៊ីចឹងខ្ញុំសួរថា តើឈ្មោះហ្នឹងត្រូវតែគូសខ្វែងដោយប៊ិកក្រហមឬអត់នោះ? ហើយខ្ញុំសូមទោសផង ប្រសិនបើខ្ញុំសួរសំណួរទៅលោកនោះ វាច្រំដែល ឬក៏ច្រើនដងនោះ។ សូមអរគុណ។

**លោក ពេជ្រ ជឹម៖**

**ឆ៖** ខ្ញុំរីករាយនឹងឆ្លើយជូន អង្គការ តុលាការ អត់មានអាក់អន់ចិត្តអន់អីទេ។ កម្លាំងមាន មិនមានចេះតែប្រឹងឆ្លើយដោយពេញចិត្ត ចង់បានយុត្តិធម៌ ចង់បានត្រឹមត្រូវ។ សូមអស់។

[១១:២១:០៧]

**ប្រធានអង្គជំនុំ៖**

លោកមិនទាន់ឆ្លើយតបទៅនឹងសំណួរដែលសួរដោយលោក វ៉ិចទ័រ កូប៉េ ទេ។ លោកសាក្សីចូរលោកចងចាំថា កាលបើសំណួរណាច្រំដែល អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាជាសំណួរច្រំដែល មិនឱ្យលោកឆ្លើយតបទេ ឬក៏ភាគីដទៃទៀតមានខាងភាគីសហព្រះរាជអាជ្ញាដែលលោកបានឃើញក្នុងអំឡុងពេលប៉ុន្មានថ្ងៃកន្លងមកនេះ តែងតែលើកតវ៉ាជំទាស់ទៅនឹងភាគីម្ខាងទៀតដោយការតាំងសំណួរច្រំដែល ឬក៏ប្រភេទសំណួរនាំមុខ ឬក៏សំណួរផ្សេងៗទៀតដែលច្បាប់គេហាម។ ដូច្នេះ ប្រសិន

អត់មានការជំទាស់តវ៉ាពីភាគី ឬក៏សម្រេចពីអង្គជំនុំជម្រះទេ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរដែលសួរដោយភាគី ឬក៏អង្គជំនុំជម្រះ។

វិចទ័រ កូប៉េ សូមសួរសំណួរចុងក្រោយសាជាថ្មីម្តងទៀតដើម្បីឲ្យសាក្សីឆ្លើយតបឲ្យចំនឹងសំណួរ។

[១១:២២:១៩]

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំចង់ដឹងថាតើលោកដឹងដែរឬទេថា ឈ្មោះមនុស្សដែលត្រូវគេបោសសម្អាតហ្នឹងគឺចាំបាច់ត្រូវតែគូសខ្វែងដោយប៊ិកក្រហម ឬមួយក៏មិនចាំបាច់ទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ទេ ព្រោះក្នុងហ្នឹងគេដាក់ចម្លើយនៅនឹងអស់ហើយ ៗយើងខាងលើសម្រេចយ៉ាងម៉េចគេដោះស្រាយតាមហ្នឹង នៅខាងមន្ទីរ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត ទៅចំណុចបន្ទាប់របស់ខ្ញុំ។ លោកបានផ្តល់សក្ខីកម្មអំពីជនពិការម្នាក់ដែលឈ្មោះ ភី។ តើលោកធ្លាប់ឮទេថា ភី ត្រូវបានគេសម្លាប់នៅក្នុងឆ្នាំ៧៩ ដោយវៀតណាមនៅភ្នំដំរី។ តើលោកធ្លាប់ឮទេ?

**ឆ៖** ពេលក្រោយវៀតណាមមក អ្នកខ្លះដឹងរឿង អត់ដែលនៅ ព្រោះបែកគ្នារត់ចូលព្រៃដូចតែគ្នា។ ប៉ុន្តែក្រោយយូរមកបានដឹង ភី ស្លាប់ អ្នកនោះស្លាប់ អ្នកណារស់ សួរមួយម៉ាត់ៗហ្នឹង នរណានៅនរណាស្លាប់ អ្នកណាបាត់ អ្នកណាអីខ្លះ ដឹងប៉ុណ្ណឹង។ ភី – ឯឈ្មោះ ភី គឺដឹង ទើបឮក្រោយមកសួរថា "អឺ! ស្លាប់ហើយ"។

[១១:២៤:២៥]

**ស៖** តើគាត់ស្លាប់នៅក្នុងពេលប្រយុទ្ធ ឬក៏គាត់ត្រូវវៀតណាមសម្លាប់?

**ឆ៖** អត់ដឹងទេ ខ្ញុំដឹងត្រឹមសួរគេទៅដឹងតែស្លាប់ៗហើយ បើស្លាប់ហើយអត់ទៅតាមដានសួរទៅទៀតទេ។ ស្លាប់ហើយចប់។

**ស៖** ហើយសំណួរចុងក្រោយរបស់ខ្ញុំផងដែរ គឺជាសំណួរទាក់ទងទៅនឹងស្រុកត្រាំកក់។ គឺខ្ញុំចង់សួរអំពីរចនាសម្ព័ន្ធ ប៉ុន្តែខ្ញុំចាំថា មានម្តងលោកនិយាយថា ត្រាំកក់រួមមានស្រុក -- រួមមានភូមិចំនួន១៤។ តើខ្ញុំចាំអ្វីដែលលោកនិយាយហ្នឹង ត្រឹមត្រូវ ឬក៏អត់ទេ?

**ឆ៖** ឃុំ១៤ មិនមែនភូមិទេ។ ប្រហែលលោកអាចច្រឡំ ពាក្យហ្នឹងច្រើនច្រឡំគ្នា ឃុំ១៤។

ភូមិច្រើន មិនចាំទេ។ ប៉ុន ៥០ ឬជាង ១០០ ភ្លេចហើយ។ ពីដើមចាំឥឡូវភ្លេចអស់ហើយ។

**ស៖** ប្រហែលខ្ញុំនិយាយខុស ហើយខ្ញុំសូមទោសផងលោក ពេជ្រ ជឹម អ្វីដែលខ្ញុំចង់និយាយ គឺខ្ញុំចង់និយាយអំពីឃុំ ដែលលោកនិយាយ។ តើលោកនិយាយថា មួយស្រុកហ្នឹងមានឃុំចំនួន១៤ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបញ្ជាក់អំមិញហើយតើ ស្រុកហ្នឹងមានឃុំ១៤។

**ស៖** ខ្ញុំគិតថា យើងកំពុងតែពិចារណាថាមានឃុំប៉ុន្មាននៅស្រុកត្រាំកក់។ ដូច្នេះ សូមលោកអនុញ្ញាតជួយបន្ថែមឈ្មោះ ឃុំគឺថា យើងមានឃុំគុស សំរោង ត្រពាំងធំត្បូង ត្រពាំងធំជើង ត្រាំកក់ ញ៉ែងញ៉ង ស្រែរនោង តាភេម គឺយើងមានឃុំប្រាំបីហើយ ចុះលោកអាចប្រាប់ឈ្មោះ ប្រាំមួយទៀតដែលនៅសល់ទេ អាចថា ឃុំពពេល។ តើលោកអាចរៀបរាប់ឃុំដែលនៅសល់ទេ?

**ឆ៖** តាភេម ហើយ អង្គតាសោម លាយបូរ, ពពេល, ជាងទង រួមមក ប៉ុន្មានហើយ លោកបូកមើល៍ បើនៅខ្វះរាប់ឲ្យទៀត នៅខ្ពបត្របែក, ខ្ពបរុន, បឹងស្រងែ។ អស់ហើយ។

**លោក វិុចទ័រ កូប៉េ៖**

សូមអរគុណលោក ពេជ្រ ជឹម ដែលបានឆ្លើយនូវសំណួរទាំងអស់របស់ខ្ញុំ។ ខ្ញុំសូមអរគុណ។

[១១:២៨:២៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយខ្ញុំចង់បញ្ជាក់ទៅមេធាវី កូប៉េ។ ខ្ញុំគិតថា ប្រហែលជាយើងអត់មានប្រតិចារឹកនៅពេលសម្រាកទេ។ ដូច្នេះហើយនៅពេលមុនយើងសម្រេចថា -- យើងសន្យាថានឹងផ្តល់សេចក្តីសម្រេចនៅពេលសម្រាក។ ដូច្នេះ ខ្ញុំចង់ឲ្យលោកលើកឡើងវិញនូវសំណួរដែលលោកចង់បានសេចក្តីសម្រេចពីអង្គជំនុំជម្រះ។ គឺថា ដោយសារសំណួរមានការសួរច្រើនហើយ ប៉ុន្តែមួយទៀតគឺ -- តើលោកចង់ឲ្យមានការបញ្ជាក់អំពីភស្តុតាងដែលទទួលបានដោយទារុណកម្ម ឬមួយក៏យ៉ាងម៉េច?

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដទាក់ទងទៅនឹងភស្តុតាងទទួលបានដោយការធ្វើទារុណកម្មនោះឡើយ។ ប៉ុន្តែតាមដែលខ្ញុំចាំ គឺចង់ដឹងថាតើ លោក ពេជ្រ ជឹម គាត់ដឹងអំពីការដែលគេឆ្លើយដាក់ថាគាត់មានបណ្តាញ -- ជាខ្សែបណ្តាញរបស់ សែ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងអាហ្នឹងជាអ្វីដែលលោកចង់ឲ្យយើងសម្រេចឬ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ។

[១១:២៩:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ច ដំណើរការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់អ្នកជំនាញ និង សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សា សាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនៅវេលាម៉ោងមួយ និងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម សាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុនផ្តល់វេទិកាជូនទៅក្រុមសហមេធាវី ការពារក្តីឲ្យលោក ខៀវ សំផន អង្គជំនុំជម្រះ ជម្រាបជូនទៅលោកមេធាវី វ៉ិចទ័រ កូប៉េ ថាសេចក្តី

សម្រេចដោយសំអាងហេតុលើការតាំងសំណួរមួយរបស់លោកមេធាវី ចំពោះសាក្សី ពេជ្រ ជឹម កាលពីព្រឹកមិញនេះ អង្គជំនុំជម្រះទុកបញ្ហានេះមួយអន្លើសិន អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចដោយមានសំអាងហេតុទៅលើបញ្ហានេះនាពេលឆាប់ៗខាងមុខនេះ។ ដោយហេតុអង្គជំនុំជម្រះទុកពេលពិនិត្យប្រតិចារឹកសវនាការ និងឯកសារពាក់ព័ន្ធ ឲ្យបានហ្មត់ចត់ជាមុនសិន។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ពេជ្រ ជឹម ។ សូមអញ្ជើញ!

[១៣:៣៥:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ដោយមានអនុញ្ញាតពីមេធាវី ខៀវ សំផន ខ្ញុំសូមបន្តសួរបន្ថែមបន្តិចទៅលើការពិភាក្សា ទាក់ទងទៅនឹងឯកសារដែលមានការកោសលុប គឺកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីយើងនេះ។ ឥឡូវនេះ យើងមានឯកសារដែលមិនមានការកោសលុបរួចទៅហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមសំណួរបន្ថែមបន្តិចទៅលើសាក្សី ជាពិសេសពាក់ព័ន្ធទៅនឹង គឺឯកសារ E127/7.1.4។ កន្លងមកនេះ ខ្ញុំបានសួរលោកថា៖ “តើលោកស្គាល់អតីតកម្មាភិបាលមកពីភូមិភាគនិរតីឬក៏ភូមិភាគពាយ័ព្យដែលនៅរស់រានមានជីវិត ហើយនៅរស់នៅក្នុងខេត្តឧត្ដរមានជ័យឬក៏អត់?” ហើយលោកឆ្លើយទៅនឹងសំណួរនេះថា៖ “លោកនិយាយយោងទៅលើបុគ្គលពីរនាក់ ហើយខ្ញុំចង់សួរលោកបន្ថែមទាក់ទងទៅនឹងបុគ្គល គឺសំណួរ៤៥ លោកនិយាយយោងទៅលើ បុគ្គលម្នាក់ដែលមានឈ្មោះថា ហ៊ុន។ ឥឡូវនេះ គឺជាឧត្ដមសេនីយ៍ ហើយនិងជាទីប្រឹក្សាសម្ដេចតេជោរដ្ឋមន្ត្រី និងមួយទៀតឈ្មោះ ខៀវ អគ្គ-លេខា ហើយរស់នៅក្បែរផ្សារត្រពាំងប្រាសាទ។ បុគ្គលពីរនាក់នេះ គឺហ៊ុន ហើយនិង ខៀវ តើពួកគាត់ជាកម្មាភិបាលនិរតី ឬក៏កម្មាភិបាលមកពីភូមិភាគពាយ័ព្យ?

[១៣:៣៧:៣៥]

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមបញ្ជាក់ ខ្ញុំអត់ស្គាល់ទេ ហ៊ុន និង ខៀវ ហ្នឹង។

**ស៖** ខ្ញុំមានឯកសាររបស់លោក គឺកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ ហើយលោកបាននិយាយនៅក្នុងនោះថា ខ្ញុំសូមដកស្រង់៖ “បុគ្គលម្នាក់ទៀត គឺឈ្មោះ ហ៊ុន ហើយឥឡូវនេះ គាត់គឺជា

ឧត្តមសេនីយ៍ទោ ហើយជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រី ហើយមួយទៀត គឺ ខៀវ អនុ -- អគ្គនាយករង -- អគ្គនាយក -- អគ្គរង។ ហើយពួកគាត់ទាំងពីរ រស់នៅក្បែរត្រពាំងប្រសាទ។ ដូច្នេះ ខ្ញុំគ្រាន់តែអានកំណត់ហេតុស្តាប់ចម្លើយរបស់លោក ហើយខ្ញុំចង់សួរលោកថាពួកគាត់ជាកម្មាភិបាលមកពីភូមិភាគពាយ័ព្យ ឬក៏និរតី?

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមស្នើដល់មេធាវីការពារក្តី។ ខ្ញុំគិតថាប្រហែលជាគាត់អានឈ្មោះចុងក្រោយខុស។ ហើយខ្ញុំគិតថា ប្រហែលជាជនជាតិខ្មែរ ឬក៏អាចមេធាវីជាតិ ជួយជាតិបាន។

**លោក វ៉ិចទ័រ កូប៉េ៖**

តើលោកអាចជួយខ្ញុំបានទេ លោកមេធាវី?

**លោក គង់ សំអុន៖**

បាទ សូមបញ្ជាក់ឈ្មោះ ទី១ គឺឈ្មោះ ហឿន និងទី២ ឈ្មោះ កែវ បាទ។

**លោក ពេជ្រ ជឹម៖**

**ឆ៖** ហឿន ជាកម្មាភិបាលកងទ័ព។ កែវ ក៏កម្មាភិបាលកងទ័ពដែរ។ រាល់ថ្ងៃនៅខាងត្រពាំងប្រាសាទ។ ហើយធ្វើទ័ពជាប់រហូតមករាល់ថ្ងៃហ្នឹង ថ្នាក់កងពល។ សុទ្ធទីប្រឹក្សាទាំងអស់ហើយពួកនុ៎ង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណដែលបានបញ្ជាក់។ ប៉ុន្តែខ្ញុំចង់ដឹងថា ពួកគាត់ជាកម្មាភិបាលនិរតី ឬក៏កម្មាភិបាលខាងពាយ័ព្យ?

**ឆ៖** មកពីនិរតី ផ្នែកកំពត១ទាំងអស់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

[១៣:៤០:៣០]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ អាទួរ វែកគែន។ ខ្ញុំជាមេធាវីតំណាង -- ការពារឲ្យលោក ខៀវ សំផន។ ខ្ញុំដឹងថាលោកអស់កម្លាំងពីព្រោះថាលោកត្រូវបានគេសួរសំណួរច្រើនមកហើយ។ ខ្ញុំជាអ្នកសួរចុងក្រោយគេ អ៊ីចឹងខ្ញុំព្យាយាមផ្តោតសំណួររបស់ខ្ញុំឲ្យបានត្រឹមត្រូវ ហើយខ្ញុំនឹងមិនសួរ

សំណួរដែលគេសួររួចមកហើយនោះទេ។ ក៏ប៉ុន្តែខ្ញុំប្រហែលជាអាចសួរសំណួរមួយចំនួនដែលគេបានសួរលោកនៅពេលដែលលោកឆ្លើយចំពោះមុខចៅក្រមស៊ើបអង្កេតនៅក្នុងកំណត់ហេតុទាំងប្រាំបី ពីព្រោះថាឥឡូវនេះហើយលោកនៅទីនេះគឺលោកត្រូវតែឆ្លើយអ្វីដែលលោកបានឆ្លើយម្តងរួចមកហើយ។ សំណួរដំបូងរបស់ខ្ញុំពាក់ព័ន្ធទៅនឹងសង្គ្រាមស៊ីវិលក្នុងចន្លោះឆ្នាំ៧០ ទៅដល់ ៧៥។ នៅក្នុងតំបន់របស់លោកនោះ ខ្ញុំចង់ដឹងថាតើលោកអាចរៀបរាប់អំពីការប្រយុទ្ធគ្នា អំពីការទម្លាក់គ្រាប់បែក អំពីហេតុការណ៍សង្គ្រាមដែលកើតឡើងនៅក្នុងស្រុកត្រាំកក់នៅចន្លោះឆ្នាំ១៩៧០ ទៅដល់ឆ្នាំ១៩៧៥។ ខ្ញុំចង់ដឹងថា បើតាមការយល់ឃើញរបស់លោកតើមានការប្រយុទ្ធគ្នាខ្លាំងក្លាទេ ហើយមានជនរងគ្រោះច្រើនទេ?

[១៣:៤២:១៦]

**លោក ពេជ្រ ជឹម៖**

**ឆ៖** ការប្រយុទ្ធសង្គ្រាម ភ្លេចហើយសង្គ្រាមអី? គឺមានសភាពខ្លាំងក្លា តទល់គ្នារវាងខាងកងទ័ពលន់នល់ កងទ័ពខ្មែរយើងតែមួយហ្នឹង គ្រាន់ថានោះលន់នល់ ខាងនេះខ្មែរក្រហម ជល់គ្នាទៅ។ គឺប្រយុទ្ធខ្លាំងក្លា បានប៉ុន្មានខែខ្ញុំមិនចាំទេ។ ប្រយុទ្ធហ្នឹងកម្រិតឡើងដល់កប៉ាល់ហោះ ២០០យប់ ២០០ថ្ងៃ ទាំងយប់ ទាំងថ្ងៃដេកក្នុងត្រង់សេ ជម្រាបជូន។ ខ្ញុំញាក់សាច់ហើយ (ឮមិនច្បាស់) ណារកត្រង់សេចូលដេក ព្រឹកឡើងបានចេញទៀត។ បើយប់លេងរូមកទាំងខ្សែៗ ទម្លាក់ចុងភ្នំដំរីរមៀល ខាងលិចស្រុកហ្នឹង រូមកចេញបាត់មក ងើបទៅវិញទៅ មកពីរទៀត ពីត្បូងម្តង ពីជើងម្តង ពីកើតម្តង ពីលិចម្តង ហើយប្រជាជនទាំងអស់គឺនៅក្នុងដំបូក។ មានការលំបាកភ័យខ្លាច ដាំភ្លើងហូបបាយអត់ទេ ហើយចាន ផើងមួយបក់ផ្សែង ឬក្រមាបក់ផ្សែង នេះបើដុតភ្លើងដាំ ហើយតែឃើញផ្សែងហ្នឹងកប៉ាល់ហោះទម្លាក់។ ដល់លំបាកអ៊ីចឹងគិតៗច្រើន គិតមិនដឹងទៅជាស្អី អ៊ីចឹងទាល់តែទប់ទល់បានឈ្នះ ចេះតែធ្វើ ធ្វើផងលំបាកផង ឆ្លងកាត់ផង។ អ៊ីចឹងដែលរឿងវាកើតច្រើន។ កម្លាំងប្រជាជននៅកងនៅលើខាងមុខមកហ្នឹង កងបុរសហ្នឹងដឹកបាយ តាៗដែល ចាស់ៗធ្វើជាលដាក់បាយដឹកជូនសមរភូមិនៅខាងមុខ។ សូមលើកខ្លីៗ ហើយខ្លះនិយាយថា បានការអីធ្វើជាលហ្នឹង ធ្វើកន្ត្រកហ្នឹង បានការអី។ ដល់មីទ្និង ខ្ញុំពន្យល់។ បើមិនបានគិតអ៊ីចឹង អាខ្លះចាប់វ៉ៃទៅ។ បានការអីធ្វើជាលដឹកទៅ បានការអីជាល។ ជាលហ្នឹងដឹកបាយឲ្យកងទ័ពនៅសមរភូមិ ដល់ដឹងអ៊ីចឹងហើយបានស្ងាត់។ សូមអស់ហើយ ប៉ុណ្ណឹង។

[១៣:៤៥:២៦]

**ស៖** លោក ពេជ្រ ជឹម--

**ឆ៖** សំណួរហ្នឹងវែងពេក ខ្ញុំឆ្លើយវែងបន្តិចទៅ អត់អស់ទេ។ មានការលំបាក ឆ្លើយមួយមាត់ប៉ុណ្ណឹង។

**ស៖** លោកនិយាយត្រូវហើយសំណួរខ្ញុំវែង ក៏ប៉ុន្តែខ្ញុំសួរហ្នឹង ពាក់ព័ន្ធទៅនឹងការប្រយុទ្ធគ្នា និងភាពហិង្សានៃការប្រយុទ្ធគ្នា។ អ៊ីចឹង ខ្ញុំចង់ដឹងថាលោកធ្លាប់ឮ ឬក៏បានសង្កេតឃើញអំពីការវាយប្រយុទ្ធគ្នានៅជុំវិញអង្គតាសោមទេ លោកដឹងអំពីការប្រយុទ្ធគ្នាហ្នឹងទេ? តើមានការប្រយុទ្ធគ្នាសាហាវឃោរឃៅ ឬក៏ខ្លាំងក្លានៅតំបន់អង្គតាសោមទេ?

**ឆ៖** ការប្រយុទ្ធគ្នាខ្លាំងក្លានៅតំបន់អង្គតាសោម។ តាកែវល្មមទេ។ វាត្រង់ហ្នឹងវាបូកមុខប្អូនប្រជុំគ្នា ហើយយូរៗដាច់តាកែវ-អង្គតាសោមម៉ាត់ទៅ ទៅនៅតែតាកែវ បានអង្គតាសោមវាធូរវិញ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរលោកថា ដឹងតាមរបៀបណាមួយថានៅចន្លោះឆ្នាំ៧០ និងឆ្នាំង៧៥ ទាហានវៀតណាមខាងជើងមានវត្តមាននៅកម្ពុជានោះ បានប្រើភូមិខ្មែរហ្នឹងសម្រាប់ជាខែលពាំងពីការទម្លាក់គ្រាប់បែកពីអាមេរិកនោះ ហើយនិងសម្ព័ន្ធមិត្ត។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើវៀតណាមខាងជើងនោះ គាត់មានបានធ្វើអ៊ីចឹងទេ គឺថាគាត់យកភូមិខ្មែរមកធ្វើជាខែលសម្រាប់ពាំងខ្លួនពីការទម្លាក់គ្រាប់បែក?

**ឆ៖** មិនមាននៅក្នុងភូមិទេ។ មានតែចេញចូលសុំទិញម្ហូបបន្លែ មាន នៅព្រៃ។ នៅក៏កាលនោះអង្គការមិនឲ្យនៅដែរ។ នៅតាមព្រៃ។

[១៣:៤៨:០៩]

**ស៖** សូមអរគុណ។ នៅអំឡុងឆ្នាំ៧០ ដល់ឆ្នាំ៧៥ដដែល តើលោកដឹងទេ ថាទាហានលន់ នល់ ឬទាហានវៀតណាមខាងត្បូងដែលជាសម្ព័ន្ធមិត្តនោះ តើមានធ្វើការគំរាមកំហែង ឬក៏អីពាក់ព័ន្ធទៅនឹងវៀតណាមខាងជើងដែលរស់នៅក្នុងស្រុករបស់លោកទេ?

**ឆ៖** វៀតណាមខាងជើងដែលមកនៅ អត់មានគំរាមកំហែងអីទេ ព្រោះគេមកៗ គេមកប្រាប់ត្រឹមត្រូវ ទាក់ទងត្រឹមត្រូវ ហើយបើទៅគំរាមកំហែងម៉េច បើអាវុធ បើយើងយកអាវុធទៅដែរ វាដោះស្រាយលែងត្រឹមត្រូវហើយ ឆេះទៅទៀត ឆេះក្នុងខាងតំបន់រំដោះជាមួយគ្នាទៀត។ អ៊ីចឹងអត់មានទេ។

**ស៖** លោក ពេជ្រ ជឹម ខ្ញុំមិននិយាយអំពីវៀតណាមខាងជើងទេ ពេលនេះខ្ញុំនិយាយអំពីវៀត-ណាមខាងត្បូងម្តង។ ខ្ញុំចង់ដឹងថាតើពួកវៀតណាមខាងត្បូងនេះ មានបានប្រព្រឹត្តអំពើហិង្សា ឬក៏មាន

ការធ្វើបាបអីទៅលើពួកទាហានវៀតណាមខាងជើងនៅក្នុងស្រុករបស់លោកទេ? ឬមួយក៏ទាហានរបស់លន់ នល់នោះ?

[១៣:៥០:០៥]

**ឆះ** មានដោយឡែក ជាវៀតណាមនៅវៀតណាម ដូចវាមិនឃើញ បើថាជាមួយគ្នា លន់ នល់ វៀតណាមជាមួយគ្នាហ្នឹង។ ហើយជាមួយនឹងវៀតណាមខាងនេះហ្នឹង វ៉ៃគ្នា មាន ប្រយុទ្ធនៅស្ពានគូ នៅអង្គតាសោម នៅជុំវិញអង្គតាសោម ពិសេសកងឈ្លបក្តាប់ជាប់ជុំវិញហ្នឹង។ ឈ្លបបួនដប់ភូមិ ឈ្លបត្រាំកក់បួនដប់ភូមិ មានបួនដប់កង។ មួយកងតូច វរសេនាតូចហ្នឹង ខាងឈ្លប ជុំបួនដប់ហើយ។ ហ្នឹងសូមបញ្ជាក់ជូនខ្លីៗប៉ុណ្ណឹង។ ឯវៀតណាមខាងត្បូង រូបភាពគេនៅជាមួយ – នៅជាមួយលន់ នល់។ បន្ទាយដោយខ្លួន តែចេញសកម្មភាពប្រយុទ្ធគឺជាមួយគ្នា។ គេមកជាមួយគ្នាមានទ្រង់ទ្រាយធំ បើគេមិនមកទេ ទាហានខ្មែរខ្លួនឯងមកគ្នាតិច មានទ្រង់ទ្រាយតូច ចេញលួមៗ។ ចេញលួមគឺចេញពីទីក្រុងណា ចេញពីទីតាំង។ សូមអស់។

**សះ** ខ្ញុំនឹងព្យាយាមបញ្ជាក់សំណួរខ្ញុំឡើងវិញ ដើម្បីឲ្យលោកឆ្លើយឲ្យបានត្រូវ។ អ្វីដែលខ្ញុំចង់ដឹងនោះថា តើលោកមានព័ត៌មានពាក់ព័ន្ធទៅនឹងការធ្វើបាប ការប្រើអំពើហិង្សា ការសម្លាប់រង្គាលរបស់ទាហានលន់ នល់ ឬក៏សម្ព័ន្ធមិត្ត ដែលជាវៀតណាមខាងត្បូងប្រឆាំងទៅលើប្រជាជនស៊ីវិល ដែល -- នៃវៀតណាមខាងជើង ដែលរស់នៅក្នុងស្រុករបស់លោកនោះ។ ចង់ដឹងថា តើលោកដឹងទេថាមានទាហានលន់ នល់ ឬក៏ទាហានវៀតណាមខងត្បូងនោះ គាត់មានបានធ្វើបាប ឬក៏សម្លាប់ជនស៊ីវិលដែលនៅវៀតណាមខាងជើងនៅក្នុងស្រុករបស់លោកទេ បើលោកដឹង លោកឆ្លើយថាដឹង បើមិនដឹងថាមិនដឹងទៅ?

[១៣:៥២:៥៨]

**ឆះ** អត់ដឹងទេ។ ខ្ញុំអំមិញស្តាប់ត្រង់ហ្នឹងអត់យល់ រកវាវឆ្លើយអត់ចូល អត់ចំ សួរច្បិចខ្លីចុចចំតែម្តង បានឆ្លើយរួច ដល់វាងយូរពេក ខ្ញុំស្តាប់អត់ទាន់។ កម្លាំងខ្សោយ បញ្ញាក៏ថយ វាមិនដូចមុនទេ។

**សះ** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកអំពីសំណួរដែលគេបានសួរលោកកាលពីម្សិលម៉្ងៃ គឺកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ នៅពេលនោះគឺលោក លីសាក់ ជាសហព្រះរាជអាជ្ញារងបានសួរលោកគឺនៅម៉ោង ១០:៣៣:១៣វិនាទី សហព្រះរាជអាជ្ញារងបានសួរលោកដូចតទៅ។ ខ្ញុំនឹងអាចសំណួររបស់គាត់។ លោកសាក្សី ខ្ញុំចង់សួរអំពីជនជាតិវៀតណាមដែលនៅស្រុកត្រាំកក់។ ខ្ញុំចង់

ដឹងអំពីអ្វីដែលបានកើតឡើងចំពោះជនជាតិវៀតណាមនៅក្នុងស្រុកនេះ និងនៅក្នុងខេត្តតាកែវក្រោយថ្ងៃ ១៧ មេសា ឆ្នាំ៧៥។ ពាក្យថា ១៧ មេសា ៧៥ គឺខ្ញុំគូសបន្ទាត់ -- ខ្ញុំសង្កត់ធ្ងន់ ហើយលោកឆ្លើយនៅពេលនោះថា "នៅសម័យនោះ ទាហានវៀតណាមមានវត្តមាននៅគ្រប់ទីកន្លែងនៅស្រុកត្រាំកក់ មិនមែនតែជនស៊ីវិលទេ ទាហានក៏នៅក្នុងហ្នឹងដែរ គឺហើយនៅក្នុងព្រៃក៏មានដែរ។ វៀតណាមដោះដូរទំនិញជាមួយនឹងខ្មែរ។ ហើយគឺថាមុននឹងយើងធ្វើការដោះដូរអីនោះ គឺថាយើងត្រូវតែមានការអនុញ្ញាតសិននៅពេលដែលគេមកទិញស្រូវពីយើងនោះ គឺយើងលក់ដុំ។ នៅសម័យនេះគឺបក្សបានសម្រប សម្រួលជាមួយវៀតណាម ដើម្បីបញ្ជូនជនជាតិវៀតណាមទៅកាន់ប្រទេសវៀតណាមវិញ។ បន្ទាប់មកទៀតជនជាតិវៀតណាមក៏មាតុភូមិនិវត្តន៍ទៅវៀតណាមវិញ។ ខ្ញុំនិយាយអំពីទាហានវៀតណាម។ មាតុភូមិនិវត្តន៍ហ្នឹងគឺធ្វើឡើងតែពីរថ្ងៃទេ។ កាលពេលនោះ គឺថាក៏មានការបញ្ជូនទាំងស៊ីវិល ក៏ដូចជាទាហានវៀតណាមផងដែរ ទៅកាន់វៀតណាមវិញនោះ"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកដូចតទៅសហព្រះរាជអាជ្ញាបានសួរសំណួរលោកពាក់ព័ន្ធទៅនឹងរយៈកាលមុន ក្រោយថ្ងៃទី១៧ មេសា ៧៥។ អ៊ីចឹងនៅពេលដែលស្តាប់ឮសំណួរចម្លើយនេះម្តងទៀតនោះ តើលោកអាចបញ្ជាក់បានទេថាចម្លើយរបស់លោកហ្នឹង គឺលោកសំដៅទៅលើៗ រយៈកាលក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥?

**ឆ៖** សូមបញ្ជាក់ ខ្ញុំនិយាយវាព័ន្ធខ្លះដែរ។ ពេលសភាពគេដក វៀតណាមដកហ្នឹង ៧២ គឺមុនរំដោះ មិនមែនក្រោយ៧៥ទេ ដែលវៀតណាមដក យើងកាលនោះអង្គការឲ្យទាក់ទងឲ្យវៀតណាមដកចេញទៅវិញនោះ គឺក្នុង៧២ ឆ្នាំ៧២ មិនចាំខែទេ។

[១៣:៥៧:១១]

**ស៖** សូមអរគុណ លោក ពេជ្រ ជឹម ដែលបានឆ្លើយបញ្ជាក់។ ឥឡូវនេះ ខ្ញុំប្តូរប្រធានបទ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោក។ ពាក់ព័ន្ធទៅនឹងសាច់ញាតិ ខ្ញុំចង់ដឹងថា តើ តាទិត្យ និង តាមុត ហ្នឹងមានជាប់សាច់ញាតិនឹងគ្នាទេ?

**ឆ៖** បងថ្លៃ និងប្អូនថ្លៃ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ដឹងថា លោកស្គាល់ឈ្មោះ ស៊ីម ដែលជាអនុលេខាស្រុកទ្រាំង ប្រសិនបើលោកស្គាល់នោះ តើ ស៊ីម ហ្នឹងមានប្រពន្ធឈ្មោះ សែម ទេ?

**ឆ៖** ស៊ីម ហ្នឹងប្រពន្ធឈ្មោះ សេម។ ស៊ីម ហ្នឹងស្លាប់ហើយ ស្លាប់នៅជំរំភ្នូណយ។ ស៊ីម ហ្នឹងបាត់មិនដែលឃើញ មិនដឹងទៅឯណា។ សួរក៏អត់លេចដែរ។ សូមអស់។

**សៈ** សូមអរគុណលោក ពេជ្រ ជឹម។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ សាក្សី រៀល សន ដែលជាអតីតប្រធានមន្ទីរពេទ្យបានមកផ្ដល់សក្ខីកម្មនៅទីនេះ ឯកសារ E1/268.1 សុំទោស 278.1 គាត់បាននិយាយអត្តចរិតរបស់យាយ ខុម ដែលជាកូនរបស់ តាម៉ុក។ គាត់ជាប្រធានស្រុកត្រាំកក់។ នេះជាចម្លើយរបស់គាត់នៅពេលនោះ។ គេសួរគាត់ថា "តើលោកអាចរៀបរាប់អំពីយាយ ខុម ដែលជាប្រធានស្រុកទេ? ហើយមានរឿងអ្វីកើតឡើងចំពោះគាត់? ចម្លើយ៖ យាយ ខុម ជាលេខាស្រុក ក៏ប៉ុន្តែក្រោយមកគាត់ឆ្កួត។ គាត់មិនអាចនិយាយពាក្យអីបានទេ។ នៅពេលដែលខ្ញុំជួបគាត់នុ៎ង គាត់ឲ្យ ទៅឲ្យទៅជីកដី ទៅជីករកដីយកឫសឈើ ទៅកាប់ឈើ ខ្ញុំគិតថា ប្រហែលជាគាត់ឆ្កួត"។ សូមបញ្ចប់ការដកស្រង់។

កាលពីព្រឹកមិញនេះ លោកខ្លួនឯងផ្ទាល់ នៅពេលដែលគេសួរលោកអំពីកូន តាម៉ុក នេះលោកក៏និយាយអំពីថាគាត់ហ្នឹងឆ្កួតដែរ មិនសូវគ្រប់ទឹក។ ដូច្នេះ ខ្ញុំចង់ដឹងថាតើ -- ព្រោះថាលោកជាអនុរបស់ខុម។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើគាត់មានបញ្ហាខួរក្បាល បញ្ហាផ្លូវចិត្តទេ ពេលដែលគាត់ចាកចេញពីមុខតំណែងគាត់នៅស្រុកនោះ? លោកមានកត់សម្គាល់ឃើញថា គាត់មានបញ្ហាអ៊ីចឹងទេ?

[១៤:០១:០៥]

**ឆៈ** កាលនោះ គិតគ្នា រកវិធីមើល រកពេទ្យ។ ពេទ្យកង អ្នកមើល។ យកពេទ្យវៀតណាមទៀត។ ហើយវិភាគទាំងអស់គ្នា ថាឈឺ គឺសសៃប្រសាទ បញ្ជាក់អ៊ីចឹង។ ហើយមិនមែនថា គាត់ឆ្កួតវិកលចរិត មិនគ្រប់ទឹកអ៊ីចឹង មិនមែនទេ មិនដល់ថាហ្នឹងទេ។ គាត់ប៉ះពាល់សសៃប្រសាទ។ ជម្រាបប៉ុណ្ណឹង។ ប៉ុន្តែគាត់ចិត្តឆៅណាស់ ម៉ាត់ណា ម៉ាត់នុ៎ងហើយ។ ធ្លាប់ឈឺអ៊ីចឹងម្ដង។ ដល់ឈឺអ៊ីចឹង ខ្ញុំបានដឹងប្រវត្តិគាត់។ ឈឺម្ដង កាលឈឺលើកមុន ទៅមើលជាស្រុកវៀតណាម។ អ៊ីចឹង បានយកវៀតណាមមកមើលនៅកន្លែងហ្នឹង ភូមិត្រពាំងថ្មហ្នឹង។ ហើយយកមក ក៏អត់ជាអត់អី។ គ្រូខ្លះថាទាស់ ការឲ្យតាមុត អត់មានខាន់ស្លា។ អ៊ីចឹង ខ្ញុំយកផ្កាស្លា យកអីមកដាក់រៀបចំ និយាយដូនតា រៀបសំពះឡើងវិញក៏វាមិនជា។ រកគ្រូប ខ្ញុំអ្នករត់រក។ រត់រកតែពេលដេកពួនគ្មាន ក៏មានដែរ។ ត្រូវមក ខុម ដេររ៉ាវ--

**សៈ** លោក ពេជ្រ ជឹម ខ្ញុំសូមកាត់ចម្លើយលោក។ ខ្ញុំចង់ដឹងថាតើគាត់នៅតែបន្តធ្វើការរហូតទៅដល់លោកថារកគ្រូពេទ្យវៀតណាមនោះ អ៊ីចឹងគាត់នៅតែធ្វើការដដែល ឬក៏អត់?

**ឆៈ** វៀតណាមមើល នៅធ្វើៗ។ សូមបញ្ជាក់ ជំងឺមើលវាជាបានមួយខែពីរ កន្លះខែ ខំធ្វើការទៀត ចាប់ទៀតទៅ។ វាបីបួនលើក។ សូមបញ្ជាក់ជូនអ៊ីចឹង។

**ស៖** សូមអរគុណលោកសាក្សី។ គ្រូពេទ្យវៀតណាមហ្នឹង គាត់ធ្វើការនៅក្នុងរបបខ្មែរក្រហម ឬក៏ជាគ្រូពេទ្យដែលមកពីណាផ្សេង? អ៊ីចឹងគាត់មានមុខងារអ្វីដែរ ហើយនៅធ្លាប់ធ្វើការនៅមន្ទីរពេទ្យណាដែរ?

[១៤:០៤:០២]

**ឆ៖** ពេទ្យវៀតណាមដែលនៅជិតៗគ្នាតាមព្រៃ តាមដុបហ្នឹង ហើយគេជិតខាងពេទ្យទៅទាក់ទងគេមកជួយជាមិត្តណ៌ា។ ពេទ្យខ្មែរអត់មានវៀតណាមឯណា។ វៀតណាមដែលនៅ ដែលខ្ញុំជម្រាបខាងដើមមក នៅតាមព្រៃខាងលិចហ្នឹង។ គេមានមកអង្គភាពគេមានពេទ្យ មានសេដ្ឋកិច្ចអីគ្រប់ទាំងអស់ ស្រី ប្រុស ឆ្លងទន្លេយ៉ាងម៉េច អីយ៉ាងម៉េច មានទាំងអស់។ វះកាត់មានគ្រប់ទាំងអស់ អ្នកចម្បាំង។ ហើយទៅទាក់ទងមក គេជួយ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ លោកស្គាល់ឈ្មោះ ណាំ សឺន ទេ?

**ឆ៖** អត់ទេ អត់ដែរឮទេ។

**ស៖** ណាំ សឿនៗ?

**ឆ៖** ណាំ សឿន ក៏អត់។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់និយាយអំពីអត្តចរិតរបស់ តាម៉ុក។ ខ្ញុំចង់សួរសំណួរបុរាណបន្តិចគឺថាលោកស្គាល់សុភាសិតថា "នៅលើ តាម៉ុក – នៅលើក្បាលតាម៉ុកមានម្លូក"។ លោកស្គាល់សុភាសិនហ្នឹងទេ លោកស្គាល់ហើយទេ? ហើយបើស្គាល់ហ្នឹងថាតើមានន័យថាយ៉ាងម៉េចដែរ?

[១៤:០៥:០០]

**ឆ៖** ពាក្យនេះបុរាណមក មិនមែនសុភាសិតទេ ទើបឮត្រឹមហ្នឹងតាម៉ុកហ្នឹង ខ្ញុំក៏មិនទាន់កំណត់ជាពាក្យ សុភាសិតរបស់ជាតិទេ អត់ទាន់ឲ្យចូលទេ។ ទើបឮត្រឹមហ្នឹង មិនដឹង តាម៉ុក ថាក៏អ្នកណាខ្ញុំទើបឮតែកុងឡានថាអ៊ីចឹង។ ថា"នៅលើក្បាល តាម៉ុក មានម្លូក"។ ហើយខ្ញុំឮអី មានមេឃ អត់ចាំទេមិនត្រឹមចាំចឹង ហើយអស់ហើយ។ ពាក្យហ្នឹងដូចជាពាក្យលេងផងៗ បញ្ឆើតាម៉ុកខ្លះផង ហើយ តាម៉ុកគាត់ថាអ៊ីចឹងក៏មិនដឹង ខ្ញុំអត់ដែលឮ អត់ទេ ឮតែគេនិយាយអ៊ីចឹង។ ជិះឡាន នៅលើឡានថាអ្នកឡានថាដែលផ្តាច់ខ្លួនមកហើយ មកលេងស្រុកម្តង ឆ្នាំ២០០០គត់។ ជិះឡានមួយយប់ មួយថ្ងៃ ដល់ភ្នំពេញហើយបានឆ្លងទៅដល់នោះ។ ជិះទាល់ភ្លឺអត់មានបានដេកទេ អង្គុយអ៊ីចឹង។ អស់ហើយ។

**ស៖** សូមអរគុណលោក។ កាលពីម្សិលមិញលោកបាននិយាយអំពីទំនាក់ទំនងរវាង ប៉ុល ពត

និង តាម៉ុក ហើយលោកបញ្ជាក់ថា ពួកគាត់ទាំងពីរនាក់ហ្នឹងឈ្លោះទាស់ទែងគ្នា។ លោកនិយាយចុងឆ្នាំ ៧៨ ដើមឆ្នាំ ៧៩ នៅពេលនោះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកដឹងអំពីភាពតានតឹង និងការឈ្លោះគ្នារវាង តាម៉ុក និង ប៉ុលពត នៅចុងឆ្នាំ៧៨ និងដើមឆ្នាំ៧៩ នុ៎ងទេ? គឺថាពេលហ្នឹងហើយអ្នកទាំងពីរហ្នឹងមាន ភាពតានតឹងគ្នាខាងផ្នែកនយោបាយ។ ដើម្បីឱ្យបានពេញលេញនោះ ខ្ញុំចង់សួរលោកថាតើ ប៉ុល ពត -- បើតាមលោកដឹងគឺថាខ្លាច ឬក៏ខ្លាច តាម៉ុក ទេ?

[១៤:០៨:២៩]

**ឆ៖** សូមជម្រាប។ ដឹងកាលនោះ ប៉ុនដល់សភាពការណ៍ហួសផុតអស់ហើយបានខ្ញុំដឹង។ ដល់ជិតហ្នឹង ពេលទាស់គ្នាខ្លាំង សន្និបាតមួយហើយ គេដកខ្ញុំខ្ទាច់។ ងន់ រាយការណ៍ឱ្យតាម៉ុកៗដកខ្ញុំចោល។ ដកខ្ញុំមកផ្ទះមក។ ក្រោយមក ទៀតចាត់តាំង៩៩ លេខរៀងមានឈ្មោះខ្ញុំដែរ ងន់ គេទៅលុបចោលខ្ទាច់ហ្នឹងនិយាយគោលៗ។ ដក ខ្ញុំមកផ្ទះ ធ្វើការនៅផ្ទះ ហើយ០៥ យកខ្ញុំមកធ្វើនៅស្រុកប្រាសាទវិញ។ ជួយគ្នាមកស្រុកអ៊ីចឹងហើយ ជួយមកកុំប្រកាន់។ ឯតាម៉ុក និង--

**ស៖** លោក ពេជ្រ ជឹម សំណួរខ្ញុំសាមញ្ញទេ លោកអាចឆ្លើយថា អត់ ឬក៏មាន។ ខ្ញុំចង់ដឹងថា នៅឆ្នាំ៧៨ និង ៧៩ គឺក្នុងរបបខ្មែរក្រហមនោះ បើតាមលោកដឹង តើ ប៉ុល ពត ហ្នឹងគាត់ខ្លាចញញើត តាម៉ុក ដែរឬអត់? ហើយមានអ្នកទាំងពីរហ្នឹងឈ្លោះគ្នា ឬក៏អត់?

[១៤:១០:០០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

ខ្ញុំមិនជំទាស់ទៅលើសំណួរថាតើវាមានទំនាស់រវាង ប៉ុល ពត ឬក៏អត់ នៅក្នុងអំឡុងពេលនោះទេ? ប៉ុន្តែខ្ញុំចង់ជំទាស់ទៅលើសំណួរដែលសួរថាតើ ប៉ុល ពត ខ្លាចតាម៉ុក ឬក៏អត់? ខ្ញុំគិតថាសាក្សីនេះ គាត់មិនអាចឆ្លើយបានទេ ហើយមេធាវីកំពុងតែនាំមុខសាក្សីរួចទៅហើយ។ ចំពោះបញ្ហាថាតើសាក្សីដឹង អំពីទំនាស់នេះ ឬក៏អត់? ដឹងអំពីភស្តុតាងនៃទំនាស់នេះឬក៏អត់ ខ្ញុំមិនជំទាស់នោះទេ។

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** ប្រសិនជាគាត់ឆ្លើយមិនបាន គាត់ប្រាប់ទៅ ថាគាត់ឆ្លើយមិនបានទៅ។ ខ្ញុំមិនបានសួរឱ្យគាត់ស្មានទេ។ ខ្ញុំគ្រាន់តែសួរគាត់ថាតើគាត់ដឹងអត់? គាត់ធ្លាប់ឮ -- ដូចជាខ្ញុំសួរអម្បាញ់មិញអ៊ីចឹងថា

"នៅលើក្បាលតាម៉ុកមានម្លូក លើម្លូកមានមេឃ" អ៊ីចឹង។ លោកសាក្សី ខ្ញុំសួរលោកហ្នឹង គឺថាសួរលោកមិនឲ្យលោកស្មានទេ។ គឺថាបើលោកដឹង ថាដឹង បើមិនដឹង ថាមិនដឹង។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើនៅពេលរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនោះ លោកដឹងថាអ្នកទាំងពីរហ្នឹងឈ្លោះគ្នាទេ?

[១៤:១១:២៣]

**លោក ពេជ្រ ជីម៖**

**ឆ៖** អត់ទេ។ សម័យនោះអត់ទេ។ ត្រូវគ្នាណាស់។ ដល់ក្រោយមក៧៨។ ចិតអីកៅ? ថ្មីហ្នឹងបានទាស់គ្នា។ បើពីមុនត្រូវគ្នាណាស់។

**ប្រធានអង្គជំនុំ៖**

បានហើយសាក្សី គេ មេធាវីសួរតែអំឡុងកម្ពុជាប្រជាធិបតេយ្យទេ។ អំឡុងឆ្នាំ១៩៧៨ ឬក៏ដើមឆ្នាំ៧៩ គឺបានន័យថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពេញលេញនៅឡើយ។ ដូច្នេះ ក្រៅពីនេះ គឺមិនបាច់ឆ្លើយតបទេ ដូចយើងបានជម្រាបហើយ។ ជៀសវាងក្នុងការឆ្លើយវែងអន្លាយផុតពីវិសាលភាពនៃភាពចាំបាច់ក្នុងការឆ្លើយតបទៅនឹងសំណួរ។ មេធាវីតាំងសំណួរបន្តទៀត។

[១៤:១២:២៨]

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងប្តូរប្រធានបទ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី ឥឡូវនេះ ខ្ញុំចង់សួរសំណួរមួយទៅកាន់លោក អំពីបងប្រុសរបស់លោក។ អ្នកស៊ើបអង្កេតនៃតុលាការនេះ បានសួរលោកជាច្រើនលើកច្រើនសា ជាពិសេសនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦។ គឺ E127.1.4 នៅក្នុងចម្លើយទី៨នោះ លោកថាបងរបស់លោកឈ្មោះ គិត បានជំនួសប្រាក់ យុត ជាប្រធានតំបន់១៣។ តើលោកអាចបញ្ជាក់បានទេ ថានៅពេលណាដែលបងរបស់លោកនោះ ជំនួស ប្រាក់ យុត?

**លោក ពេជ្រ ជីម៖**

**ឆ៖** សូមជម្រាប កាលនោះខ្ញុំមកនៅឆ្ងាយហើយ។ អត់ដឹងខែថ្ងៃច្បាស់ទេ គ្រាន់តែឮដំណឹងថា អ្ហ៎! ឡើងជំនួស។ ឡើងទៀតហើយ គេឡើងហើយ។ ដឹងថាបងខ្ញុំឡើង។ ខ្ញុំក៏បង្អំប្រកបដែរ ការងារសុទ្ធតែរៀងខ្លួន។ អ៊ីចឹង កំណត់អត់បានទេ ថ្ងៃខែអត់ចាំ។ ដឹងថា ឡើង។

[១៤:១៤:២៩]

**ស៖** ដើម្បីជួយលោកត្រង់ចំណុចនេះ នៅពេលដែលគេសួរលោក នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយអ្នកស៊ើបអង្កេតតុលាការនេះ។ គឺឯកសារ E127/7.1.3 លោកបានបញ្ជាក់ថា គេបានបញ្ជូនទៅភូមិភាគកណ្តាលក្នុងជាមួយគ្នា ជាមួយនឹង ប្រាក់ យុត។ ហើយ ប្រាក់ យុត នេះ បានមកផ្តល់សក្ខីកម្មនៅទីនេះ នៅក្នុងសំណុំរឿង០០២/០១ គឺកាលពីឆ្នាំ២០១២ គឺឯកសារ E1/31.1 គាត់បានបញ្ជាក់ថា "គេបញ្ជូនគាត់ទៅភូមិភាគកណ្តាល គឺនៅចន្លោះខែកុម្ភៈ និងខែមិថុនា ឆ្នាំ៧៧"។ លោកបានផ្តល់ចម្លើយ ហើយប្រាក់ យុត ក៏បានផ្តល់ចម្លើយដែរ។ អ៊ីចឹងតើចំណុចនេះធ្វើឲ្យលោកចាំឡើងវិញបានទេថា នៅពេលណាដែលយើងអាចកំណត់អំពីការចាកចេញរបស់លោក និងការចាកចេញរបស់ប្រាក់ យុត ហើយនិងការមកដល់នៃបងប្រុសរបស់លោក។ អ៊ីចឹងចំណុចនេះធ្វើឲ្យលោកចងចាំអំពីការបរិច្ឆេទទេ?

**ឆ៖** អត់ទេ ចាំតែថ្ងៃខ្ញុំចេញទេ បងខ្ញុំចេញខ្ញុំអត់ដឹងទេ។ ប្រាក់ យុត ក៏ខ្ញុំអត់ចាំដែរ។ ហើយមិនបានសាកសួរពីគាត់មកពីណា ខែណា ប្រាក់ យុត មកពីអង្កាល់ អត់បានសាកសួររហូតឥឡូវហ្នឹង។ អត់ទេ អត់ចាប់អារម្មណ៍។

[១៤:១៦:៤១]

**ស៖** បាទ ដើម្បីឲ្យច្បាស់ជាងនេះទៅទៀត លោកអាចរំឭកជូនតុលាការបានដែរឬទេថា នៅពេលណាដែលលោកបានចេញទៅភូមិភាគកណ្តាលនុ៎ង?

**ឆ៖** ថ្ងៃ១៣ ចេញទៅ។ ១៣ដល់ភ្នំពេញ, ១៤ចេញពីភ្នំពេញទៅទៀតដល់កំពង់ចាម។

**ស៖** ក៏ប៉ុន្តែថ្ងៃទី១៣ហ្នឹង ចង់និយាយថ្ងៃទី១៣ ខែណា ឆ្នាំណាដែរ? ពីព្រោះថា១៣ទទេ ខ្ញុំមិនដឹងថា ថ្ងៃណា ខែណា ឆ្នាំណា។

**ឆ៖** មួយពាន់ប្រាំបួនរយហុក អ៊ីចឹង? -- ចិតសិប -- ១៩៧៦។

**ស៖** បាទ សូមអរគុណ។ ដើម្បីបន្តទៅទៀតនៅចំណុចនេះដដែលនេះ លោកបាននិយាយរឿងលម្អៀងបន្តិចដែរថា នៅពេលថ្ងៃទី១ ដែលលោកមកឆ្លើយនៅទីនេះ លោកហាក់ដូចជាប្រាប់ថា លោកចេញទៅភូមិភាគកណ្តាលនោះនៅឆ្នាំ១៩៧៧ទេ។ ប៉ុន្តែព្រឹកមិញនេះលោកបានឆ្លើយថា នៅឆ្នាំ១៩៧៩ ហើយអម្បាញ់មិញនេះក៏អ៊ីចឹង -- ៧៦ ហើយឥឡូវនេះក៏លោកថា ៧៦ដែរ។ អ៊ីចឹង ខ្ញុំសូមនិយាយអំពីព្រឹត្តិការណ៍មួយដើម្បីជួយឲ្យលោករំឭកកាលបរិច្ឆេទឡើងវិញ។ គឺថា និយាយពីទង់កិត្តិយស។ លោក

បាននិយាយថា លោកបានទទួល -- ស្រុករបស់លោកបានទទួលរង្វាន់ទង់កិត្តិយសហ្នឹងដោយលទ្ធផលនៃការងារ នៃស្រុករបស់លោកនៅឆ្នាំ១៩៧៦។ អ៊ីចឹង នេះគឺជាលទ្ធផលសេដ្ឋកិច្ចនៅក្នុងឆ្នាំ១៩៧៦ នោះ អ៊ីចឹងខ្ញុំសួរថាតើ -- ខ្ញុំសួរលោកថាតើ អ៊ីចឹង តើវាមានរឿងហាក់ដូចជាមិនមានន័យទៀតទេមើល៍ទៅ ព្រោះថា ពេលដែលលោកទទួលរង្វាន់នោះនៅពាក់កណ្ដាលឆ្នាំ១៩៧៦នោះ -- នៅដើមឆ្នាំ១៩៧៦នោះ ឬក៏អាចឆ្នាំ ហើយឆ្នាំពីរខុសគ្នា ៧៦, ៧៧។ សូមលោកជួយពន្យល់បញ្ជាក់ម្ដងទៀតមើល៍?

[១៤:២០:០៧]

**ឆៈ** ថ្ងៃហ្នឹងបើខុស ខុសតាំងពីថ្ងៃចុះដំបូងមក តាំងសម្ភាសដំបូងនៅផ្ទះខ្ញុំ។ ខ្ញុំថា ៧៦ អ្នកកត់ថា អត់ទេ ៧៧។ ដល់សួរអ្នកណាក៏៧៧ដែរ ហើយខ្ញុំនៅស្ងៀម។ បញ្ជាក់ប៉ុណ្ណឹង។ អ្នកដែលទៅសម្ភាស គេកត់ ៧៧ មិនមែន ៧៦ ទេ។ ខ្ញុំនៅស្ងៀមទៅ។ ប៉ុនចំណាំខ្ញុំ ខ្ញុំថា ៧៦ ខែ០២ ឆ្នាំ៧៦។ ឯធ្វើពិធីប្រគល់បក្សហ្នឹងអាច ៧៥ ក្រោយរំដោះ៧៥ ធ្វើនៅហ្នឹងមុនបន្តិចហ្នឹង។ ហ្នឹងសូមបញ្ជាក់ជូនប៉ុណ្ណឹង។ ហើយអង្គការតុលាការកែដាក់ម៉េច ដាក់ទៅខ្ញុំអត់ទំនាស់ទេ។ បើដំណើរហ្នឹងវាអ៊ីចឹងខុសថ្ងៃ បច្ចេកទេសប៉ុណ្ណឹង ខ្ញុំអត់ទាស់ទេ។

**សៈ** បាទ លោកសាក្សី ខ្ញុំមានទង់បដិវត្តបកប្រែថ្ងៃទី៦ ខែ៦ ឆ្នាំ១៩៧៧ គឺឯកសារ E3/135 នៅក្នុងឯកសារនេះ គឺថានៅខែ៦ ឆ្នាំ១៩៧៧ នេះមានការប្រគល់ពានរង្វាន់ទង់បដិវត្តនៅឆ្នាំ១៩៧៧ ទៅស្រុកត្រាំកក់។ អ៊ីចឹងដោយសារលោកធ្វើការនៅស្រុកត្រាំកក់ អ៊ីចឹងខ្ញុំសួរថាតើនៅពេលដែលគេផ្ដល់ទង់កិត្តិយសនេះឲ្យនេះ លោកនៅត្រាំកក់ដែរឬទេ ពេលហ្នឹង?

**ឆៈ** កាលនោះ ខ្ញុំនៅនោះ។ តាម៉ុក អ្នកប្រគល់។ មកដាក់នៅលើតុ អត់មានជូនដៃទេ តុអ៊ីចឹង ហើយខ្ញុំអង្គុយតុហ្នឹង គាត់កាន់មកដាក់ប៉ុក "ជូនបក្ស១០៥ និងកម្មាភិបាលទាំងអស់ដែលខំប្រឹងធ្វើការបានផលស្រូវ ជាប់លេខ១"។ ប៉ុនទង់ហ្នឹងដាក់នៅពីមុខខ្ញុំ។ មេដាយទង់នេះ ស្មើហ្នឹងមេដាយមាស។ បញ្ជាក់ប៉ុណ្ណឹង។

[១៤:២៣:១៥]

**សៈ** បាទ ខ្ញុំសូមអរគុណដែលបាននិយាយបញ្ជាក់នេះ ដែលអាចឲ្យខ្ញុំស្គាល់ពីកាលបរិច្ឆេទ ដែលខ្ញុំចង់បាន។ នៅទីនេះ លោកបាននិយាយច្រើនដងអំពីស្ត្រីម្នាក់ដែលឈ្មោះ បឿន។ តើ បឿន នេះ មានមុខងារអ្វីដែរនៅក្នុងស្រុកហ្នឹង? ហើយគាត់កាន់មុខតំណែងគាត់នៅក្នុងស្រុកហ្នឹង នៅពីពេលណា ដល់ពេលណាដែរ បើសិនជាលោកដឹង?

**ឆ៖** កាលខ្ញុំនៅ គាត់ធ្វើឃុំ ប្រធានឃុំជាងទង។ ហើយពេលដែលខ្ញុំចេញហួសមក ដឹងគាត់មានបានឡើងមកចូលស្រុកដែរឬក៏អត់ អត់ដឹង។

**ស៖** បើសិនជាលោកមិនដឹងនោះ បើលោកមិនដឹងម៉េចក៏លោកនិយាយពីរឿងហ្នឹងដូចជាមើលទៅដូចជាធម្មតាអ៊ីចឹង?

**ឆ៖** មិនដឹងត្រង់គាត់ឡើង បើឡើងៗពេលណា អីពេលណា ព្រោះខ្ញុំទៅនោះហើយ ខ្ញុំអស់ពេលដកឡើង លើកហើយ។ អ្នកខាងនោះ អ្នកនៅត្រាំកក់ថ្មី មួយតំបន់គេលើកនោះ។ បើមានលើកខ្ញុំអត់ចាំថ្ងៃដឹងទេ។ ហើយលើកកាលនោះ សូមបញ្ជាក់ជូន មួយខែបាត់ ពីរខែបាត់ គ្រាន់តែលើកធ្វើការនោះ ឲ្យដឹងនឹងគ្នាប៉ុណ្ណឹង មិនទាន់ប្រកាសធ្វើមីទិ្ដងអី សន្និបាតគេដឹងទូទាំងខេត្តផង តំបន់ផង បាត់ទៀតហើយ ឡើងទៅលើទៀតហើយ ឡើងទៅទៀត សភាពការណ៍សង្គ្រាមធ្វើឲ្យច្បាប់ទាំងអស់ទៅអត់រួច។ គឺដកដាក់ៗ បើមិនអ៊ីចឹងវាអត់ទាន់សភាពការណ៍ ហើយចាំយើងមករួមដឹងដែរ បើចេញហើយ យើងមកធ្វើអីទៀត។ សូមបញ្ជាក់ជូនអ៊ីចឹង។ ឯ បឿន ហ្នឹង ខ្ញុំឧស្សាហ៍និយាយហ្នឹង ការងារអីរាក់ជ្រៅប្រាប់គ្នា គាត់ក៏ប៊ានសំណូមពរខ្ញុំ ថាអី "កុំកាចពេក ព្រោះអាណិតប្រជាជន គ្រប់គ្រងប្រជាជន" ខ្ញុំក៏ជួយគាត់។ គាត់ឃុំបង្អែករបស់ស្រុក។

[១៤:២៦:១៩]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមចោទសំណួរមួយទៀតទាក់ទងទៅនឹងភូមិសាស្ត្រនៅស្រុករបស់លោក។ អ៊ីចឹង ខ្ញុំចង់សួរថាតើព្រំប្រទល់ខាងកើតនៃស្រុកត្រាំកក់នោះនៅតាមបណ្ដោយផ្លូវរទេះភ្លើងឬក៏យ៉ាងណា? អ៊ីចឹងខ្ញុំសូមម្ដងទៀត។ តើព្រំប្រទល់ស្រុកត្រាំកក់ហ្នឹងស្របនឹងផ្លូវរទេះភ្លើងឬក៏យ៉ាងណា?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ស្របត្រង់កន្លែងតាមផ្លូវជាតិខាងលិចក្រុង។ ដល់មកត្បូង ដល់មកជើងគឺឆាក ឆាកយកឃុំរំចង់មួយទៀត ក្នុងស្រុកទ្រាំងហ្នឹង។ មូលហេតុយក ស្រុកទ្រាំងចូលទៅអត់ដល់ ស្រុកត្រាំកក់ចូលដល់។ ហ្នឹងភូមិសាស្ត្រសង្គ្រាមអ៊ីចឹង គេចូលដល់គេធ្វើ បើឯងមាន មានចូលឯណាបាន អ៊ីចឹងគេឲ្យទៅនេះសិន។ ខាងត្បូងក៏អ៊ីចឹងដែរ។ ខាងកើតផ្លូវរទេះភ្លើង ព្រោះគេមានដៃបង្អែកឈរពីក្រោយ គេទ័ពដឹកជញ្ជូនគ្រាប់រំសេវទៅរួច ខាងនោះទៅអត់រួច អត់ឈ្នាន់។ សូមអស់។

**ស៖** ខ្ញុំត្រូវសួរលោក ថាតើខ្ញុំត្រូវយល់យ៉ាងម៉េចដែរ ថាផ្លូវរថភ្លើងហ្នឹងឆ្លងកាត់ស្រុកត្រាំកក់នៅកន្លែងណាមួយ ឬក៏យ៉ាងម៉េច លោកឆ្លើយអម្បាញ់មិញចង់និយាយថាអីចឹង? ថាផ្លូវរថភ្លើងហ្នឹងរត់កាត់ ឆ្លងកាត់ស្រុកត្រាំកក់ ឬក៏យ៉ាងណា?

**ឆ៖** គឺផ្លូវហ្នឹងត្រង់ ចេញពាក់កណ្ដាលកុងហ្នឹងមក មកដល់ហ្នឹង។ ផ្លូវចំពាមហ្នឹង ផ្លូវរទេះភ្លើងអត់ទេ ឆ្លងត្រឹមហ្នឹង ត្រង់ផ្លូវចំពាមហ្នឹងឆ្លងមកជើងមក អត់មានចូលក្រុងទេ វ៉ានៅហ្នឹង។ ដូចនេះចែកគ្នាត្រឹមរទេះភ្លើងហ្នឹង។ និយាយប៉ុណ្ណឹងហើយឆាប់ចប់ ឆាប់ស្គាល់។

**ស៖** បាទ សូមអរគុណ។ ក៏ប៉ុន្តែ ខ្ញុំសុំឲ្យលោកផ្ដង់អារម្មណ៍ទៅសំណួរខ្ញុំ។ ខ្ញុំសួរម្ដងទៀតថាផ្លូវរថភ្លើងមានឆ្លងកាត់លើទឹកដីស្រុកត្រាំកក់ដែរឬទេ? ឬក៏ដើម្បីទៅដល់ផ្លូវរទេះភ្លើងហ្នឹងយើងត្រូវចេញពីទឹកដីរបស់ស្រុកត្រាំកក់ហ្នឹងបានទៅដល់ផ្លូវរទេះភ្លើង?

**ឆ៖** មានកាត់ ផ្លូវរទេះភ្លើងហ្នឹងកាត់លើស្រុកត្រាំកក់ ទ្រាំងក៏កាត់។ សូមអស់ហើយ។

**ស៖** តើលោកមានស្គាល់កន្លែងមួយដែលមានឈ្មោះអូរចំបក់ដែរឬទេ? បើមាន -- គោកចំបក់ -- ហើយបើលោកស្គាល់ទេនៅកន្លែងណាដែរ? បាទ ខ្ញុំអានម្ដងទៀតគឺឈ្មោះ អូរចំបក់ បាទ។

[១៤:៣០:៤៨]

**ឆ៖** អត់ស្គាល់ ជួនឈ្មោះពីរហៅខុសគ្នា ខ្ញុំមិនដែលឮ។ អូរចំបក់ហ្នឹង បើនៅគៀនខាងកើតទៀតខ្ញុំក៏មិនដែលចូលដល់ជិតអស់ហ្នឹង ដូច្នេះមិនស្គាល់ច្បាស់។

**ស៖** តើលោកដឹងដែរឬទេថាកន្លែងនោះ អូរចំបក់ហ្នឹងស្ថិតនៅស្រុកត្រាំកក់ ឬក៏នៅក្រៅស្រុកត្រាំកក់?

**ឆ៖** អត់ច្បាស់ នឹកមិនឃើញហើយមិនដឹងនៅត្រង់ណា មិនដែលធ្លាប់ស្គាល់ ឬក៏ស្គាល់ហើយភ្លេចវិញ ប៉ុនមិននឹកឃើញអូរចំបក់មាននៅម្ដុំលិចក្រុងហ្នឹង មិនមានៗទេ អត់មានអូរទេ។ នៅក្នុងទ្រាំងមិនច្បាស់ទេ សូមរំលងទៅ។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបញ្ជាក់។ តើលោកដឹងដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យលោកដឹងទេថាគេបានសាងសង់ប្រឡាយចេញពីទឹកសាបមកត្រាំកក់ហ្នឹងដើម្បីស្រោចស្រពធ្វើប្រព័ន្ធស្រោចស្រព?

**ឆ៖** អត់យល់ ទឹកសាបឯណា?

[១៤:៣៣:០០]

**ស៖** បាទ តើលោកដឹងទេ ថាតើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពី ៧៥ ទៅដល់ ៧៩ ហ្នឹង ដឹងទេថាគេបានសាង -- ធ្វើជីកប្រឡាយចេញពីបឹងមកពីតាកែវមកហ្នឹងមកស្រុកត្រាំកក់។ ប្រឡាយហ្នឹងអូសមកពីតាកែវមកត្រាំកក់ ដើម្បីជាប្រព័ន្ធស្រោចស្រព។ តើលោកមានដឹងទេថាមានគេជីកប្រឡាយហ្នឹង?

**ឆ៖** សូមបញ្ជាក់ដល់គាត់ឮអ៊ីចឹង បាននឹកឃើញ។ ខ្ញុំចេញហួសហើយ មានធ្វើមែន។ សាន ធ្វើ។ ថ្ងៃមួយខ្ញុំមកយកស្មីមកឲ្យទេកាលហ្នឹង មកលេងហើយចូល "បងអើយមកដេកលេងនេះហើយ មកដេកមួយគ្នាមួយយប់" "ធ្វើអីហ្នឹងចុះ!" "ធ្វើកន្លែងបូមទឹក" ជួបបងសានហ្នឹង។ ខ្ញុំថា "ដេកអី បើប្រញាប់ទៅដល់នោះៗព្រឹកឡើងមកវិញហើយ នៅដេកមិនកើត" "អ៊ីចឹងស្រេចតែបង"។ ក៏អត់បានដេកជាមួយគ្នាទេ ព្រោកមួយសន្ទុះ ខ្ញុំមកដេកអង្គរកាទៅ។ ដល់អង្គរកា មានបានស្មី យប់ជ្រៅសំបុត្រតាមទាន់ទៅវិញទាំងយប់ សំបុត្រមកកន្លែង នីរសារមក យកសំបុត្រមក ទៅវិញទាំងយប់។ ដល់កំពង់ចាមវិញភ្លឺការងារផ្សៀតតែបន្តិចហ្នឹងក៏មមាញឹក។ សូមអស់ហើយ។ សាន ធ្វើ។

[១៤:៣៥:០០]

**ស៖** តើលោកដឹងដែរឬទេថាគេចាប់ផ្តើមជីកប្រឡាយហ្នឹង ចាប់ជីកពីតាកែវមក ឬក៏គេចាប់ជីកពីខាងត្រាំកក់នេះ ទៅតាកែវវិញទេ តើលោកដឹងថាគេចាប់ផ្តើមជីកពីខាងណាទៅខាងណា?

**ឆ៖** មិនច្បាស់។ ឆ្លើយខុសហើយ! សួរជីកបូមទឹកពីតាកែវឡើងលើ មកលាយបូរ។ ខ្ញុំជួបសាន ធ្វើហ្នឹង។ ឥឡូវសួរពីត្រាំកក់។ ត្រាំកក់ប្រឡាយពីខ្ពបត្របែក ជាពីរ។ ផ្លូវពីរផ្លូបសួរតែមួយ ឆ្លើយម៉េច? ចងកន្ទុយមួយមកជួបនេះអ៊ីចឹង ឆ្លើយថាអី? សូមអត់ឆ្លើយ។

**ស៖** បាទ កាលពម្សិលមិញ មានចៅក្រមមួយរូបបានសួរសំណួរមួយទៅលោក ទាក់ទងទៅនឹងទស្សនកិច្ចជាយថាហេតុរបស់លោក ខៀវ សំផន ហើយនិង នួន ជា នៅការដ្ឋាន ហើយនិងការជីកប្រឡាយ។ ហើយពេលនោះលោកបានឆ្លើយថា ខ្ញុំសូមដកស្រង់អានជូនលោកស្តាប់។ ក្រោយម៉ោង ១១:៣៩:៥៤ លោកបានឆ្លើយថា "ខ្ញុំដឹងថា ពួកគាត់បានមកនៅពេលហ្នឹង ក៏ប៉ុន្តែខ្ញុំមិនដឹងថានៅកន្លែងណាជាក់លាក់នោះទេ។ ហើយក៏ខ្ញុំមិនដឹងថាខ្ញុំបានជួបគាត់ដែរឬទេ ក៏ប៉ុន្តែកាលនោះមានមនុស្សម្នាក់ឈ្មោះ សែន ទៅតាមសហករណ៍។ បើតាមដឹងហ្នឹង ខ្ញុំមិនដែលធ្លាប់ជូនគាត់ទៅទេ ព្រោះខ្ញុំមានការងារផ្សេងទៀតត្រូវធ្វើ។ ខាងមុខ ហើយអ្នកផ្សេងទៀត អ្នកចាត់ចែងខាងទស្សនកិច្ចរបស់គាត់ហ្នឹង ព្រោះនាំគាត់ទៅសហករណ៍អីហ្នឹង ខ្ញុំមិនដឹងទេ"។ អ៊ីចឹង ខ្ញុំសូមសួរលោកថា សែន នេះ ដែលលោកបាន

និយាយម្សិលមិញនេះ សែន ហ្នឹងជាបុគ្គលដែលលោកទើបតែនិយាយអម្បាញ់មិញហ្នឹងមែនទេ? មនុស្ស តែមួយ ឬក៏យ៉ាងណា?

[១៤:៣៨:១១]

**ផ៖** មិញអត់មាននិយាយ សែន ទេ។ បើពីម្សិលមាននិយាយ សេន។ ដឹងថា ហ៊ូ សេន ហ្នឹង នាំបង ខៀវ សំផន ទៅលេង ទៅទស្សនកិច្ច ប៉ុន្តែខ្ញុំនឹក -- រកនឹកឃើញ “កាលនោះអញទទួលគាត់ ត្រង់ណា?” ដូចនឹកវាមិនឃើញ។ ប៉ុន្តែ ហ៊ូ សេន អ្នកនាំ ហើយដឹងដំណឹង។ ប្រហែលមិត្ត ខុម ទៅទទួលជូនគាត់ ហើយខ្ញុំ មិត្តខុម ឲ្យនៅទទួលការងារអីៗផ្សេង។ ហ្នឹងប្រហែលអ៊ីចឹងទេ។ បានសម ភ្លេច។ សេន ហ្នឹង នៅមន្ទីរ នៅភ្នំពេញ មន្ទីរភ្នំពេញ ជូនលោក នួន ជា ហើយលោក ខៀវ សំផន ទៅ។

**ស៖** អ៊ីចឹង ទស្សនកិច្ចដែលលោកមិនមានវត្តមានហ្នឹង បើតាមលោកដឹងហ្នឹង ទស្សនកិច្ចហ្នឹង បានប្រព្រឹត្តទៅនៅថ្ងៃណា? ខែណា? ឆ្នាំណា? បើសិនជាលោកចាំ។ ហើយអ្នកណាជាអ្នកនិយាយ អំពីទស្សនកិច្ចហ្នឹងទៅកាន់លោក?

**ផ៖** អត់ទេ អត់ចាំ។

**ស៖** តើលោកចាំថាអ្នកណា អ្នកនិយាយពីទស្សនកិច្ចហ្នឹងប្រាប់លោកដែរឬទេ? បើមិនអ៊ីចឹងទេ តើលោកដឹងតាមរបៀបណាដែរ?

**ផ៖** នឹកឃើញហើយ កាលនោះខ្ញុំនៅកណ្តាលហើយ ហើយខ្ញុំទៅលេងឮថា បង ខៀវ សំផន ថ្ងៃមុនមកនេះ មកត្រាំកក់។ ហ៊ូ សេន ជូនមក ខ្ញុំនៅកំពង់ចាមហើយ។ សូមអស់ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណបាទ។ អ៊ីចឹងគេប្រាប់លោក ប៉ុន្តែលោកមិនចាំថាអ្នកណាជាអ្នកប្រាប់ នោះទេ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ឥឡូវ-- បាទ អរគុណលោកមេធាវី ឥឡូវនេះដល់ពេលសម្រាកហើយ។

**លោក អាកខ្ទួរ វ៉ែកគែន៖**

លោកប្រធាន ខ្ញុំអត់បានឮចម្លើយជាភាសាបារាំងទេ លោកប្រធាន។ ខ្ញុំសូមស្តាប់ចម្លើយគាត់ បន្តិចសិនបានទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមៗលោកពេជ្រ ជឹម ឆ្លើយសំណួរចុងក្រោយអម្បាញ់មិញពាក់ព័ន្ធជាមួយនឹងរឿងដំណើរទៅ

ទស្សនកិច្ចរបស់លោក ខៀវ សំផន ហ្នឹងណា ដែលលោកដឹង។ អំមិញឮតែភាសាខ្មែរ ហើយអត់មានបានបកប្រែជាភាសាបារាំង និងភាសាអង់គ្លេស។

**លោក ពេជ្រ ជីម៖**

**ឆ៖** ទស្សនកិច្ចរបស់លោក ខៀវ សំផន ហ្នឹងលោក គឺកាលនោះ ខ្ញុំទៅនៅភាគកណ្ដាលហើយដល់មកលេងមកតាកែវ មកគេប្រាប់ អ្នកមន្ទីរ១០៥ គាត់ថា "បងខៀវ សំផន ទើបនឹងមក ហ៊ូ សេនជូនទៅ"។ "គាត់មកធ្វើអី? គាត់ថាគាត់ធ្វើទស្សនកិច្ចមកមើលស្រូវស្រែផលដំណាំយើង"។ ប៉ុណ្ណឹងខ្ញុំដឹងត្រឹមប៉ុណ្ណឹង។ សូមអស់។

[១៤:៤៣:២៦]

**លោក អាកទ្បូរ វែកគែន៖**

បាទ ខ្ញុំបានចម្លើយរបស់គាត់ហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្ដល់វេទិការជូនទៅក្រុម

មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីលោកខៀវ សំផន ថាតើមានសំណួរអីច្រើនដែរឬទេ ដែលអាចបន្លាយពេលដល់ម៉ោងបួនដែរឬទេ? ពីព្រោះបញ្ហានេះ ថ្ងៃសុក្រពាក់ព័ន្ធជាមួយនឹងលទ្ធភាពក្នុងការពិនិត្យមធ្យោបាយដឹកជញ្ជូនបុគ្គលិកត្រឡប់ទៅទីក្រុងភ្នំពេញវិញ។

**លោក អាកទូរ វែកគែន៖**

លោកប្រធានខ្ញុំគិតថា យើងប្រហែលជាអាចចប់មុនម៉ោងបួនលោកប្រធាម យ៉ាងយូរបំផុតហ្នឹងម៉ោងបួនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោក ពេជ្រ ជឹម កាលពីម្សិលមិញលោកបាននិយាយអំពីគម្រោងការងារនៅក្នុងស្រុករបស់លោក។ លោកបាននិយាយថានៅចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ការដ្ឋាននៅក្នុងស្រុករបស់លោកហ្នឹងពីដើមមកធ្វើឡើងដោយមានការចេញបញ្ជាពីស្រុកហើយ ដោយមានឯកភាពពីតំបន់។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ។ តើតំបន់ហ្នឹង គឺមកមើលទីតាំងការដ្ឋានសិនមុននឹងយល់ព្រម ឬក៏តំបន់នោះទុកចិត្តទៅសំណើដែលស្រុកដាក់ជូនទៅតំបន់ ដោយមិនបាច់មកមើលទីតាំងដោយខ្លួនឯងទេ អ៊ីចឹងឬក៏យ៉ាងណា?

[១៥:០៤:១៤]

**លោក ពេជ្រ ជឹម៖**

**ឆ៖** ស្តាប់អត់បានទេ។

**ស៖** បាទខ្ញុំសួរឡើងវិញម្តងទៀត។ នៅពេលដែលមានគម្រោងការដ្ឋាននៅក្នុងស្រុករបស់លោកតើការងារទាំងអស់ហ្នឹងៗ ដូចលោកនិយាយម្សិលមិញអ៊ីចឹង គឺថាការងារទាំងអស់ហ្នឹងគឺស្នើដោយស្រុកគឺថាស្រុកផ្តួចផ្តើមគំនិតខ្លួនឯង ខ្ញុំសួរថាតើស្រុកនោះជាអ្នកផ្តួចផ្តើមគំនិតធ្វើការដ្ឋានអីហ្នឹងឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

តាំងសំណួរសាជាថ្មី! អំមិញបែបមានបញ្ហាថាមពល ឧបករណ៍។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** បាទនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ការដ្ឋាននៅក្នុងស្រុករបស់លោកហ្នឹង កើតចេញពីគំនិតផ្តួចផ្តើមរបស់ស្រុក ឬក៏យ៉ាងណា?

**លោក ពេជ្រ ជឹម៖**

**ឆ៖** មតិណែនាំរបស់តំបន់ ណែនាំខាងស្រុកហើយពិគ្រោះគ្នាទៅមើល ក៏សម្រេចធ្វើ។ ប៉ុនថា ខាងភូមិភាគមានណែនាំពីមុនមក ទាំងតំបន់ទាំងស្រុក។ គាត់មកហ្នឹងណែនាំធ្វើទំនប់ រកមើលដី មើលកន្លែងធ្វើទំនប់។ គាត់ថា "មើលមានផែនទីផែនអី គូរលើផែនទីហ្នឹងមក ធ្វើត្រង់ណាវាងយ៉ាងម៉េច" ហើយក៏ពិគ្រោះគ្នាធ្វើមានទ្រង់ទ្រាយធំអ៊ីចឹងមក មានការយល់ព្រមពីតំបន់។ ដល់ហើយក៏ពិគ្រោះជាមួយតំបន់។ ដូចនេះ មិនៗស្រុកម្នាក់ឯង គឺឯកភាពអង្គការខាងលើ ទាំងតំបន់ ទាំងភូមិភាគ។

**ស៖** បាទ ដើម្បី -- នៅពេលដែលស្រុកសម្រេចថាធ្វើទំនប់អីមួយហើយ តើតំបន់ ឬក៏ភូមិភាគហ្នឹងចុះមកមើលដល់កន្លែងដើម្បីផ្ទៀងផ្ទាត់ដោយខ្លួនឯងឬក៏តំបន់ ឬក៏ភូមិភាគហ្នឹងគាត់ទុកចិត្តលើស្រុកហើយឲ្យស្រុកធ្វើទៅមិនបាច់ចុះមកមើលទេ?

**ឆ៖** ពិតមែន គាត់ព្រមហើយរៀបចំយ៉ាងម៉េច ប្អូនគាត់ទៅមើលដីហើយ ធ្វើចុះ! ដល់ហើយបានភូមិភាគទៅមើល។ អស់ហើយ។

[១៥:០៩:៣២]

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយពីប្រធានបទមួយទៀតដែលទាក់ទងនឹងការបញ្ជូនស្រោមសំបុត្របិទៗជិត ឬក៏បើកចំហរវាងមន្ទីរសន្តិសុខក្រាំងតាចាន់ និងការិយាល័យ -- មន្ទីរស្រុក ហើយនិងមន្ទីរតំបន់។ ឥឡូវខ្ញុំសូមសង្ខេបអ្វីដែលលោកបាននិយាយអំពីការបញ្ជូនស្រោមសំបុត្រទាំងអស់នេះ។ បើសិនជាខ្ញុំមិនច្រឡំទេ លោកបានពន្យល់ថា ស្រោមសំបុត្រដែលបិទជិត មានបញ្ជីអ្នកទោសនៅក្រាំងតាចាន់ ដែលចេញពីស្រោមសំបុត្រនេះ ចេញពីមន្ទីរសន្តិសុខហ្នឹងបញ្ជូនទៅមន្ទីរស្រុក ហើយលោកមិនបើកស្រោមសំបុត្រហ្នឹងទេ លោកត្រូវបញ្ជូនទៅបន្តទៅតំបន់ទៀតដែលតំបន់នោះគេជាអ្នកបើកស្រោមសំបុត្រនោះ ហើយគេជាអ្នកសម្រេចផងដែរទៅលើជោគវាសនានៃទោស នៅមន្ទីរក្រាំងតាចាន់។ ហើយបានដាក់សំបុត្រហ្នឹងនៅក្នុងស្រោម ហើយបិទជិត ហើយបញ្ជូនទៅឲ្យលោក ដើម្បីឲ្យលោកបញ្ជូនបន្តទៅមន្ទីរក្រាំងតាចាន់ទៀត។ តើការរៀបរាប់របស់ខ្ញុំនេះ ជាការសង្ខេបត្រឹមត្រូវនៃអ្វីដែលលោកនិយាយហ្នឹង គឺការបញ្ជូនសំបុត្រដែលចេញពីក្រាំងតាចាន់ ហើយបញ្ជូនមកក្រាំងតាចាន់វិញនេះ។ ខ្ញុំសង្ខេបអម្បាញ់មិញនេះត្រឹមត្រូវដែរឬទេ?

[១៥:១១:៤០]

**ឆ៖** សំបុត្រដែលក្រាំងតាចាន់ផ្ញើមក មានពេលខ្លះមិនផ្ញើទេ។ ផ្ញើត្រង់តែម្តង ទៅមន្ទីរតំបន់

តែម្តង។ មានតែទាក់ទងដល់១០៥ បានផ្ញើឆ្លងកាត់១០៥ សូមបញ្ជាក់ជូន។ អ្នកទោសហ្នឹងមានច្រើន ស្រុកទាំងប្រាំ បើទាក់ទងនឹងស្រុកត្រាំកក់បានគេឲ្យឆ្លងកាត់ស្រុកត្រាំកក់។ ចុះបើគិរីវង់? ទ្រាំង? គេអត់ឲ្យនេះទេ អត់ឲ្យមកត្រាំកក់ទេ គេទៅតំបន់ហើយ។ មានការទាក់ទងម៉េច តំបន់ហៅស្រុកនោះ មកជួបដោយឡែកទៀត។ ហ្នឹងសូមបញ្ជាក់ជូនប៉ុណ្ណឹង។ ពាក់ព័ន្ធហ្នឹង គឺថាមនុស្សរបស់ស្រុកត្រាំកក់ ត្រាំកក់ទៅទទួល ហើយពិនិត្យតវ៉ាអីយ៉ាងម៉េច មានពេលហ្នឹង ហើយមានសិទ្ធិតវ៉ា សមហេតុផលបានប៉ានដែរ មិនសមផល មិនប៉ានតវ៉ាទេ។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ខ្ញុំសូមអានផ្នែកមួយជូនលោកស្តាប់ គឺជាចម្លើយរបស់លោកដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃតុលាការហ្នឹងនេះ។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ គឺឯកសារ E319.1.18 ចម្លើយ៨៦។ ខ្ញុំសូមអានសំណួរនិងចម្លើយ។ “សំណួរ៖ ជាទូទៅអំណាចលេខាស្រុកនោះ តើគ្របទៅលើបញ្ហាសន្តិសុខ មន្ទីរសន្តិសុខ ឬការចាប់ខ្លួន ឬក៏ការដ្ឋានទាំងអស់ដែលមាននៅក្នុងស្រុកដែរឬទេ? ចម្លើយ៖ មិនមានសិទ្ធិអំណាចចាប់មនុស្សទេ។ ក៏ប៉ុន្តែមានចាត់ចែង និងដោះស្រាយកុំឲ្យមានជនក្បត់។ ចំណែកមន្ទីរសន្តិសុខរបស់តំបន់ ជារបស់បក្ស។ លេខាស្រុកមានសិទ្ធិអំណាចឃោសនា អប់រំ ផ្គត់ផ្គង់ជីវិភាព ដោះស្រាយជីវភាពឲ្យប្រជាជន បំបាត់កុំឲ្យមានជនក្បត់ និងប្រមូលកម្លាំងឲ្យកាន់តែប្រសើរឡើង ដើម្បីវ៉ៃខ្មាំង”។ បាទ សូមចប់ការដកស្រង់។

បាទ សំណួរដូចតទៅនេះ៖ ការបំបាត់ខ្មាំងនៅក្នុងចម្លើយលោកនេះ អ៊ីចឹងតួនាទី របស់លោកនោះ ជនក្បត់ណានៅក្នុងស្រុកនេះ លោកចង់និយាយយ៉ាងម៉េចដែរ? មានន័យថាយ៉ាងម៉េចដែរថាបំបាត់កុំឲ្យមានជនក្បត់ហ្នឹង?

[១៥:១៥:២៨]

**ឆ៖** បញ្ជាក់ជូន នេះការងាររណសិរ្ស ការងារស្រុក ពន្យល់អ៊ីចឹង ហើយបើតាមដានសួរទៅ ខ្ញុំអត់ឆ្លើយអត់កើតទេ។ អប់រំឲ្យល្អ កុំឲ្យមានអ្នកខូចអីហ្នឹង បាត់ហើយ អ៊ីចឹង។ មានការទាស់គ្នាហើយសម្រួលៗគ្នាដោះស្រាយកុំទាស់គ្នាទៅ ឈប់ទាស់ទៅ កសាងគោលជំហរសាមគ្គីភាពគ្នាទៅ ត្រង់ហ្នឹងដែលខ្ញុំថា សិទ្ធិចៅហ្វាយស្រុកមានអ៊ីចឹង។ សួរម៉េចទៅទៀត ខ្ញុំអត់ដឹង។ សូមឆ្លើយប៉ុណ្ណឹងបញ្ជាក់។

**ស៖** អ៊ីចឹងនៅពេលដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេតថាតួនាទីរបស់លោកហ្នឹង គឺថាបំបាត់កុំឲ្យមានជនក្បត់ហ្នឹង។ អ៊ីចឹងត្រូវយល់ថាតួនាទីរបស់លោកហ្នឹងគឺតួនាទីអប់រំជនក្បត់។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** នាទីរបស់ចៅហ្វាយស្រុកហ្នឹងអ៊ីចឹង អ្នកទទួលខុសត្រូវតួនាទីរបស់បក្សហ្នឹងគឺអ៊ីចឹង។ ដឹកនាំទាំងមូល ទាំងពួង ទាំងស្រុង អ្វីទាំងអស់លើបក្សតែមួយ។ បើអ៊ីចឹងជាគណៈ អត់ទេ គ្រាន់មានសិទ្ធិស្មើ។ ឯទាំងមូល ទាំងពួង ទាំងស្រុង បក្សតែមួយ ប្រធានបក្សមួយហ្នឹង។ លោកយល់អ៊ីចឹងបានយល់មាគ៌ាបដិវត្តន៍វាច្បាស់។ បក្សមួយហ្នឹងដាច់ហើយ ដឹកនាំទាំងមូល ទាំងពួង ទាំងស្រុង អ្វីទាំងអស់នៅលើម្នាក់។ បក្សដែលចូលហើយហ្នឹង អត់ទាន់ពេញសិទ្ធិ ពេញហើយក្តីគ្រាន់តែមានសិទ្ធិទៅស្មើទេ។ ឯសម្រេចប្រធានបក្សហ្នឹង ហើយនិងទៅជួបនឹងបក្សខេត្តៗ តំបន់ហ្នឹងទៅជួបបក្សភាគទៀត។ ដូចនេះខាងក្រោម--

**ស៖** លោក ពេជ្រ ជឹម បាទ ខ្ញុំសូមអរគុណ។ អ៊ីចឹង តើលោកខ្លួនឯងផ្ទាល់ហ្នឹងជាសមាជិកបក្សដែរ ជាបក្ខជនដែរ បើខ្ញុំមិនច្រឡំទេ។ នៅក្នុងសំណុំរឿងនេះ មានចម្លើយរបស់សាក្សីម្នាក់ គឺសាក្សី TCW-822 ដែលត្រូវបានសួរទាក់ទងនឹងរឿងលោក គាត់បានប្រាប់ថា នៅក្នុងក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ លោកមានរហស្សនាមមួយ ដែលគេហៅលោកថា លោកជា "យមរាជ យមបាល"។ តើលោកស្គាល់ឈ្មោះរហស្សនាមរបស់លោកហ្នឹងទេ? គេហៅថាជា "យមបាល" នៅសម័យនោះ?

[១៥:១៨:៥៧]

**ឆ៖** អត់ដឹងទេ។ មិនដឹងឮគេថាម៉េចៗ អត់ដឹង អត់យល់ទេ ប៉ុន្តែធ្វើហ្នឹងប្រុងប្រយ័ត្នណាស់ អត់ឲ្យខុស អត់ឲ្យជ្រុលជ្រួស អាក្រក់ហួសពេក។ មាត់មនុស្សរាប់រយ រាប់ពាន់ រាប់សែន ទប់យ៉ាងម៉េចក៏មិនស្កប់ដែរ។ មួយសែនបាន ប៉ុន្តែនៅសល់២.០០០, ៣.០០០ គេអត់ពេញចិត្ត។ មនុស្សកាលនោះ ២៥០.០០០ នៅស្រុកត្រាំកក់ ប៉ុនមួយខេត្ត។ សូមអស់។ គេថាអីថា ខ្ញុំមិនមានការខឹងតូចចិត្តអីទេ។ សូមអស់ហើយ។

**ស៖** ខ្ញុំសុំស្នើមួយថា តើដើម្បីគ្រប់គ្រង គឺថាបំពេញការងាររបស់លោកជាលេខាស្រុកនោះ ថាការងារក្នុងការបំបាត់កុំឲ្យមានជនក្បត់ហ្នឹង លោកក៏បានដាក់បន្ទុកទៅលើថ្នាក់តំបន់ទៅវិញ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ ថាស្រុកហ្នឹងថាមកពីតំបន់ទេ ទាក់ទងនឹងការបំបាត់ជនក្បត់អីហ្នឹង?

**ឆ៖** អត់ត្រឹមត្រូវ។ អាហ្នឹងចលនាវាលេចចេញអ៊ីចឹង ចលនាសង្គ្រាមវាកើតអ៊ីចឹង ធម៌វាកើតអ៊ីចឹងមក ធម្មជាតិបង្កើតមកអ៊ីចឹងមក គឺធម៌ ភាវធម៌វាកើតមក គ្មានអ្នកណាបង្កើតទេ។ ហើយគេថាខ្ញុំយមរាជ ថាៗទៅ បើខ្ញុំមិនបានធ្វើយមរាជ មិនបានសម្លាប់អ្នកណា ហើយអនុវត្តទៅតាមគេណែនាំតាមមាគ៌ា តាមបក្ស ធ្វើមែន រួមធ្វើជាមួយមិនធ្វើយ៉ាងម៉េច អត់ធ្វើយ៉ាងម៉េច អត់កើត។ សូមអស់។

នោះ អត់បានបន្ទោសតំបន់ អត់ដែលដាក់ទោសមកពីតំបន់ទេ អត់ទេ។ សូមអស់។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

[១៥:២១:០០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមកត់ត្រាចូលប្រតិចារឹក។ លោកមេធាវី វែកគែន តើឯកសារយោងដែលនិយាយអំពី-- ដែលលោកបានដកស្រង់អំមិញ ពាក្យ "យមរាជ យមបាល" អំមិញហ្នឹង លោកអាចផ្តល់លេខឯកសារ ឬក៏លេខ ERN អីជូនតុលាការបានទេ។

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំនឹងរកឯកសារយោងហ្នឹងជូនតុលាការនៅពេលដែលសហភាតាខ្ញុំគាត់ឡើងសួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

[១៥:២៣:០១]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ពេជ្រ ជឹម។ ខ្ញុំមានសំណួរតិចតួចទេ ដើម្បីនឹងសួរបញ្ជាក់លោក លោកបានឆ្លើយកាលពីថ្ងៃទី២២កន្លងទៅនេះ ពេលព្រឹក ទាក់ទងទៅនឹងតួនាទីរបស់លោក ដែលលោកបានឆ្លើយថា លោកជាគណៈស្រុក ហើយជាបុគ្គលទី៥ ហើយនៅក្នុងស្រុកហ្នឹង គឺមានលេខាដែលលោកចាត់ទុកជាចៅហ្វាយស្រុក ជាមនុស្សទី១នៅក្នុងស្រុក។ ខ្ញុំចង់ឲ្យលោកជួយរៀបរាប់បានទេ ថាតើបុគ្គលទី២ ទី៣ ទី៤ហ្នឹងមានឋានៈអ្វីដែរ នៅពេលដែលលោកធ្វើការស្រុកត្រាំកក់ នៅក្រោយឆ្នាំរំដោះ៧៥ហ្នឹង?

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមជម្រាប បុគ្គលទី១ ខាងបក្ស, ទី២ ក៏គាត់ខាងបក្សមហាជន ដើរធ្វើមីទ្ទិង និងរៀនសូត្រឲ្យបក្ស។ ពីរនាក់ហ្នឹងជាប់គ្នា គារ – ខុម និងគារ។ ទី៣ ភាស់ – ភាស់, ជាតិ ហ្នឹង។ គាត់សមាជិកគណៈកៀងគរនៃតំបន់ គាត់នៅហ្នឹង ដើងជាប់ សមាជិកស្រុក អនុលេខាសាខាបក្សស្រុក។ ទី៤ បានញ៉ៀវ ទទួលខាងយោធា។ ទី៥ ខ្ញុំទទួលខាងសេដ្ឋកិច្ច គេចាត់ទាំងខាងលើហ្នឹងហើយស្រេច ខ្ញុំទើបតែចូលក្រោយៗទេ។ ធ្វើការក្នុងនាម បើនិយាយថារណសិរ្សនៅខាងមុខ ជួរមុខ រត់ការទាំងអស់ ជូនបក្សស្រុក បក្សតំបន់។

[១៥:២៥:០០]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បន្ថែមពីឈ្មោះ ភាស់ និងជាតិ ហ្នឹងជាតិហ្នឹង បានទេ ថាជាសមាជិកហ្នឹងគាត់ទទួលខុសត្រូវផ្នែកអីដែរ?

**ឆ៖** ភាស់, ជាតិ គាត់ទទួលខាងនារី ក្តាប់នារី។ ដូចថា មិត្តខុម គាត់តែឯង គាត់ណែនដៃពេក អ៊ីចឹងមាន ភាស់ ហ្នឹងមើលផ្ទាល់។ នារីកាលនោះមួយខេត្តនៅមូលហ្នឹង។ អ៊ីចឹងគាត់គណៈកៀងគរនារីប្រចាំតំបន់ផង ដើងជាប់ស្រុកម្ខាង។

**ស៖** បាទ ចុះនៅពេលដែលលោក តាមខ្ញុំស្តាប់កន្លងមក បានធ្វើជាលេខាស្រុកត្រាំកក់ហ្នឹង តើការចាត់ចែងការងារហ្នឹងមានការផ្លាស់ទេរវាងលោកទទួលតួនាទីជាគណៈស្រុក ហើយនិងជាលេខាស្រុក?

**ឆ៖** ផ្លាស់ប្តូរតែពេលខ្ញុំចេញមក ចេះឡើងថ្នាក់បន្តិចៗហ្នឹងមក។ ផ្លាស់ពេលខ្ញុំចេញហ្នឹងឯង។

**ស៖** បាទ ផ្លាស់ប្តូរនៅពេលនេះ ខ្ញុំចង់និយាយអំពីការទទួលខុសត្រូវ និងភារកិច្ចជាគណៈស្រុក និងការងារជាលេខាស្រុក។ ឧទាហរណ៍ទាក់ទងនឹងការចាត់តាំង ឬក៏ការងារផ្សេងៗទៀតនៅក្នុងស្រុករបស់លោក។ តើមានការផ្លាស់ប្តូរការងារដែរទេ?

[១៥:២៧:៣៧]

**ឆ៖** មិនយល់។ ក្តាប់អត់ជុំ ចង់ដឹងថាម៉េច សូមបញ្ជាក់ខ្លីមួយម៉ាត់ពីរ។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកប្រៀបធៀបពីការងាររបស់លោក ក្នុងនាមជាគណៈស្រុក ហើយនិងការងារក្នុងនាមជាលេខាស្រុក តើមានចំណុចត្រង់ណាដែលខុសគ្នា ឬដូចគ្នាយ៉ាងដូចម្តេច? លោកអាចបញ្ជាក់បានទេ?

**ឆ៖** មិនមានអីប្លែកគ្នា ព្រោះដល់ការងារដែលខ្ញុំឡើងផុតទៅ ការងារបក្សខ្ញុំទទួល ប៉ុនដល់សេដ្ឋកិច្ចអត់មានអ្នកដាក់ ខ្ញុំទទួលបក្សសេដ្ឋកិច្ចទៀតហ្នឹង ជម្រាបត្រង់។ ទំនប់ប្រឡាយ រកស្រូវអង្ករតំបន់នៅតែទារពីខ្ញុំដដែល អីចឹងអត់មានអ្នកណាដាក់អ្នកណាទេ អត់ ហើយខ្ញុំប្រគល់លើឃុំទាំងអស់ម្ចាស់ការតែម្តង។ គ្រាន់តែទទួលរួម ប៉ុន្តែឃុំម្ចាស់ការប៉ុណ្ណេះៗ ធ្វើឲ្យបានប៉ុណ្ណេះបាវៗ ប៉ុណ្ណេះតោនអីចឹង។ ថាឲ្យប្លែកអី គ្រាន់តែបន្ទុកវាទម្ងន់ សូមបញ្ជាក់ជូន ដល់អីចឹងបន្ទុកជាទម្ងន់ឡើង វាចេះតែច្រើនឡើងៗ។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងបទពិសោធន៍របស់លោកផ្ទាល់ ក្នុងនាមជាគណៈស្រុកឬក៏ជាលេខាស្រុកនៅស្រុកត្រាំកក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ជួបនៅបញ្ហាជាក់ស្តែងចូលរួមដោះស្រាយបញ្ហាជាក់ស្តែងណាមួយ ដែលអាចជម្រាបជូនអង្គជំនុំជម្រះបានអំពីការចូលរួមដោះស្រាយរបស់លោក។ ឧទាហរណ៍ទាក់ទងទៅនឹងបញ្ហាម្ហូបអាហារ បញ្ហាស្បៀង។ លោកអាចលើកបញ្ហាដែលលោកបានជួបប្រទះ ហើយធ្វើការដោះស្រាយដោយផ្ទាល់ទៅលើបញ្ហាស្បៀងអាហារនេះបានទេ?

[១៥:៣០:៣៧]

**ឆ៖** កន្លងមកជួបច្រើនណាស់បញ្ហាដោះស្រាយស្បៀងម្ហូបអាហារនេះ។ ការដោះស្រាយមិនមែនម្នាក់ រួមជាមួយប្រធានគណៈទាំងអស់ហ្នឹង។ សំខាន់ឃុំ លេខាឃុំហៅមកជួប ហើយលើកផែនការឲ្យ គេជួយយោបល់មកហើយគេផ្តល់អី ជាស្រូវ ជាអង្ករ ជាអ្វីផ្សេងៗ នៅឃុំហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីករណីជាក់ស្តែងដែលលោកបានដោះស្រាយផ្ទាល់ទេ? ករណីណាមួយដែលឃុំលើកឡើងមកលោក ឬក៏ពីប្រជាពលរដ្ឋលើកពីបញ្ហាហ្នឹងមកលោក ហើយលោកបានចូលរួមដោះស្រាយដោយផ្ទាល់? លោកអាចលើកករណីជាក់ស្តែងបានទេ?

**ឆ៖** ដោះស្រាយច្រើនណាស់ ប៉ុនរកចាប់ថាត្រង់ណាមិនដោះស្រាយ នឹកមិនឃើញទេ។ គ្រាន់តែដោះស្រាយហ្នឹងវា -- ចំពោះប្រជាជនដោះស្រាយឧបត្ថម្ភគ្រប់ទាំងអស់ ប៉ុន្តែសហករណ៍ដោះស្រាយរឿងយើងដោះដែរ។ ហើយខោអាវបក្ស ប៉ុនខ្ញុំរៀបរយយកមកចែកជូន ដេរនៅហ្នឹង នៅស្រុកខ្ញុំហ្នឹងបានគ្រប់គ្រាន់។ ស្នើស្រុក សួរថា "យកធ្វើអី?" "យកទៅរៃ" ខុស។ ជម្រាបថា យកខោអាវខ្លះ ជូនកងនេះ កងនោះ កងនារី កងយុវជន។ ហ៎! ខោអាវដែលកាត់ហើយរហ័សចែកកម្មាភិបាលមួយខេត្តមួយតំបន់ នៅពេញឃ្លាំង។ ពេលចូលបើកវគ្គគាត់ថា "បងចាត់តាំងទៅយកខោអាវមកចែក" មិនមែន

គាត់ចែកខ្លួនគាត់ គាត់ថា "ចែកទៅ"។ វិធីចែក ខ្ញុំអង្គុយបត់ជើង ជូនដៃពីរក្នុងនាមអង្គការជំនួសឲ្យបក្ស តំបន់ លើកជូនដៃពីរ គេក៏អង្គុយមកលើកដៃពីរដែរ ជាកិត្តិយស។ អាវនីឡុង ពណ៌ទាហាន កាត់ដេរ មួយកំប្លេៗម្នាក់។ នេះការធ្វើឃើញថាចប់។ សូមអស់ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាសុខភាព ឧទាហរណ៍ទាក់ទងទៅនឹងថ្នាំសម្រាប់ព្យាបាល តើលោកមានធ្លាប់ទទួលសំណូមពរពីមន្ទីរពេទ្យ ឬក៏ពីមន្ទីរសុខភាពណា ដើម្បីទាក់ទងសុំថ្នាំពីលោក ឬក៏ពីថ្នាក់លើដែរទេ?

[១៥:៣៤:២៦]

**ឆ៖** ថ្នាំពេទ្យ ដល់គាត់រំឭកបាននឹកឃើញ។ ស្គាល់គេណាដែលគេនៅភ្នំពេញហ្នឹង ខុម រកបានខ្លះ ខ្ញុំក៏បានខ្លះ ពីពេទ្យ២២ហ្នឹងបានខ្លះ ដោះស្រាយចែកជូនទៅពេទ្យក្នុងស្រុក ពេទ្យឃុំ ពេទ្យស្រុក ពេទ្យឃុំ ពេទ្យចល័ត ចែកជូនហ្នឹង។ ក្រោយរំដោះដែលរកបានហ្នឹង មុនអត់ទេ មុនស្លថ្នាំ ធ្វើថ្នាំពេទ្យស្ដរួចទៅដាក់ស្បោង មួយដបៗ ចងស្បោងសេរ៉ូមមួយដប អាដបទឹកក្រូចហ្នឹង ហើយទៅបូមចាក់ចេះតែជាដែរ។ ហ្នឹងបច្ចេកទេសពេទ្យគេធ្វើ មិនមែនធ្វើលេងទេ ពេទ្យគេចេះ គេយល់។ ដោះស្រាយរួចអាហ្នឹង ហើយនារីពេទ្យចល័តហ្នឹង ដាក់អាហ្នឹងមួយកន្ត្រកទៅស្ពាយ អាមួយចាក់ៗតាមកង តាមផ្ទះអស់ ចាក់ជាហើយមកយកទៀត ហ្នឹងបានដើរតួ។ ចាស់ៗគាត់បញ្រោកលេង "ហ៎! ចៅយកទឹកក្រូចមកដាក់ឲ្យយាយហូបបន្តិច" សើច(ឮមិនច្បាស់)។ ថ្នាំពេទ្យហ្នឹង ហៅទឹកក្រូចទៅ ហើយទូលទៅកន្ទៀតទៅ។ សូមអស់ហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងទំហំនៃសេចក្ដីត្រូវការរបស់អ្នកជំងឺនៅក្នុងស្រុករបស់លោក ហើយនិងថ្នាំដែលលោករកបានហ្នឹងវាឆ្លើយតបគ្នាយ៉ាងដូចម្ដេចដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ពេជ្រ ជឹម៖**

**ឆ៖** ថ្នាំពេទ្យដែលរកបានហ្នឹងមិនធូនល្មមទេ ប៉ុន្តែថាវាធូរស្រាលមួយកម្រិតដែរ វាអន់ឈឺដែរ អន់គ្រុនដែរ បានថ្នាំក្រោយរំដោះមកហ្នឹង ថ្នាំពីភ្នំពេញ ថ្នាំល្អៗបានចែកហូរហែ។ ប្រជាជនក៏បាន រយៈហ្នឹងបានខោអាវ បានអី មានកូនចៅដែលនៅកងចល័តទៅភ្នំពេញគេផ្ញើមក បានធូរធារតាមហ្នឹង ថ្នាំ

ពេទ្យក៏បាន ខោសអាវក៏បាន។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា មានប្រភពណាទៀតដែលអាចទទួលបានថ្នាំពេទ្យនោះ ក្រៅពីយកពីភ្នំពេញទៅ?

**ផ៖** ខុម បានទៀត តាគាត់ឲ្យ គាត់យកភ្នំពេញដែរ។ ប៉ុន្តែ តាម៉ុកឲ្យ បក្សឲ្យ។

**ស៖** បាទ សូមអរគុណ។ លោកមានចាត់ចែងទិញថ្នាំពីក្រៅប្រទេសទេ? ឧទាហរណ៍ដូចប្រទេសវៀតណាមជាដើម?

**ផ៖** អត់មានទេ អត់បានរៀបចំទេ។

[១៥:៣៨:៤៩]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាសន្តិសុខ ខ្ញុំចង់សួរលោកថាតើលោកធ្លាប់មានប្រជាជនណាម្នាក់មកជួបលោកនិយាយអំពីបញ្ហាចាប់ចងសាច់ញាតិ ឬក៏បងប្អូនរបស់គេ ហើយស្នើសុំឲ្យលោកជួយដែរទេ?

**ផ៖** មាន ក្នុងបណ្ដាអ្នកទាំងអស់ហ្នឹង ដែលមកប៉ាានស្នើអស់ហ្នឹង ប៉ាានតែខ្ញុំ ក្រៅពីហ្នឹង គេអត់ប៉ាានទៅស្នើទេ។ បើទៅជាមួយ ខុម ពូជូនទៅបន្តិចទៅ រឿងទាក់ទងអ៊ីចឹង។ ហើយជួយដោះស្រាយ ប៉ុន្តែខ្លះវិវត្តន៍សភាពការណ៍វាទៅហួស ខ្លះគេមិនដោះ ឆ្លើយអ៊ីចឹង ប៉ុន្តែសូមអត់ទោសមុននឹងស្នើមិនមែនចេះតែស្នើៗ ហ្នឹងខ្ញុំបញ្ជាក់ជូនហូរហែហើយ។ គួរយល់ហើយចំណុចហ្នឹង មើលទៅវាទំនងហើយទុកចិត្តអ្នកដែលស្នើ មេដឹកនាំក៏ដោយ មេទុកចិត្តថ្ងៃហ្នឹង ទំនងនិយាយបានឬមិនបាន។ គាត់និយាយស្រួលមក ណែនាំអ៊ីចេះអ៊ីចុះទៅ យើងស៊កវិញ សុំអ៊ីចេះមួយ បងប្អូនយំខ្លាំងណាស់ អ៊ីចេះអ៊ីចុះអីទៅ សម្រួលៗគាត់ព្រម ហ្នឹងកើតហើយ។ មិនមែនអត់នេះទៅ អត់ធ្វើទេ គឺទៅជាប់ ដំណើរចង្អៀតផង ក៏ជ្រៀតទៅនឹងគ្នាហ្នឹង ចង្អៀតក៏ជ្រៀតទៅនឹងគ្នាហ្នឹង ហ្នឹងជម្រាបជូនត្រង់។ ហើយអ្នកត្រាំកក់គេសំណូមពរពី ញ៉ែរ អើយកុំកាចពេក ធ្វើត្រឹមប៉ុនពូជឹម បានហើយ។ ប៉ុន្តែខ្ញុំមិនអួតទេ ប៉ុន្តែមានខ្លះគេស្អប់ដែរហ្នឹង មិនដឹងធ្វើម៉េច។ ជួយអត់បាន បានស្អប់។

[១៥:៤១:១៣]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចាប់ខ្លួន អ្នកទោសណាម្នាក់ តើការចាប់ខ្លួននោះចេញពីថ្នាក់មូលដ្ឋាន ឬក៏ចេញពីថ្នាក់ណាផ្សេងទៀតដែលលោកអាចបញ្ជាក់អំពីសាច់រឿងដែលនាំឲ្យមានការចាប់ខ្លួន?

**ឆ៖** ហ្នឹងបញ្ជាក់ច្រើនដែរហើយ។ បញ្ជាក់ពីមុនមកក៏បានបញ្ជាក់ បន្ទាប់ៗមកក៏បញ្ជាក់។

**ស៖** បាទ លោកអាច--

**ឆ៖** ហើយបើធ្វើក៏--

**ស៖** ខ្ញុំសូមកាត់លោកសាក្សី។ លោកអាចបញ្ជាក់ជាៗចំនួន ជាភាគរយបានទេថា ភាគច្រើនករណីដែលចាប់ខ្លួន បើលោកប្រៀបធៀបពីត្រឹមលោកជាគណៈស្រុក ឬក៏ជាលេខាស្រុក ហើយបើប្រៀបធៀបខាងក្រោមលោក ហើយនិងខាងលើលោកវិញ តាមសមត្ថកិច្ចទាំងពីរហ្នឹង ខាងក្រោមលោកនិងខាងលើលោកហ្នឹង តើមូលហេតុ ឬក៏ការបញ្ជាឱ្យមានការចាប់ខ្លួនហ្នឹងចេញពីប្រភពណាច្រើនជាង?

**ឆ៖** ត្រឹមខ្ញុំឡើងធ្វើការ ហើយពីមុនមកក៏ខ្ញុំនៅហ្នឹងដែរ មិនមែនត្រឹមឡើងធ្វើការស្ដីទីហ្នឹងទេ មិនមានឱ្យមានការរៀបចំការចាប់ខ្លួនហ្នឹង គឺចង្អៀតណាស់ មិនព្រមឱ្យមានចាប់។ ហាក! បើហេតុផលយកមករឿងទំនាស់ ទំនាស់រឿងអី មួយ ពីរ លើកមក យកទៅប្រាប់តំបន់។ តំបន់ថា មិនទាន់ជឿទេ ឱ្យមិត្ត ជឹម ទៅពិនិត្យទៅ ម៉េចគាត់ប្រើតែខ្ញុំ។ ដល់ខ្ញុំទៅពិនិត្យឃើញរឿងទាស់គ្នា ខ្ញុំថាអត់ទេ ទាស់គ្នាបន្តិចបន្តួច។ គាត់ស្របតាមខ្ញុំ មានចាប់អី អប់រំទៅ។ ហ្នឹងអឺចឹង។

[១៥:៤៤:២៧]

**ស៖** បាទ លោកអាចបញ្ជាក់ថា ករណីដែលចាប់ខ្លួនដោយមូលហេតុឈ្លោះគ្នាបន្តិចបន្តួចហ្នឹងវាមានច្រើនប៉ុនណាដែរក្នុងស្រុករបស់លោក?

**ឆ៖** តិចណាស់ ទំនាស់គ្នាអឺចឹង មិនមានចាប់យកទៅដាក់ មានតែដោះស្រាយប្រជុំ ឱ្យរៀនសូត្រ ឃុំរៀនសូត្រ ស្រុកហៅមករៀនសូត្រមួយថ្ងៃ ឬចុះទៅនិយាយ ហៅនិយាយ។ រៀនសូត្រហ្នឹងមិនមែនេះ រៀនសូត្រ គឺនិយាយខ្លីៗ ចាំរៀននៅសាលាមានពេលណាធ្វើ។ ណែនាំ ប្រើពាក្យណែនាំវិញ ណែនាំខ្លីៗទៅ ឱ្យអត់ខិនទាំងសងខាងទៅ ហ្នឹងមានតិចៗ ចំនួនតិចទេ ប្រហែលជាដប់ទៅម្ភៃភាគរយ ហើយអប់រំបានមកល្អ ប៉ុណ្ណឹង។

**ស៖** បាទសូមអរគុណ។ ទាក់ទងករណីដែលមានលើកឡើងអំពីការលួចរបស់ហូប ឧទាហរណ៍ លួចបេះផ្លែឈើ លួចដំឡូងអីជាដើម។ តើលោកធ្លាប់ចូលរួមដោះស្រាយក្នុងករណីបែបនេះទេ?

**ឆ៖** បញ្ហាលួចផ្លែឈើ លួចនេះ លួចនោះ លួចមាន់ស្ងោរ លួចអង្ករដាំបាយ ហ្នឹងលើកមកប្រជុំ ហើយដោះស្រាយ ហើយណែនាំទៅឃុំ ទៅមេកងវិញថាសម្រួលចុះ ហើយឱ្យឈប់ធ្វើអីចឹង កុំប្រកាន់

គ្នាខ្លាំងពេកគ្នាហូបមួយឆ្អែតហើយ ឲ្យមកឃើញអ៊ីចឹង កុំយកឈ្មោះយកចាញ់អី។ ទាំងអស់គ្នាទាំងលេខាបក្សទាំងនេះហ្នឹងធ្វើ ណែនាំសម្រេចស្រុកហ្នឹងឲ្យឃុំធ្វើ សម្រួលទៅ មេកងធ្វើទៅ ហើយបើនៅជិតៗហ្នឹងហៅមកដោះស្រាយ ជួបប្រធាន ប្រជុំផ្ទាល់ ណែនាំផ្ទាល់។ ហើយតាមដានថ្ងៃក្រោយមកពីរនាក់ហ្នឹងម៉េចហើយ ទំនាស់ហ្នឹងយ៉ាងម៉េចហើយ ឲ្យដោះស្រាយ ស្រួលឲ្យល្អ តាមដាន មិនអត់ទេ។

**ស៖** លោកមានដែលជួបប្រទះពីករណីដែលចាប់ខ្លួនដោយមិនមានការដោះស្រាយពីលោកបញ្ជូនទៅមន្ទីរឃុំឃាំងណាមួយដោយមូលហេតុលួចរបស់ហូបនេះដែរទេ? លួចដំឡូង លួចផ្លែឈើ លួចមាន់ លួចបាយអីជាដើម ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ?

[១៥:៤៧:៥៧]

**ឆ៖** មិនមានទេ។ លួចផ្លែឈើអី ហើយចាប់បញ្ជូនមក អត់មានទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ។

លោកប្រធានខ្ញុំសូមអានជូន ERN ដែលលោកចៅក្រម ឡាវ៉ែន៍ ស្នើសុំអម្បាញ់មិញនេះ។ ភាសាបារាំងមានលេខ 01093760, ភាសាអង់គ្លេស 01050219, ភាសាខ្មែរ 00968938 បាទ។ ហើយលេខឯកសារគឺ E305/13.23.451។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការ -- មានបញ្ហាអ៊ីចេះលោក -- បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំមានសំណើជូនអង្គជំនុំជម្រះទាក់ទងទៅនឹងសាក្សីមួយនេះ។ នេះជាលើកទី១ ហើយក្នុងរយៈពេលពីរឆ្នាំដែលខ្ញុំស្នើសុំ ព្រោះថាឥឡូវនេះវាមានភាពមិនស៊ីសង្វាក់គ្នារវាងសាក្សីហ្នឹងនៅពេលខ្ញុំសួរ និងនៅពេលដែលចៅក្រម ឡាវ៉ែន៍សួរ និងនៅពេលមេធាវីការពារក្តីបានសួរ។ ដូច្នេះខ្ញុំមិនមែនខ្លួនខ្ញុំទេ គឺខ្ញុំចង់ស្នើសុំឲ្យអង្គជំនុំជម្រះសាកសួរទៅលើសំណួរមួយចំនួនទៅលើសាក្សីរូបនេះ ស្នើសុំឲ្យមានការបញ្ជាក់បំភ្លឺពីសាក្សី។ អ្វីដែលខ្ញុំចង់និយាយយោងគឺនៅពេលដែលខ្ញុំសួរសាក្សីនេះ ក៏ដូចជា

នៅពេលចៅក្រម ឡាវែន៍ សួរ សាក្សីគាត់ផ្តល់ថាគឺមានការបញ្ជាពីមេតំបន់ឲ្យបោសសម្អាតមន្ត្រីរដ្ឋការ ហើយបញ្ជានេះត្រូវបានគេផ្តល់មកឲ្យមេស្រុកឈ្មោះ ខុម ប៉ុន្តែនៅថ្ងៃនេះយើងឮថាមិនមាន -- ដែលមានបញ្ជាពី តាម៉ុក ដែលថាមិនឲ្យមានការប៉ះពាល់ទៅលើឋានន្តរសក្តិមួយចំនួន។ ដូច្នេះ ខ្ញុំគិតថាវាមានការប្រើប្រាស់ពាក្យ ហើយការបង្កាប់បញ្ជា ហើយជាបញ្ជាជាមូលដ្ឋានមួយ។ ខ្ញុំគិតថា មុនពេលដែលសាក្សីនេះគាត់ចាកចេញទៅ វាចាំបាច់សម្រាប់យើងទាំងអស់គ្នា ក៏ដូចជាអង្គជំនុំជម្រះដើម្បី -- ដែលអង្គជំនុំជម្រះត្រូវសាកសួរដើម្បីឲ្យមានការបញ្ជាក់អំពីសក្ខីកម្មរបស់សាក្សីដែលមានការលើកឡើងពីការបង្កាប់បញ្ជាខុសគ្នាចំនួនពីរ។

ខ្ញុំគិតថា វាមានឯកសាររាប់រយមកស្រុកត្រាំកក់ ដែលកត់ត្រាពីការចាប់ខ្លួនមន្ត្រីមានឋានន្តរសក្តិ និងចាប់ពីវរសេនីយ៍ឡើងទៅ។ ដូច្នេះ ខ្ញុំគិតថាអង្គជំនុំជម្រះអាចធ្វើការសាកសួរដើម្បីឲ្យមានការបញ្ជាក់បំភ្លឺពីសាក្សីនេះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ អង្គជំនុំជម្រះបន្ថែមម៉ោងពេលជូនទៅសហព្រះរាជអាជ្ញា មានពេល៥នាទីក្នុងការតាំងសំណួរបន្ថែមចំពោះសាក្សីនេះ ហើយនិងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី៥នាទីដែរ ដើម្បីសាកសួរសាក្សីពាក់ព័ន្ធជាមួយនឹងសំណួរចុងក្រោយ ដែលសួរឡើងដោយភាគីសហព្រះអាជអាជ្ញាពាក់-ព័ន្ធនឹងបញ្ហានេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីលោកទើបនឹងឮអ្វីដែលខ្ញុំបាននិយាយ ហើយហេតុផលដែលខ្ញុំងើបឈរឡើងនៅពេលនេះ ព្រោះថាយើងបានស្តាប់ឮនូវសក្ខីកម្មសំខាន់ៗចំនួនពីរខុសគ្នា ទាក់ទងទៅនឹងអ្វីដែលកើតឡើងចំពោះមន្ត្រីរដ្ឋការរបបលន់ នល់។ លោកបានប្រាប់ខ្ញុំ ហើយនិងចៅក្រម ឡាវែន៍ ថាមានការបញ្ជាចេញពីប្រធានតំបន់ឈ្មោះ សោម ពាក់ព័ន្ធទៅនឹងការបោសសម្អាតមន្ត្រីរដ្ឋការ។ ហើយនៅពេលដែលយើងសួរលោកអំពីភស្តុតាង គឺនិយាយអំពីការប្រជុំថ្នាក់ស្រុក ហើយលោកនិយាយថា យាយខុម ជាអ្នក

ផ្តល់ព័ត៌មានបន្តទាក់ទងទៅនឹងការបោសសម្អាតមន្ត្រីរដ្ឋការ។ ហើយយើងក៏បាន -- ហើយក៏មានការបង្ហាញឯកសារមួយចំនួនពីស្រុកត្រាំកក់ទៅនឹងការចាប់ខ្លួនមន្ត្រីរដ្ឋការលន់ នល់។ ប៉ុន្តែនៅព្រឹកនេះ នៅពេលដែលមេធាវីការពារក្តីសួរលោកអំពីកិច្ចប្រជុំដែលសាក្សីផ្សេងទៀតបានផ្តល់សក្ខីកម្ម លោកបានរៀបរាប់អំពីកិច្ចប្រជុំជាមួយ តាម៉ុក ដែលនៅក្នុងការប្រជុំនេះ តាម៉ុក ចេញបញ្ជាដែរថាឋានន្តរសក្តិមួយចំនួនមិនត្រូវឲ្យមានការ -- មិនត្រូវប៉ះពាល់នោះឡើយ។ ហើយលោកនិយាយថានោះ -- ហើយក៏លោកប្រើពាក្យថា "ជាការបញ្ជា" នៅពេលនោះ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់អំពីសក្ខីកម្មរបស់លោកនេះ ថាតើលោក ដែលលោកបានទទួលស្គាល់ថាមន្ត្រីរដ្ឋការលន់ នល់ បានគេសម្លាប់ ប៉ុន្តែហេតុអ្វីបានជា យាយខុម ជាបញ្ជូន -- បញ្ជាពីថ្នាក់លើមក? ហើយលោក ក្រោយមកទៀតលោកនិយាយអំពីតាម៉ុក ទៅវិញ តើមានបញ្ជា -- តើមានយ៉ាងម៉េចដែរ?

[១៥:៥៤:៣៦]

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមបញ្ជាក់ថា ហ្នឹងជាច្បាប់ ជាបញ្ញត្តិ។ បើមិនមានពី តាម៉ុក ក៏មិនមានមកតំបន់ដែរ។ បើមិនមានមកតំបន់ ក៏មិនមានមក ខុម ដែរ។ លោកប្រកាន់ថា ខ្ញុំថា តាម៉ុក អាហ្នឹងខ្ញុំជម្រាបឲ្យឃើញថាវាមកពីលើមក។ ក្បាលឫស -- ក្បាលហុងមក មិនមែនទឹកក្បាលហុង។ សូមបញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** យើងយល់ថាការបញ្ជាមកពីថ្នាក់លើ ប៉ុន្តែអ្វីដែលខ្ញុំចង់ស្វែងយល់ គឺថាតើលោកអាចពន្យល់បានទេ ហេតុអ្វីមានការបញ្ជាពីរខុសគ្នា គឺថាមានម្តងមានការផ្លាស់ប្តូរការបញ្ជាបែបនេះ? ព្រោះថាមានគោលនយោបោសសម្អាតដែរឬទេ? ហើយប្រសិនបើមាន តើគេចេញគោលនយោបាយបោសសម្អាតហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំចាប់មិនច្បាស់ចំណុចហ្នឹង មិនទាន់ សុំអត់ឆ្លើយ។ ខ្ញុំវែកញែកមកច្បាស់លាស់ច្រើនហើយ មិនសមមិនយល់ពាក្យមួយម៉ាត់ប៉ុណ្ណឹង។

[១៥:៥៦:២៤]

**ប្រធានអង្គជំនុំ៖**

មិនច្បាស់ទេសាក្សី ដោយសារមានចម្លើយសក្ខីកម្មរបស់លោកផ្ទុយគ្នា។ ឥឡូវកំពុងតែវែកញែកអាចំណុចផ្ទុយគ្នា។ សំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងចម្លើយរបស់លោកដែលផ្តល់សក្ខីកម្មផ្ទុយគ្នាប៉ុន្មានថ្ងៃនេះ លើចំណុចផ្ទុយគ្នា។ អ៊ីចឹងហើយបានជាការសួរដដែក ធ្វើដេញដោលនេះដើម្បីឲ្យ

លោកឆ្លើយបំភ្លឺអំពីចំណុចផ្ទុយគ្នាហ្នឹង វាមានហេតុផលអ្វី។ លោកឆ្លើយអំមិញ គឺអត់ច្បាស់ទេ។ ភាសាខ្មែរក៏ស្ដាប់មិនយល់អំពីខ្លឹមសារដែរ មិនមែនមូលហេតុមកពីបកស្រាយ បកប្រែភាសាទេ គឺនិយាយមិនច្បាស់លាស់ ស្ដាប់មិនយល់ អ៊ីចឹងហើយបានជាសួរ។ យើងបានប្រាប់លោកហើយថា ក្នុងនាមលោកជាសាក្សី មានកាតព្វកិច្ចត្រូវតែឆ្លើយការពិតតាំងពីដំបូងទី ក្នុងកាតព្វកិច្ចក្នុងការត្រូវការឆ្លើយ។

សហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរគឺខ្ញុំចង់សួរថា ប្រសិនបើវាពិតដូចដែលលោកនិយាយព្រឹកមិញនេះថា តាម៉ុក គាត់ចេញបញ្ជាមិនឱ្យប៉ះពាល់ទៅដល់មន្ត្រីរាជការនៅក្នុងឋានន្តរស័ក្តិមួយចំនួន។ ប្រសិនបើវាពិតដូច្នេះមែន ហេតុអ្វីបានជាលេខាតំបន់ឈ្មោះ សោម បង្គាប់ឱ្យយាយខុម, ហើយយាយខុម បង្គាប់មកមេឃុំ និងមេស្រុក ឱ្យបោសសម្អាតខ្មាំងទៅវិញ? តើហេតុអ្វី? តើការបង្គាប់បញ្ជាគឺមានការផ្លាស់ប្ដូរទៅតាមពេល ឬក៏យ៉ាងម៉េច?

**លោក ពេជ្រ ជឹម៖**

**ឆ៖** មុន និងក្រោយគេដឹងហើយ។ ដល់ច្រើនពេកវាវ័ណ្ឌ។ មុន និងក្រោយគេដឹង ក្រោយ១៧មេសា មកដឹង។ តែ ខុម ប្រជុំកំណត់បោស ដោះស្រាយ អាហ្នឹងក៏យកពីតាមកដែរហ្នឹង ដោះស្រាយកម្រិតថ្នាក់ ស័ក្តិប៉ុន្មានៗហ្នឹង ក្រោយ១៧មេសា។

[១៥:៥៩:០៩]

**ស៖** ខ្ញុំព្យាយាមម្ដងទៀត ខ្ញុំផ្ដល់ឯកសារធំៗពីរដុំដល់លោក ជូនលោក គឺE3/4095 និង E3/2107 គឺជាឯកសារមកពីក្រាំងតាចាន់ ដែលគ្របដណ្ដប់ទៅលើប៉ុន្មានខែក្នុងឆ្នាំ៧៦ ហើយនៅក្នុងសៀវភៅមួយ មានអ្នកទោស ១១០៥ ដែលគេរាយការណ៍ គឺ E3/4095។ ចំណែកឯ E3/2107 គឺខែធ្នូ៧៦ ដល់ខែមករា ៧៧ ហើយមានមនុស្ស៩0នាក់ ត្រូវបានគេរាយការណ៍ថាចាប់ខ្លួន ហើយសួរចម្លើយមនុស្សទាំងអស់នេះភាគច្រើនគឺជាអតីតទាហាន និងមន្ត្រីរដ្ឋការសម័យលន់នល់។ តើស្រុកជាអ្នកសម្រេចខ្លួនឯងក្នុងការចាប់មនុស្សទាំងអស់នេះ ឬក៏ស្រុកធ្វើការសម្រេចអនុលោមទៅតាមការបញ្ជាពីថ្នាក់លើ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!។

ក្រឡាបញ្ជីជូនបន្ទប់ព័ត៌មានទៅខាងអង្គភាពដឹកជញ្ជូនឱ្យពន្យារពេលរថយន្តឱ្យហើយទៅមិន

ម៉ោងប៉ុន្មានចប់ទេល្ងាចនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ដំបូងខ្ញុំសូមកត់សម្គាល់ពីរឿងពេលវេលាដែលលោកប្រធានផ្តល់ឲ្យភាគីសហព្រះរាជអាជ្ញា ៥នាទី ហើយខ្ញុំឃើញថាវាលើសច្រើនហើយ ៗម៉ោងក៏វាដល់ម៉ោងបួនដែរ ទី១។ ហើយទី២ ខ្ញុំយល់ឃើញថា ចម្លើយរបស់សាក្សីដែលបានលើកក្នុងពេលកន្លងមកនេះ ទោះបីវាមានចំណុចខុសគ្នា ក៏ប៉ុន្តែសាក្សីមិនៗមានកាតព្វកិច្ចថាត្រូវតែបង្ហាញថាសក្ខីកម្មរបស់គាត់ហ្នឹងស្រប គ្នាទាំងស្រុងទេ នេះជាឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះក្នុងការសម្រេចពិនិត្យទៅលើសក្ខីកម្មរបស់គាត់ថាគួរជឿចំណុចណា ហើយចំណុចណាដែលមិនគួរជឿ។ ហើយបើសិនជាយើងធ្វើការសួរដេញដោលបញ្ជាក់បន្ថែមទៅលើសក្ខីកម្មរបស់សាក្សីខ្ញុំយល់ថាដូចជាមិនមានផលល្អសម្រាប់ការស្វែងរក--

**ប្រធានអង្គជំនុំ៖**

បាទ បានហើយៗ ព្រោះអីពេលវេលា។ សូមអញ្ជើញអ្នកឆ្លើយតបនឹងសំណួរ!

**លោក ពេជ្រ ជឹម៖**

**ឆ៖** ការឆ្លើយរបស់ខ្ញុំជួនខ្លះវាព័ន្ធដែរ។ មុខក្រោយៗ វ័ណ្ដ។ ថាឲ្យខុសស្ថានការណ៍វាអត់ខុសនៅក្នុងហ្នឹង ប៉ុន្តែវាវ័ណ្ដ លៃអត់ច្បាស់ ដំណើរតែមួយហ្នឹងឯង។ សូមតុលាការដោះស្រាយតាមដំណើរចំណុចល្អ ណាមិនល្អ បដិសេធចោល។ សូមអ៊ីចឹងចុះ ហើយខ្ញុំក៏ -- ការចាំវាបាត់ហើយ អស់--

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ។

សូមអញ្ជើញតសហព្រះរាជអាជ្ញារង ម៉ោងបួនហើយ ១០នាទីហើយ ប្រហែលជាភាគីមេធាវីគេនឹងតសំណួរដូចលោកដែរ។

[១៦:០២:១០]

**លោក ខេល លីសាក់៖**

បាទ ខ្ញុំសំណួរមួយទៀតទេ លោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី នៅពេលដែលចាប់ផ្តើម គឺថាលោកនិយាយថាលោកចង់ប្រាប់ការពិត។ មានរបាយការណ៍វាប់រយនៃការចាប់ខ្លួនមន្ត្រីរដ្ឋការលន់ នល់។ ខ្ញុំសួរសាមញ្ញទេ ថាតើស្រុកទទួលបញ្ជាពី

ប្រធានតំបន់ឈ្មោះ សោម ឲ្យធ្វើការងារទាំងនេះដែរឬទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** រឿងនេះមានមុនមានក្រោយ ហើយតាមដែលខាង ខុម ប្រជុំហ្នឹងខ្ញុំដឹង។ ទៅជួយផែនការពីតំបន់ អ៊ីចឹងទៅបានដឹងពីគាត់ហ្នឹងឯង។ ហើយកំណត់ប្រជុំ ហើយសម្រេច តាមគោលការណ៍ហ្នឹងស័ក្តិ១ ទៅស័ក្តិ៥ហ្នឹងៗចាំប៉ុណ្ណឹង។ ឯហៅធ្វើចាប់ប៉ុន្មានៗ អត់មានទាន់ឃើញធ្វើទេ អនុវត្តទាន់ឃើញទេ គោលការណ៍គឺអ៊ីចឹង តែខ្ញុំក៏មិនបានធ្វើ បានតែចាប់ -- ណែនាំឃុំទៅចាប់អ្នកនេះ ចាប់នោះ អត់ទេ។

**លោក ឌេល លីសាក់៖**

សូមអរគុណ ដែលឲ្យអង្គជំនុំជម្រះផ្តល់ឱកាសឲ្យខ្ញុំដាក់សំណួរ ហើយខ្ញុំសូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះផងដែរ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីចុងជាក្រោយនេះមានសំណួរអ្វីសួរដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេ លោកប្រធាន យើងមិនមានសំណួរអ្វីទេ។ ព្រោះថា ចម្លើយរបស់សាក្សីគឺច្បាស់លាស់ណាស់ទៅហើយ។

**លោក គង់ សំអុន៖**

បាទ ខាងក្រុមមេធាវីលោក ខៀវ សំផន ក៏អត់មានសំណួរអីបន្ថែមដែរ។ សូមអរគុណ។

[១៦:០៥:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃចន្ទ ទី២៧ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃចន្ទ ទី២៧ មេសា ខែមេសា និងថ្ងៃបន្តបន្ទាប់ទៀត អង្គជំនុំជម្រះនឹងសវនាការដាក់ បង្ហាញឯកសារគន្លឹះពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមភាគីជ្រាប និងចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោក ពេជ្រ ជឹម ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងថ្នាក់ជាសាក្សីក្នុងរយៈពេលបួនថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការ

ស្វែងរកការពិតនៅក្នុងរឿងក្ដីនេះ។ ការផ្ដល់សក្ខីកម្មរបស់លោកមកដល់នេះ ដល់ទីបញ្ចប់ហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានក៏គោលដៅណាដែលលោកមានចង់ទៅបានហើយ។ សូមលោកវិលត្រឡប់វិញប្រកបដោយសុវត្ថិភាព ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរ ចំពោះមេធាវីការពារក្ដី -- មេធាវីប្រឹក្សា មឿង សុវណ្ណ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពសាក្សី និងអ្នកជំនាញក្នុងការជូនលោក ពេជ្រ ជឹម វិលត្រឡប់ទៅកាន់ទីលំនៅរបស់គាត់ ឬក៏គោលណាដែលគាត់មានបំណងចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ខៀវ សំផន និង នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញ នៅព្រឹកថ្ងៃចន្ទ ទី២៧ ខែមេសា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*